ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នៅ**ខេត្តត្បូងឃ្មុំ** ដូចមានសមាសភាពខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម រឿន រិទ្ធីរ័ត្ន | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២. ឯកឧត្តម អៀម គន្ធឌី | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៣. ឯកឧត្តម ថូ ជារិទ្ធ | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក។ |

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ៥ កើតខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ តុលា ឆ្នាំ២០១៩

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.........សហវ.........

**ប្រកាស**

**ស្ដីពី**

**ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យអនុវត្ត "ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់" ដែលហៅកាត់ថា "**ស.គ.ស.ប.**" សម្រាប់ក្រសួង-ស្ថាប័នសាធារណៈ និងមន្ទីរជំនាញរាជធានី ខេត្ត។

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ មិនអនុវត្តចំពោះ រដ្ឋបាលថ្នាក់ក្រោមជាតិ, សហគ្រាសសាធារណៈ, និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

"ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់" ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋាន "ស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ មូលដ្ឋានសាច់ប្រាក់"។

"ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់" ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ក្រុមប្រឹក្សាជាតិគណនេយ្យ អាចចេញគោលការណ៍ណែនាំស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ក្នុងករណីចាំបាច់។

**ប្រការ ៣.-**

អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដោយអនុលោមតាមស្តង់ដាដូចមានចែងក្នុងប្រការ ១ សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៤។

គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ដែលអនុវត្តដោយស្ថាប័នសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដោយអនុលោមតាមស្តង់ដាដូចមានចែងក្នុង ប្រការ ១ ស្របតាមគោលការណ៍ណែនាំ ដែលត្រូវកំណត់ដោយក្រុមប្រឹក្សាជាតិគណនេយ្យ។

**ប្រការ ៤.-**

ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គាធិការ ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ស្ថាប័នសាធារណៈដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ការរាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់

## មាតិកា


កថាខណ្ឌ

**ផ្នែកទី ១÷ លក្ខខណ្ឌចាំបាច់**

គោលបំណង

**១.១ វិសាលភាពនៃលក្ខខណ្ឌចាំបាច់ ........ ១.១.១ – ១.១.៦**

**១.២ មូលដ្ឋានសាច់ប្រាក់ ........ ១.២.១ – ១.២.១០**

និយមន័យ ........ ១.២.១ - ១.២.១០

មូលដ្ឋានគណនេយ្យសាច់ប្រាក់ ........ ១.២.២

សាច់ប្រាក់សមមូល ........ ១.២.៣ - ១.២.៥

សាច់ប្រាក់ដែលគ្រប់គ្រងដោយស្ថាប័នរាយការណ៍ ........ ១.២.៦ - ១.២.៩

ការគ្រប់គ្រងស្ថាប័ន ........ ១.២.១០

**១.៣ លក្ខខណ្ឌនៃការដាក់បង្ហាញ និងការលាតត្រដាង ........ ១.៣.១ – ១.៣.៣៣**

និយមន័យ ........ ១.៣.១ - ១.៣.៣

របាយការណ៍ហិរញ្ញវត្ថុ ........ ១.៣.៤ - ១.៣.១១

ព័ត៌មានដែលត្រូវដាក់បង្ហាញនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ .. ១.៣.១២ - ១.៣.២៤

ចំណាត់ថ្នាក់ ........ ១.៣.១៧ - ១.៣.១៨

បន្ទាត់គណនី, ចំណងជើង និងសរុបរង ........ ១.៣.១៩

ការរាយការណ៍លើមូលដ្ឋានសុទ្ធ ........ ១.៣.២០ - ១.៣.២៤

គោលនយោបាយគណនេយ្យ និងកំណត់សម្គាល់ពន្យល់ ........ ១.៣.២៥ - ១.៣.៣៣

រចនាសម្ព័ន្ធនៃកំណត់សម្គាល់ ........ ១.៣.២៥ - ១.៣.២៦

ការជ្រើសរើស និងការលាតត្រដាងអំពីគោលនយោបាយគណនេយ្យ ...... ១.៣.២៧ - ១.៣.៣៣

**១.៤ ការពិចារណាទូទៅ ........ ១.៤.១ - ១.៤.២៥**

កាលបរិច្ឆេទរាយការណ៍ ........ ១.៤.១ - ១.៤.៣

ភាពទាន់ពេលវេលា ........ ១.៤.៤

កាលបរិច្ឆេទអនុញ្ញាតចេញផ្សាយ ........ ១.៤.៥ - ១.៤.៦

ព័ត៌មានអំពីស្ថាប័ន ........ ១.៤.៧ - ១.៤.៨

ការរឹតត្បិតលើសមតុល្យសាច់ប្រាក់ និងការទទួលបានកម្ចី ........ ១.៤.៩ - ១.៤.១២

សង្គតិភាពនៃការដាក់បង្ហាញ ........ ១.៤.១៣ - ១.៤.១៥

ព័ត៌មានប្រៀបធៀប ........ ១.៤.១៦ - ១.៤.២០

ការកំណត់អត្តសញ្ញាណរបាយការណ៍ហិរញ្ញវត្ថុ ........ ១.៤.២១ - ១.៤.២៥

**១.៥ ការកែតម្រូវកំហុសឆ្គង** ........ **១.៥.១ - ១.៥.៥**

**១.៦ រូបិយបណ្ណបរទេស** ........ **១.៦.១ - ១.៦.៨**

និយមន័យ ........ ១.៦.១

ប្រព្រឹត្តិកម្មចំណូល ចំណាយ និងសមតុល្យសាច់ប្រាក់ជារូបិយបណ្ណបរទេស ........ ១.៦.២ - ១.៦.៨

**១.៧ ការដាក់បង្ហាញព័ត៌មានអំពីថវិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ** ........ **១.៧.១ - ១.៧.៤៦**

និយមន័យ ........ ១.៧.១ - ១.៧.៧

ផែនការថវិកាដែលបានអនុម័ត ........ ១.៧.២ - ១.៧.៤

ផែនការថវិកាដើមនិងផែនការថវិកាចុងក្រោយ ........ ១.៧.៥ - ១.៧.៦

ចំនួនទឹកប្រាក់ជាក់ស្តែង ........ ១.៧.៧

ការដាក់បង្ហាញការប្រៀបធៀបផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង ........ ១.៧.៨ - ១.៧.៣២

វិសាលភាព ........ ១.៧.៩ - ១.៧.១០

ការប្រៀបធៀបផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង ........ ១.៧.១១ - ១.៧.១៦

ការដាក់បង្ហាញ ........ ១.៧.១៧ - ១.៧.១៩

កម្រិតនៃការសរុបបញ្ចូលគ្នា ........ ១.៧.២០ - ១.៧.២២

ការផ្លាស់ប្តូរពីផែនការថវិកាដើមទៅផែនការថវិកាចុងក្រោយ ........ ១.៧.២៣ - ១.៧.២៤

មូលដ្ឋានប្រៀបធៀប ........ ១.៧.២៥ - ១.៧.៣០

ផែនការថវិកាច្រើនឆ្នាំ ........ ១.៧.៣១ - ១.៧.៣២

ការលាតត្រដាងកំណត់សម្គាល់នៃមូលដ្ឋានថវិកា ការិយបរិច្ឆេទ និងវិសាលភាព ... ១.៧.៣៣ - ១.៧.៤០

ការផ្ទៀងផ្ទាត់ចំនួនទឹកប្រាក់ជាក់ស្តែងតាមមូលដ្ឋានប្រៀបធៀប និងចំនួនទឹកប្រាក់ជាក់ស្តែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ........ ១.៧.៤១ - ១.៧.៤៦

ការបង្ហាញអំពីលក្ខខណ្ឌចាំបាច់នៃផ្នែកទី ១ នៃស្តង់ដា

**ផ្នែកទី ២៖ ការលាតត្រដាងបន្ថែមដែលត្រូវបានលើកទឹកចិត្ត**

**២.១ ការលើកទឹកចិត្តឱ្យមានការលាតត្រដាងបន្ថែម** ........ **២.១.១ – ២.១.១០៣**

និយមន័យ ........ ២.១.១ - ២.១.២

អត្ថប្រយោជន៍សេដ្ឋកិច្ច ឬសក្តានុពលសេវានាពេលអនាគត ........ ២.១.២

និរន្តរភាព ........ ២.១.៣ - ២.១.៥

ប្រតិបត្តិការដែលត្រូវបានគ្រប់គ្រង ........ ២.១.៦ - ២.១.១៣

ការប្រមូលប្រាក់ចំណូល ........ ២.១.៩ - ២.១.១១

លំហូរសាច់ប្រាក់ "ឆ្លងកាត់" ........ ២.១.១២

ការផ្ទេរកញ្ចប់ចំណាយ ........ ២.១.១៣

ការលាតត្រដាងថ្នាក់ចម្បងៗនៃលំហូរសាច់ប្រាក់ ........ ២.១.១៤ - ២.១.២១

ការលាតត្រដាងអំពីភាគីពាក់ព័ន្ធ ........ ២.១.២២ - ២.១.២៣

ការលាតត្រដាងអំពីទ្រព្យសកម្ម បំណុល ចំណូល ចំណាយ និងការប្រៀបធៀបជាមួយផែនការថវិកា ........ ២.១.២៤ - ២.១.៣២

ការប្រៀបធៀបជាមួយផែនការថវិកា ........ ២.១.២៨ - ២.១.៣២

របាយការណ៍ហិរញ្ញវត្ថុរួម ........ ២.១.៣៣ - ២.១.៦១

និយមន័យ ........ ២.១.៣៣

ស្ថាប័នសេដ្ឋកិច្ច ........ ២.១.៣៤ - ២.១.៣៦

វិសាលភាពនៃរបាយការណ៍ហិរញ្ញវត្ថុរួម ........ ២.១.៣៧ - ២.១.៤៦

ការផ្លាស់ប្តូរទៅកាន់របាយការណ៍ហិរញ្ញវត្ថុរួម ........ ២.១.៤៧ - ២.១.៤៩

នីតិវិធីនៃការរួមបញ្ចូលគ្នា ........ ២.១.៥០ - ២.១.៥២

ការលាតត្រដាងនៃការរួមបញ្ចូលគ្នា ........ ២.១.៥៣ - ២.១.៥៦

ការទិញ និងការលក់ស្ថាប័នក្រោមការគ្រប់គ្រង និងស្ថាប័នប្រតិបត្តិចំណុះផ្សេងទៀត ........ ២.១.៥៧ - ២.១.៦១

កិច្ចសម្រុះសម្រួលរួមគ្នា ........ ២.១.៦២ - ២.១.៦៣

ការរាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសដែលមានអតិផរណាខ្ពស់ ........ ២.១.៦៤ - ២.១.៧៦

ការអះអាងឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុ ........ ២.១.៦៦ - ២.១.៧១

ព័ត៌មានប្រៀបធៀប ........ ២.១.៧២

របាយការណ៍ហិរញ្ញវត្ថុរួម ........ ២.១.៧៣ - ២.១.៧៤

ការជ្រើសរើស និងការប្រើប្រាស់សន្ទស្សន៍តម្លៃទូទៅ ........ ២.១.៧៥ - ២.១.៧៦

ចំណាយដោយភាគីទីបីជំនួសឱ្យស្ថាប័ន ........ ២.១.៧៧ - ២.១.៨១

គម្រោងនៃជំនួយខាងក្រៅ និងជំនួយផ្សេងទៀត ........ ២.១.៨២ - ២.១.១០៣

និយមន័យ ........ ២.១.៨២

ជំនួយ ........ ២.១.៨៣ - ២.១.៨៩

ជំនួយខាងក្រៅដែលបានទទួល ........ ២.១.៩០

ជំនួយផ្សេងទៀតដែលបានទទួល ........ ២.១.៩១

ជំនួយខាងក្រៅ និងជំនួយផ្សេងទៀតដែលបានទទួល ........ ២.១.៩២ - ២.១.៩៩

ទំនិញ និងសេវាដែលបានទទួល ........ ២.១.១០០ - ២.១.១០៣

**២.២ រដ្ឋាភិបាលនិងស្ថាប័នសាធារណៈដទៃទៀត ដែលបំពេញដំណើរនៃការផ្លាស់ប្តូរទៅកាន់មូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ ........ ២.២.១ - ២.២.៩**

ការដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ........ ២.២.១ - ២.២.៣

របាយការណ៍ហិរញ្ញវត្ថុរួម -- ស្ថាប័នសេដ្ឋកិច្ច ............................................. ២.២.៤ - ២.២.៦

ការលាតត្រដាងដែលបានតម្រូវ និងការលាតត្រដាងដែលត្រូវបានលើកទឹកចិត្ត ក្រោមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ............................................. ២.២.៧

IPSAS ៣៣ - ការប្រើប្រាស់ស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈតាមមូលដ្ឋានបង្គរ ជាលើកដំបូង ............................................. ២.២.៨ - ២.២.៩

ឧបសម្ព័ន្ធ ២÷ ការបង្ហាញពីការលាតត្រដាងជាក់លាក់ដែលបានលើកទឹកចិត្តនៅក្នុងផ្នែកទី ២ នៃស្តង់ដា

ឧបសម្ព័ន្ធ ៣÷ ការដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ក្នុងទម្រង់ដែលតម្រូវបានដោយ IPSAS ២, របាយការណ៍លំហូរសាច់ប្រាក់

ឧបសម្ព័ន្ធ ៤÷ បុគ្គលិកលក្ខណៈបែបគុណភាពនៃព័ត៌មានដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ

**ឧបសម្ព័ន្ធ ១**

## ផ្នែកទី១÷ លក្ខខណ្ឌចាំបាច់

*ផ្នែកទី១ នៃស្តង់ដានេះ កំណត់ពីលក្ខខណ្ឌចាំបាច់សម្រាប់ការរាយការណ៍តាមមូលដ្ឋានគណនេយ្យសាច់ប្រាក់។ លក្ខខណ្ឌចាំបាច់តាមច្បាប់ត្រូវបានកំណត់ជាប្រភេទតួអក្សរទ្រេតដិត។ លក្ខខណ្ឌទាំងនេះប្រើពាក្យ "ត្រូវ" ដើម្បីបង្ហាញថា ពាក្យទាំងនោះជាលក្ខខណ្ឌចាំបាច់តាមច្បាប់។ នៅក្នុងស្តង់ដានេះ លក្ខខណ្ឌចាំបាច់តាមច្បាប់ត្រូវបានកំណត់ក្នុងបរិបទជាកថាខណ្ឌបែបអត្ថាធិប្បាយដែលមានលក្ខណៈសាមញ្ញ។ ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មិនមានគោលបំណងអនុវត្តចំពោះគណនីមិនសារវន្តនោះទេ។*

### គោលបំណង

គោលបំណងនៃស្តង់ដានេះ គឺដើម្បីកំណត់ពីរបៀបដែលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅនឹងត្រូវបានដាក់បង្ហាញតាមមូលដ្ឋានសាច់ប្រាក់។

គោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុដោយស្ថាប័នសាធារណៈ គឺដើម្បីផ្តល់នូវព័ត៌មានដែលមានប្រយោជន៍អំពីស្ថាប័នដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោល-បំណងទូទៅផ្សេងទៀត ដើម្បីគណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្ត។ ព័ត៌មានអំពីចំណូលសាច់ប្រាក់ ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់របស់ស្ថាប័ន គឺចាំបាច់ក្នុងគោលបំណងគណនេយ្យភាព និងផ្តល់នូវធាតុចូលដ៏សំខាន់សម្រាប់ការវាយតម្លៃលើសមត្ថភាពរបស់ស្ថាប័ន ដើម្បីបង្កើតសាច់ប្រាក់គ្រប់គ្រាន់នាពេលអនាគត និងប្រភពសាច់ប្រាក់ដែលអាចរកបាន និងការប្រើប្រាស់សាច់ប្រាក់ទាំងនោះ។ ដើម្បីធ្វើការសម្រេចចិត្ត និងវាយតម្លៃលើការសម្រេចចិត្តនេះក្នុងការបែងចែកធនធានសាច់ប្រាក់និងនិរន្តភាពនៃសកម្មភាពរបស់ស្ថាប័ន អ្នកប្រើប្រាស់តម្រូវឱ្យមានការយល់ដឹងអំពីពេលវេលា និងភាពច្បាស់លាស់នៃចំណូលសាច់ប្រាក់ និងចំណាយសាច់ប្រាក់។

ការអនុលោមតាមលក្ខខណ្ឌចាំបាច់ និងការលើកទឹកចិត្តនៃស្តង់ដានេះ នឹងធ្វើឱ្យប្រសើរនូវការរាយការណ៍ហិរញ្ញវត្ថុប្រកបដោយភាពពេញលេញ និងមានតម្លាភាពអំពីចំណូលសាច់ប្រាក់ ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់របស់ស្ថាប័ន។ ការអនុលោមនេះ ក៏នឹងជួយធ្វើឱ្យប្រសើរឡើងនូវភាពដែលអាចប្រៀបធៀបគ្នាបានរវាងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅរបស់ស្ថាប័នផ្ទាល់នៅក្នុងការិយបរិច្ឆេទមុនៗ និងជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នផ្សេងទៀតដែលអនុវត្តមូលដ្ឋានសាច់ប្រាក់។

### តួនាទីរបស់ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់

ក្រុមប្រឹក្សាជាតិគណនេយ្យយល់ឃើញថា គោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុអាចសម្រេចបានជោគជ័យបំផុតគឺតាមរយៈការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ។ ជាលទ្ធផល ក្រុមប្រឹក្សាជាតិគណនេយ្យបានលើកទឹកចិត្តឱ្យស្ថាប័នសាធារណៈដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដែលអនុលោមតាមលក្ខខណ្ឌចាំបាច់នៃស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ។ ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ត្រូវបានរៀបចំឡើងជាជំហានចាំបាច់ ដើម្បីជួយដល់ដំណើរការនៃការផ្លាស់ប្តូរទៅកាន់ការរាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាគណនេយ្យ

សាធារណៈ មូលដ្ឋានបង្គរ។ ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ផ្នែកទី ១ ពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីឈានទៅកាន់ការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរនៅឡើយទេ។ តួនាទីនៃការលាតត្រដាងបន្ថែមក្នុងផ្នែកទី២ នៃស្តង់ដា គឺដើម្បីជួយជំរុញដល់ការគាំទ្រនៃដំណើរការអន្តរកាលរបស់ស្ថាប័នទៅកាន់ការរាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ។

## ១.១ វិសាលភាពនៃលក្ខខណ្ឌចាំបាច់

១.១.១ ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ត្រូវបានរៀបចំឡើងដើម្បីអនុវត្តចំពោះស្ថាប័នសាធារណៈដែលបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងអស់ ដូចខាងក្រោម÷

(ក) មានទំនួលខុសត្រូវសម្រាប់ការផ្តល់សេវា ដើម្បីផ្តល់អត្ថប្រយោជន៍ដល់សាធារណជន និង/ឬ ដើម្បីបែងចែកឡើងវិញនូវប្រាក់ចំណូល និងទ្រព្យធន

(ខ) ផ្តល់ហិរញ្ញប្បទានដល់សកម្មភាពរបស់ខ្លួនដោយផ្ទាល់ ឬដោយប្រយោល តាមរយៈមធ្យោបាយសារពើពន្ធ និង/ឬ ការផ្ទេរពីស្ថាប័នផ្សេងទៀតរបស់រដ្ឋាភិបាល, វិភាគទានសង្គម, បំណុល, ឬកម្រៃ និង

(គ) គោលបំណងចម្បងរបស់ស្ថាប័នសាធារណៈ គឺមិនដើម្បីស្វែងរកប្រាក់ចំណេញនោះទេ។

១.១.២ *ស្ថាប័នសាធារណៈមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅតាមមូលដ្ឋានសាច់ប្រាក់ដែលបានផ្តល់និយមន័យនៅក្នុងស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់នេះ ត្រូវអនុវត្តលក្ខខណ្ឌចាំបាច់នៃផ្នែកទី ១ នៃស្តង់ដានេះ ក្នុងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន។*

១.១.៣ របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ ត្រូវបានរៀបចំឡើងជាចំបង ដើម្បីឆ្លើយតបទៅនឹងតម្រូវការព័ត៌មានរបស់អ្នកទទួលផលសេវា និងអ្នកផ្តល់ធនធានដែលមិនមានសិទ្ធិទាមទារនូវរបាយការណ៍ដែលបានរៀបចំឡើងដើម្បីបំពេញតាមតម្រូវការព័ត៌មានជាក់លាក់របស់ពួកគេ និងតំណាងអ្នកប្រើប្រាស់ទាំងនេះ។ អ្នកទទួលផលសេវា, អ្នកផ្តល់ធនធាន, និងតំណាងរបស់ពួកគេទាំងនោះ រួមមាន ពលរដ្ឋ, និវាសនជន, អ្នកជាប់ពន្ធ, អ្នកជាប់ពន្ធ, សមាជិកអង្គនីតិបញ្ញត្តិ (ឬសមាជិកស្ថាប័នប្រហាក់ប្រហែល), សមាជិកសភា (ឬសមាជិកស្ថាប័នតំណាងប្រហាក់ប្រហែល), ភ្នាក់ងារម្ចាស់ជំនួយ, អ្នកផ្តល់កម្ចី, និងបុគ្គលដទៃទៀតដែលផ្តល់ធនធាន ឬទទួលអត្ថប្រយោជន៍ពីសេវារបស់រដ្ឋាភិបាល។ របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅដែលត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការព័ត៌មានរបស់អ្នកទទួលផលសេវានិងអ្នកផ្តល់ធនធាន ដើម្បីគណនេយ្យភាពនិងការធ្វើសេចក្តីសម្រេចចិត្ត ក៏អាចផ្តល់នូវព័ត៌មានដែលមានសារៈប្រយោជន៍ចំពោះភាគីដទៃផងដែរ។ របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ រួមបញ្ចូលទាំងរបាយការណ៍ហិរញ្ញវត្ថុទាំងឡាយណាដែលត្រូវបានដាក់បង្ហាញដាច់ដោយឡែក ឬត្រូវបានដាក់បង្ហាញជាមួយនឹងឯកសារសាធារណៈផ្សេងទៀតដូចជា របាយការណ៍ប្រចាំ

ឆ្នាំ។ សម្រាប់គោលបំណងនៃស្តង់ដានេះ ពាក្យ "របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ" និង "របាយការណ៍ហិរញ្ញវត្ថុ" អាចត្រូវបានប្រើជំនួសគ្នាបាន បើមិនមានការបញ្ជាក់ណាមួយផ្សេងពីនេះ។

១.១.៤ ស្ថាប័នរាយការណ៍ គឺជាស្ថាប័នមួយដែលដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ឬនៅពេលដែលស្ថាប័នគ្រប់គ្រងធ្វើការជ្រើសរើសដើម្បីដាក់បង្ហាញបណ្តុំរបាយការណ៍ហិរញ្ញវត្ថុ នោះស្ថាប័នរាយការណ៍រួមមានស្ថាប័នគ្រប់គ្រង និងស្ថាប័នក្រោមការគ្រប់គ្រងមួយឬច្រើន ដែលដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុហាក់បីដូចជាស្ថាប័នទាំងនោះគឺជាស្ថាប័នតែមួយ។ ស្ថាប័នសាធារណៈមួយ (ចាប់ពីពេលនេះតទៅសំដៅដល់ស្ថាប័នរាយការណ៍ ឬស្ថាប័ន បើមិនមានការបញ្ជាក់ណាមួយផ្សេងពីនេះ) គឺជារដ្ឋាភិបាល ឬស្ថាប័នសាធារណៈដទៃទៀត, កម្មវិធី ឬសកម្មភាពណាមួយដែលងាយនឹងកត់ចំណាំដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងសម្រាប់សកម្មភាពទាំងនោះ។ កថាខណ្ឌ ១.៤.៧ នៃស្តង់ដានេះតម្រូវឱ្យមានការលាតត្រដាងព័ត៌មានជាក់លាក់អំពីស្ថាប័ន និងសកម្មភាពដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងពាក់ព័ន្ធនឹងស្ថាប័ន និងសកម្មភាពរបស់ស្ថាប័នទាំងនោះ។

១.១.៥ ស្តង់ដានេះអនុវត្តស្មើគ្នាចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នដោយឡែកមួយ និងចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នរាយការណ៍មួយដែលមានស្ថាប័នគ្រប់គ្រងមួយនិងស្ថាប័នក្រោមការគ្រប់គ្រងមួយឬច្រើន។ ស្តង់ដាតម្រូវឱ្យមានការរៀបចំរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដែលទទួលស្គាល់សាច់ប្រាក់ដែលបានគ្រប់គ្រងដោយស្ថាប័នរាយការណ៍ និងការលាតត្រដាងពីគោលនយោបាយគណនេយ្យ និងកំណត់សម្គាល់ពន្យល់។

១.១.៦ *ស្ថាប័នមួយដែលរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមលក្ខខណ្ឌចាំបាច់នៃ ផ្នែកទី ១ របស់ស្តង់ដានេះត្រូវលាតត្រដាងពីការពិតលើរបាយការណ៍ហិរញ្ញវត្ថុនោះ។ របាយការណ៍ហិរញ្ញវត្ថុមិនត្រូវបានចាត់ទុកថាអនុលោមតាមស្តង់ដានេះឡើយ ប្រសិនបើរបាយការណ៍ហិរញ្ញវត្ថុនោះមិនបានអនុលោមតាមគ្រប់លក្ខខណ្ឌចាំបាច់ទាំងអស់នៅក្នុងផ្នែកទី ១ នៃស្តង់ដានេះ។*

**១.២ មូលដ្ឋានសាច់ប្រាក់**

**និយមន័យ**

១.២.១ *ពាក្យដែលបានប្រើក្នុងស្តង់ដានេះត្រូវបានផ្តល់និយមន័យជាក់លាក់ដូចខាងក្រោម÷*

*<u>សាច់ប្រាក់</u> រួមមាន សាច់ប្រាក់ក្នុងដៃ, ប្រាក់បញ្ញើគ្មានកាលកំណត់ និងសាច់ប្រាក់សមមូល។*

*<u>មូលដ្ឋានសាច់ប្រាក់</u> មានន័យថា ជាមូលដ្ឋានគណនេយ្យមួយដែលទទួលស្គាល់ប្រតិបត្តិការ និងព្រឹត្តិការណ៍ដទៃទៀត តែនៅពេលដែលសាច់ប្រាក់ត្រូវបានទទួល ឬត្រូវបានទូទាត់ប៉ុណ្ណោះ។*

*<u>សាច់ប្រាក់សមមូល</u> គឺជាការវិនិយោគរយៈពេលខ្លីមួយដែលអាចប្តូរទៅជាសាច់ប្រាក់បានដោយងាយ និងមានហានិភ័យលើការប្រែប្រួលតម្លៃតិចតួចបំផុត។*

*លំហូរសាច់ប្រាក់* គឺជាលំហូរចូល និងលំហូរចេញនៃសាច់ប្រាក់។

*ចំណាយសាច់ប្រាក់* គឺជាលំហូរចេញនៃសាច់ប្រាក់។

*ចំណូលសាច់ប្រាក់* គឺជាលំហូរចូលនៃសាច់ប្រាក់។

*ការគ្រប់គ្រងសាច់ប្រាក់* កើតឡើងនៅពេលស្ថាប័នអាចប្រើ ឬក៏អាចទទួលអត្ថប្រយោជន៍ពីសាច់ប្រាក់ ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន ហើយអាចមិនរួមបញ្ចូល ឬដាក់បញ្ញត្តិលើការប្រើប្រាស់របស់អ្នកដទៃចំពោះអត្ថប្រយោជន៍នោះ។

*ការគ្រប់គ្រងស្ថាប័ន÷* ស្ថាប័នមួយគ្រប់គ្រងស្ថាប័នដទៃ នៅពេលដែលស្ថាប័នទទួលរងឥទ្ធិពល ឬមានសិទ្ធិទទួលបានអត្ថប្រយោជន៍ផ្សេងៗពីការចូលរួមរបស់ខ្លួនជាមួយស្ថាប័នដទៃនោះ និងមានឥទ្ធិពលដល់ចរិកលក្ខណៈ ឬទំហំអត្ថប្រយោជន៍ទាំងនោះតាមរយៈសិទ្ធិរបស់ខ្លួនមកលើស្ថាប័នផ្សេងទៀត។

*ស្ថាប័នក្រោមការគ្រប់គ្រង ឬស្ថាប័នបុត្រសម្ព័ន្ធ* គឺជាស្ថាប័នមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នដទៃ (ស្គាល់ថាជា ស្ថាប័នគ្រប់គ្រង) ។

### មូលដ្ឋានគណនេយ្យសាច់ប្រាក់

១.២.២ មូលដ្ឋានគណនេយ្យសាច់ប្រាក់ទទួលស្គាល់ប្រតិបត្តិការ និងព្រឹត្តិការណ៍នៅពេលដែលសាច់ប្រាក់ (រួមបញ្ចូលទាំង សាច់ប្រាក់សមមូល)ត្រូវបានទទួល ឬត្រូវបានទូទាត់ដោយស្ថាប័នប៉ុណ្ណោះ។ របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងតាមមូលដ្ឋានសាច់ប្រាក់ ផ្តល់ឱ្យអ្នកអាននូវព័ត៌មានអំពីប្រភពសាច់ប្រាក់ដែលបានទទួលនៅក្នុងអំឡុងការិយបរិច្ឆេទ, គោលបំណងដែលសាច់ប្រាក់ត្រូវបានប្រើ និងសមតុល្យសាច់ប្រាក់នាកាលបរិច្ឆេទរាយការណ៍។ ការវាស់វែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ផ្តោតលើសមតុល្យសាច់ប្រាក់ និងការផ្លាស់ប្តូរ។ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ អាចផ្តល់នូវព័ត៌មានបន្ថែមអំពីបំណុលដូចជា, ទឹកប្រាក់ត្រូវសង និងកម្ចី និងទ្រព្យសកម្មមិនមែនសាច់ប្រាក់មួយចំនួនដូចជា, ទឹកប្រាក់ត្រូវទារ, ការវិនិយោគ និងទ្រព្យ រោងចក្រ និងបរិក្ខារ។

### សាច់ប្រាក់សមមូល

១.២.៣ សាច់ប្រាក់សមមូល ត្រូវបានរក្សាទុកសម្រាប់គោលបំណងបំពេញកាតព្វកិច្ចសាច់ប្រាក់រយៈពេលខ្លីជាជាងសម្រាប់ការវិនិយោគ ឬគោលបំណងផ្សេងទៀត។ ការវិនិយោគមួយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសាច់ប្រាក់សមមូល លុះត្រាតែការវិនិយោគនោះអាចប្តូរទៅជាសាច់ប្រាក់បានដោយងាយ និងមានហានិភ័យលើការប្រែប្រួលតម្លៃតិចតួចបំផុត។ ដូច្នេះ ការវិនិយោគ ជាទូទៅ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសាច់ប្រាក់សមមូល នៅពេលដែលការវិនិយោគនោះមានកាលបរិច្ឆេទផុតកំណត់ក្នុងរយៈពេលខ្លី (បីខែ ឬតិចជាង) គិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់ការវិនិយោគ។ ការវិនិយោគមូលធនមិនត្រូវបានរាប់បញ្ចូលជាសាច់ប្រាក់សមមូលនោះទេ លុះត្រាតែការវិនិយោគមូលធននោះ មានលក្ខណៈសម្បត្តិជាសាច់ប្រាក់សមមូល។

១.២.៤ កម្ចីធនាគារ ជាទូទៅ ត្រូវបានចាត់ទុកថានាំឱ្យកើតមានលំហូរចូលនៃសាច់ប្រាក់។ ទោះបីជាយ៉ាងណា នៅក្នុងយុត្តាធិការមួយចំនួន ឥណទានវិបារូបដែលត្រូវសងឡើងវិញតាមតម្រូវការ បង្កើតឱ្យមានផ្នែកដ៏សំខាន់មួយនៃការគ្រប់គ្រងសាច់ប្រាក់របស់ស្ថាប័ន។ នៅក្នុងស្ថានភាពបែបនេះ ឥណទានវិបារូបត្រូវបានរួមបញ្ចូលជាធាតុមួយនៃសាច់ប្រាក់។ បុគ្គលិកលក្ខណៈនៃកិច្ចសម្រុះសម្រួលរបស់ធនាគារបែបនេះ គឺថា សមតុល្យធនាគារតែងតែប្រែប្រួលពីវិជ្ជមានទៅជាការដកហួសកម្រិត។

១.២.៥ លំហូរសាច់ប្រាក់មិនរួមបញ្ចូលនូវលំហូររវាងគណនីដែលបង្កើតឱ្យមានសាច់ប្រាក់នោះទេ ដោយសារគណនីទាំងនេះគឺជាផ្នែកមួយនៃការគ្រប់គ្រងសាច់ប្រាក់របស់ស្ថាប័ន ជាជាងការកើនឡើង ឬការធ្លាក់ចុះនៃសាច់ប្រាក់ដែលស្ថាប័នគ្រប់គ្រង។ ការគ្រប់គ្រងសាច់ប្រាក់ រួមបញ្ចូលទាំងការវិនិយោគសាច់ប្រាក់លើសក្នុងដៃ ទៅក្នុងសាច់ប្រាក់សមមូល។

## សាច់ប្រាក់ដែលគ្រប់គ្រងដោយស្ថាប័នរាយការណ៍

១.២.៦ សាច់ប្រាក់ត្រូវបានគ្រប់គ្រងដោយស្ថាប័ន នៅពេលស្ថាប័នអាចប្រើ ឬ ក៏អាចទទួលបានអត្ថប្រយោជន៍ពីសាច់ប្រាក់នោះ ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន និងមិនរួមបញ្ចូល ឬ ដាក់បញ្ញត្តិលើការប្រើប្រាស់របស់អ្នកដទៃចំពោះអត្ថប្រយោជន៍ទាំងនោះ។ សាច់ប្រាក់ដែលត្រូវបានប្រមូល ឬធ្វើវិភាជន៍ ឬត្រូវបានផ្តល់ជាអំណោយទៅកាន់ស្ថាប័នមួយ ដែលស្ថាប័នអាចប្រើដើម្បីផ្តល់មូលនិធិដល់គោល-បំណងប្រតិបត្តិការរបស់ខ្លួន, ទទួលទ្រព្យសកម្មមូលធន, ឬ សងបំណុលរបស់ខ្លួន គឺត្រូវបានគ្រប់គ្រងដោយស្ថាប័ន។

១.២.៧ ចំនួនទឹកប្រាក់ដែលបានដាក់បញ្ញើនៅក្នុងគណនីធនាគាររបស់ស្ថាប័ន គឺត្រូវបានគ្រប់គ្រងដោយស្ថាប័ននោះ។ នៅក្នុងករណីមួយចំនួន សាច់ប្រាក់ដែលស្ថាប័នរបស់រដ្ឋាភិបាលមួយ÷

(ក) ប្រមូលជំនួសឱ្យរដ្ឋាភិបាលរបស់ខ្លួន (ឬស្ថាប័នដទៃ) គឺត្រូវបានដាក់បញ្ញើក្នុងគណនីធនាគារផ្ទាល់របស់ខ្លួន មុនពេលផ្ទេរទៅក្នុងប្រាក់ចំណូលរួម ឬទៅក្នុងគណនីរបស់រដ្ឋាភិបាលទូទៅដទៃទៀត និង

(ខ) គ្រោងនឹងផ្ទេរទៅភាគីទីបី ជំនួសឱ្យរដ្ឋាភិបាលរបស់ខ្លួន គឺត្រូវបានដាក់បញ្ញើជាលើកដំបូងនៅក្នុងគណនីធនាគារផ្ទាល់របស់ខ្លួន មុនពេលផ្ទេរទៅឱ្យគម្រជនស្របច្បាប់។

នៅក្នុងករណីទាំងនេះ ស្ថាប័ននឹងគ្រប់គ្រងសាច់ប្រាក់សម្រាប់តែកាវិយបរិច្ឆេទនៅក្នុងអំឡុងពេលដែលសាច់ប្រាក់ស្ថិតនៅក្នុងគណនីធនាគាររបស់ខ្លួនប៉ុណ្ណោះ មុនពេលផ្ទេរទៅក្នុងប្រាក់ចំណូលរួម ឬទៅក្នុងគណនីធនាគារដែលគ្រប់គ្រងដោយរដ្ឋាភិបាលដទៃ ឬទៅភាគីទីបី។ កថាខណ្ឌ ១.៤.៩ តម្រូវឱ្យមានការលាតត្រដាងពីសមតុល្យសាច់ប្រាក់ដែលបានរក្សាទុកដោយស្ថាប័នមួយ នាកាលបរិច្ឆេទរាយការណ៍ដែលស្ថាប័នមិនអាចប្រើបាន ឬ ប្រឈមនឹងការរឹតបន្តឹងពីកត្តាខាងក្រៅ។ សេចក្តីណែនាំបន្ថែមលើការ

ធ្វើប្រព្រឹត្តិកម្មលំហូរសាច់ប្រាក់ដែលស្ថាប័នផ្តល់ជំនួសឱ្យស្ថាប័នផ្សេងទៀត ត្រូវបានរួមបញ្ចូលនៅក្នុងកថាខណ្ឌ ២.១.៦ ទៅ ២.១.១៣ នៃផ្នែកទី ២ នៃស្តង់ដានេះ។

១.២.៨ នៅក្នុងយុត្តាធិការមួយចំនួន រដ្ឋាភិបាលមួយនឹងគ្រប់គ្រងការចំណាយរបស់នាយកដ្ឋាននីមួយៗ និងស្ថាប័នផ្សេងទៀត តាមរយៈមុខងាររតនាគារមជ្ឈការដែលជារឿយៗត្រូវបានគេសំដៅដល់ "គណនីទោលរតនាគារ"។ ក្រោមកិច្ចសម្រុះសម្រួលទាំងនេះ នាយកដ្ឋាននិងស្ថាប័ននីមួយៗមិនបង្កើតគណនីធនាគារដាច់ដោយឡែកពីគ្នានោះទេ។ ផ្ទុយទៅវិញ មុខងាររតនាគារមជ្ឈការនឹងដើរតួនាទីជាធនាគារជំនួសឱ្យនាយកដ្ឋាននីមួយៗ និងស្ថាប័នផ្សេងទៀត។ លំហូរចូលនៃសាច់ប្រាក់, លំហូរចេញនៃសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់របស់ស្ថាប័នដែលហូរចូល ឬ ដែលត្រូវបានរក្សាទុកនៅក្នុងគណនីទោលរតនាគារ នឹងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដោយអនុលោមទៅតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.៤។ តាមទស្សនៈរបស់មុខងាររតនាគារមជ្ឈការ ចំណាយជំនួសឱ្យនាយកដ្ឋាននីមួយៗនិងស្ថាប័នផ្សេងទៀត ត្រូវបានចាត់ទុកជាការផ្លាស់ប្តូរនៅក្នុងគណនីរបស់ពួកគេ ដោយឆ្លុះបញ្ចាំងពីវិធីសាស្ត្រដែលធនាគារបានប្រើនៅក្នុងគណនេយ្យសម្រាប់ចំណាយ ដែលបានធ្វើឡើងជំនួសឱ្យអតិថិជនរបស់ខ្លួន។

១.២.៩ នៅក្នុងករណីមួយចំនួន មុខងាររតនាគារមជ្ឈការនឹងត្រូវបានអនុវត្តដោយស្ថាប័នមួយដែលគ្រប់គ្រងគណនីធនាគារ ដែលចំណាយជំនួសឱ្យនាយកដ្ឋានប្រតិបត្តិការនីមួយៗនិងស្ថាប័នផ្សេងទៀត ត្រូវបានធ្វើឡើង។ នៅក្នុងករណីទាំងនេះ ការផ្ទេរ និងចំណាយពីគណនីធនាគារទាំងនេះ ឆ្លុះបញ្ចាំងពីចំណូលនិងចំណាយសាច់ប្រាក់ដែលស្ថាប័នកណ្តាលគ្រប់គ្រងជំនួសឱ្យនាយកដ្ឋានប្រតិបត្តិការនីមួយៗ និងស្ថាប័នផ្សេងទៀត។ កថាខណ្ឌ ១.៣.១៣ បញ្ជាក់ថា ចំណូលនិងចំណាយសាច់ប្រាក់ដែលកើតឡើងពីប្រតិបត្តិការដែលស្ថាប័នបានគ្រប់គ្រងជំនួសឱ្យស្ថាប័នផ្សេងទៀត និងដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសំខាន់ អាចត្រូវបានរាយការណ៍តាមមូលដ្ឋានសុទ្ធ។ កថាខណ្ឌ ១.៤.៩ តម្រូវឱ្យមានការលាតត្រដាងពីសមតុល្យសាច់ប្រាក់ដែលបានរក្សាទុកដោយស្ថាប័ន នាកាលបរិច្ឆេទរាយការណ៍ដែលមិនអាចប្រើបានដោយស្ថាប័ន ឬប្រឈមនឹងការរឹតបន្តឹងពីកត្តាខាងក្រៅ។

## ការគ្រប់គ្រងស្ថាប័ន

១.២.១០ រដ្ឋាភិបាលនិងស្ថាប័នសាធារណៈផ្សេងទៀត អាចគ្រប់គ្រងស្ថាប័នច្រើន រួមបញ្ចូលទាំងនាយកដ្ឋានរដ្ឋាភិបាល, ភ្នាក់ងារ និងស្ថាប័នសាធារណៈពាណិជ្ជកម្ម។ របាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានរៀបចំឡើងពាក់ព័ន្ធនឹងស្ថាប័នរាយការណ៍មួយដែលមានស្ថាប័ន ឬ ស្ថាប័នគ្រប់គ្រងមួយ និងស្ថាប័នដែលត្រូវបានគ្រប់គ្រងទាំងអស់ ឬមួយចំនួន។ ស្តង់ដានេះលើកទឹកចិត្ត (ក្នុងកថាខណ្ឌ ២.១.៣៧) ប៉ុន្តែមិនតម្រូវឱ្យស្ថាប័នគ្រប់គ្រងធ្វើការរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ដែលមានស្ថាប័នគ្រប់គ្រង និងស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ ជាមួយនឹងការលើកលែងនៅក្នុងស្ថានភាពកំណត់ជាក់លាក់។ កត្តា

ដែលត្រូវពិចារណាក្នុងការវាយតម្លៃ ថាតើស្ថាប័នមួយគ្រប់គ្រងស្ថាប័នផ្សេងទៀតសម្រាប់គោលបំណងរាយការណ៍ហិរញ្ញវត្ថុ ឬក៏យ៉ាងណា គឺត្រូវបានកំណត់នៅក្នុង IPSAS ៣៥, *របាយការណ៍ហិរញ្ញវត្ថុរួម*។

## ១.៣ លក្ខខណ្ឌនៃការដាក់បង្ហាញ និងការលាតត្រដាង

**និយមន័យ**

១.៣.១ *ពាក្យខាងក្រោមត្រូវបានប្រើនៅក្នុងស្តង់ដានេះជាមួយនឹងនិយមន័យដូចបានបញ្ជាក់÷*

*<u>គោលនយោបាយគណនេយ្យ</u> គឺជាគោលការណ៍, មូលដ្ឋាន, ការសន្មត, វិធាន និងការអនុវត្តជាក់លាក់ដែលស្ថាប័នបានប្រើក្នុងការរៀបចំ និងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។*

*<u>ភាពជាសារវន្ត÷</u> ព័ត៌មានមានភាពជាសារវន្ត ប្រសិនបើការលុបបំបាត់ឬការរាយការណ៍ខុស អាចជះឥទ្ធិពលដល់ការអនុវត្តគណនេយ្យភាពរបស់ស្ថាប័ន ឬការសម្រេចចិត្តដែលអ្នកប្រើប្រាស់ធ្វើ ផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នដែលបានរៀបចំឡើង សម្រាប់ការិយបរិច្ឆេទរាយការណ៍នោះ។ ភាពជាសារវន្តផ្អែកលើទាំងចរិកលក្ខណៈ និងចំនួនគណនីដែលត្រូវបានវិនិច្ឆ័យក្នុងស្ថានភាពជាក់លាក់របស់ស្ថាប័ននីមួយៗ។*

*<u>កាលបរិច្ឆេទរាយការណ៍</u> មានន័យថា កាលបរិច្ឆេទនៃថ្ងៃចុងក្រោយនៃការិយបរិច្ឆេទរាយការណ៍ដែលរបាយការណ៍ហិរញ្ញវត្ថុមានជាប់ពាក់ព័ន្ធ។*

១.៣.២ របាយការណ៍ហិរញ្ញវត្ថុ កើតចេញពីដំណើរការប្រតិបត្តិការធំៗដែលបានរៀបចំឡើង ដោយត្រូវបានសរុបបញ្ចូលគ្នាទៅតាមក្រុម, ចរិកលក្ខណៈ និងមុខងាររបស់ពួកគេ។ ដំណាក់កាលចុងក្រោយនៅក្នុងដំណើរការសរុបបញ្ចូលគ្នា និងការធ្វើចំណាត់ថ្នាក់ គឺការដាក់បង្ហាញទិន្នន័យបង្រួញ និងទិន្នន័យដែលបានធ្វើចំណាត់ថ្នាក់ដែលបង្កើតបានជាបន្ទាត់គណនីនៅលើផ្ទៃមុខនៃរបាយការណ៍ហិរញ្ញវត្ថុ ឬនៅក្នុងកំណត់សម្គាល់។ ប្រសិនបើបន្ទាត់គណនីមួយមិនមានភាពជាសារវន្តទេ បន្ទាត់គណនីនឹងត្រូវបានសរុបបញ្ចូលគ្នាជាមួយនឹងគណនីផ្សេងទៀតនៅលើផ្ទៃមុខនៃរបាយការណ៍ហិរញ្ញវត្ថុ ឬនៅក្នុងកំណត់សម្គាល់។ គណនីមួយដែលមិនមានភាពជាសារវន្តគ្រប់គ្រាន់ ដើម្បីធានាការដាក់បង្ហាញដាច់ដោយឡែកនៅលើផ្ទៃមុខនៃរបាយការណ៍ហិរញ្ញវត្ថុ យ៉ាងណាក៏ដោយ អាចមានភាពជាសារវន្តគ្រប់គ្រាន់ ដែលគណនីនោះគួរត្រូវបានដាក់បង្ហាញដាច់ដោយឡែកនៅក្នុងកំណត់សម្គាល់។

១.៣.៣ គោលការណ៍នៃភាពជាសារវន្តបានចែងថា លក្ខខណ្ឌចាំបាច់នៃការលាតត្រដាងជាក់លាក់នៃស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មិនចាំបាច់ត្រូវបំពេញតាមឡើយ បើព័ត៌មានមិនមានភាពជាសារវន្ត។

**របាយការណ៍ហិរញ្ញវត្ថុ**

១.៣.៤ *ស្ថាប័នមួយត្រូវរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលនូវធាតុ ដូចខាងក្រោម÷*

(ក) *របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដែលទទួលស្គាល់ចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់ទាំងអស់ដែលត្រូវបានគ្រប់គ្រងដោយស្ថាប័ន*

(ខ) *គោលនយោបាយគណនេយ្យ និងកំណត់សម្គាល់ពន្យល់ និង*

(គ) *ពេលវេលាដែលស្ថាប័នធ្វើការផ្សព្វផ្សាយជាសាធារណៈនូវផែនការថវិកាអនុម័តរួច; ការប្រៀបធៀបផែនការថវិកា និងចំនួនជាក់ស្តែងជារបាយការណ៍ហិរញ្ញវត្ថុបន្ថែមដាច់ដោយឡែក ឬជាតារាងជួរឈរផែនការថវិកាមួយនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដោយអនុលោមទៅតាមកថាខណ្ឌ ១.៧.៨ នៃស្តង់ដានេះ។*

១.៣.៥ *នៅពេលដែលស្ថាប័នមួយជ្រើសរើសក្នុងការលាតត្រដាងពីព័ត៌មានដែលបានរៀបចំ ផ្អែកលើមូលដ្ឋានផ្សេងពីមូលដ្ឋានគណនេយ្យសាច់ប្រាក់ដូចបានផ្តល់និយមន័យនៅក្នុងស្តង់ដានេះ ឬត្រូវបានតម្រូវដោយកថាខណ្ឌ ១.៣.៤ (គ) ព័ត៌មានទាំងនេះត្រូវលាតត្រដាងក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។*

១.៣.៦ របាយការណ៍ហិរញ្ញវត្ថុ រួមមានរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ និងរបាយការណ៍ផ្សេងទៀតដែលលាតត្រដាងព័ត៌មានបន្ថែមអំពីចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់ដែលបានគ្រប់គ្រងដោយស្ថាប័ន និងគោលនយោបាយគណនេយ្យ និងកំណត់សម្គាល់។ អនុលោមតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.៤ (ក) ខាងលើ មានតែចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់ដែលបានគ្រប់គ្រងដោយស្ថាប័នរាយការណ៍ប៉ុណ្ណោះដែលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ឬ របាយការណ៍ផ្សេងទៀតដែលអាចត្រូវបានរៀបចំ។ អនុលោមទៅតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.៤ (គ) ខាងលើ របាយការណ៍ហិរញ្ញវត្ថុអាចរួមបញ្ចូលនូវការប្រៀបធៀបផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែងជារបាយការណ៍ហិរញ្ញវត្ថុបន្ថែម។

១.៣.៧ កថាខណ្ឌ ១.៧.១៧ នៃស្តង់ដានេះបានចែងថា ស្ថាប័នមួយអាចដាក់បង្ហាញការប្រៀបធៀបផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែងជាតារាងជួរឈរផែនការថវិកាបន្ថែមនៅក្នុងរបាយការណ៍ចំណូល និងចំណាយសាច់ប្រាក់ តែនៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុនិងផែនការថវិកាត្រូវបានរៀបចំឡើង ផ្អែកលើមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបានប៉ុណ្ណោះ។ នៅពេលដែលផែនការថវិកានិងរបាយការណ៍ហិរញ្ញវត្ថុមិនត្រូវបានរៀបចំឡើងផ្អែកលើមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបានទេ នោះរបាយការណ៍ប្រៀបធៀបដាច់ដោយឡែកមួយនៃផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែង ត្រូវបានដាក់បង្ហាញ។

១.៣.៨ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលនូវការពិពណ៌នាបែបនិទាន ឬតារាងលម្អិត ឬការវិភាគអំពីចំនួនទឹកប្រាក់ដែលបានបង្ហាញនៅលើផ្ទៃមុខនៃរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានបន្ថែម។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលនូវព័ត៌មានដែលបានតម្រូវ និងព័ត៌មានលើកទឹកចិត្ត ដែលត្រូវលាតត្រដាងដោយស្តង់ដានេះ ហើយអាចរួមបញ្ចូលនូវការលាតត្រដាងផ្សេងទៀតដែលចាត់ទុកថាចាំបាច់ ដើម្បីសម្រេចបាននូវការដាក់បង្ហាញដ៏ត្រឹមត្រូវមួយ និងធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពផងដែរ។

១.៣.៩ ស្តង់ដានេះមិនបានរារាំងស្ថាប័នមិនឱ្យធ្វើការរួមបញ្ចូលនូវរបាយការណ៍ផ្សេងៗបន្ថែមពីលើរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ដូចបានបញ្ជាក់ក្នុងកថាខណ្ឌ ១.៣.៤ ខាងលើ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅនោះទេ។ ជាលទ្ធផល របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ ក៏អាចរួមបញ្ចូលនូវរបាយការណ៍បន្ថែមដែល÷

(ក) រាយការណ៍អំពីចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់សម្រាប់ខ្ទង់មូលនិធិធំៗដូចជា, មូលនិធិប្រាក់ចំណូលរួម

(ខ) ផ្តល់ព័ត៌មានបន្ថែមអំពីប្រភព និងការប្រើប្រាស់កម្ចី និងចរិកលក្ខណៈ និងប្រភេទនៃចំណាយសាច់ប្រាក់ ឬ

(គ) ផ្តល់ការប្រៀបធៀបចំនួនទឹកប្រាក់ជាក់ស្តែង និងចំនួនទឹកប្រាក់ផែនការថវិកា។

អនុលោមតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.៥ ខាងលើ របាយការណ៍បន្ថែមណាមួយនឹងរាយការណ៍តែអំពីចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់ដែលគ្រប់គ្រងដោយស្ថាប័នតែប៉ុណ្ណោះ។

១.៣.១០ ស្ថាប័នដែលរាយការណ៍ដោយប្រើមូលដ្ឋានគណនេយ្យសាច់ប្រាក់ ជារឿយៗតែងតែប្រមូលព័ត៌មានអំពីគណនីដែលមិនត្រូវបានទទួលស្គាល់តាមគណនេយ្យសាច់ប្រាក់។ ឧទាហរណ៍អំពីប្រភេទព័ត៌មានដែលអាចប្រមូលបាន រួមមានព័ត៌មានលម្អិតអំពី÷

(ក) ប្រាក់ដែលត្រូវទទួល, ប្រាក់ដែលត្រូវសង, កម្ចី, និងបំណុលដទៃទៀត, ទ្រព្យសកម្មមិនមែនសាច់ប្រាក់ និងចំណូល និងចំណាយបង្គរ

(ខ) កាតព្វកិច្ច និងបំណុលយថាហេតុ

(គ) សូចនាករនៃការអនុវត្ត និងការសម្រេចបាននូវគោលបំណងនៃការផ្តល់សេវា។

១.៣.១១ ស្ថាប័នដែលបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ ដោយអនុលោមតាមស្តង់ដានេះ ត្រូវលាតត្រដាងព័ត៌មានទាំងនេះនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលព័ត៌មាននោះអាចមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់។ នៅពេលការលាតត្រដាងទាំងនេះត្រូវបានធ្វើឡើង ការលាតត្រដាងគួរត្រូវបានពិពណ៌នាយ៉ាងច្បាស់លាស់និងងាយស្រួលយល់។ ប្រសិនបើមិនត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ នោះការប្រៀបធៀបជាមួយផែនការថវិកាក៏អាចធ្វើការ

រួមបញ្ចូលនៅក្នុងកំណត់សម្គាល់បានផងដែរ។ ផ្នែកទី ២ នៃស្តង់ដានេះលើកទឹកចិត្តឱ្យមានការរួមបញ្ចូលនូវព័ត៌មានអំពីទ្រព្យសកម្មមិនមែនសាច់ប្រាក់ និងបំណុល និងការប្រៀបធៀបជាមួយផែនការថវិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ។

**ព័ត៌មានដែលត្រូវដាក់បង្ហាញនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់**

១.៣.១២ *របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ត្រូវដាក់បង្ហាញចំនួនដូចខាងក្រោម សម្រាប់ការិយបរិច្ឆេទរាយការណ៍÷*

(ក) *ចំណូលសាច់ប្រាក់សរុបរបស់ស្ថាប័ន ដែលបង្ហាញដាច់ដោយឡែកអំពីចំណាត់ថ្នាក់រងនៃចំណូលសាច់ប្រាក់សរុប ដោយប្រើមូលដ្ឋានចំណាត់ថ្នាក់សមស្របមួយចំពោះប្រតិបត្តិការរបស់ស្ថាប័ន*

(ខ) *ចំណាយសាច់ប្រាក់សរុបរបស់ស្ថាប័នដែលបង្ហាញដាច់ដោយឡែកអំពីចំណាត់ថ្នាក់រងនៃចំណាយសាច់ប្រាក់សរុប ដោយប្រើមូលដ្ឋានចំណាត់ថ្នាក់សមស្របមួយចំពោះប្រតិបត្តិការរបស់ស្ថាប័ន*

(គ) *សមតុល្យសាច់ប្រាក់ដើមគ្រានិងចុងគ្រារបស់ស្ថាប័ន។*

១.៣.១៣ *ចំណូលសាច់ប្រាក់សរុប និងចំណាយសាច់ប្រាក់សរុប និងចំណូលសាច់ប្រាក់និងចំណាយសាច់ប្រាក់សម្រាប់ចំណាត់ថ្នាក់រងនីមួយៗនៃចំណូលនិងចំណាយសាច់ប្រាក់ ត្រូវរាយការណ៍លើមូលដ្ឋានដុល លើកលែងតែចំណូលនិងចំណាយសាច់ប្រាក់អាចត្រូវបានរាយការណ៍លើមូលដ្ឋានសុទ្ធ នៅពេល÷*

(ក) *ចំណូលនិងចំណាយសាច់ប្រាក់កើតឡើងពីប្រតិបត្តិការដែលស្ថាប័នគ្រប់គ្រងជំនួសឱ្យភាគីដទៃទៀត ហើយដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ឬ*

(ខ) *ចំណូលនិងចំណាយសាច់ប្រាក់គឺសម្រាប់គណនីដែលផលរបរមានភាពរហ័ស, ទឹកប្រាក់មានចំនួនច្រើន និងឥណប្រតិទានមានរយៈពេលខ្លី។*

១.៣.១៤ *បន្ទាត់គណនី, ចំណងជើង និងសរុបរង ត្រូវដាក់បង្ហាញនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ នៅពេលដែលការដាក់បង្ហាញបែបនេះមានភាពចាំបាច់ដើម្បីដាក់បង្ហាញដោយត្រឹមត្រូវអំពីចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់របស់ស្ថាប័ន។*

១.៣.១៥ ស្តង់ដានេះ តម្រូវឱ្យស្ថាប័នទាំងអស់ដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ដែលលាតត្រដាងអំពីសមតុល្យសាច់ប្រាក់ដើមគ្រានិងចុងគ្រារបស់ស្ថាប័ន, ចំណូលសាច់ប្រាក់សរុប និងចំណាយសាច់ប្រាក់សរុបនៅក្នុងការិយបរិច្ឆេទរាយការណ៍ ក៏ដូចជាចំណាត់ថ្នាក់រងសំខាន់ៗផងដែរ។ ការធ្វើបែបនេះនឹងធានាថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវព័ត៌មានលម្អិតអំពីសមតុល្យសាច់ប្រាក់របស់ស្ថាប័ននិងការផ្លាស់ប្តូរនៅក្នុងការិយបរិច្ឆេទនោះនៅក្នុងទម្រង់មួយដែលអាចទទួលយកបាន និងងាយយល់ចំពោះអ្នកប្រើប្រាស់។

១.៣.១៦ ការលាតត្រដាងព័ត៌មានអំពីចំណុចទាំងនេះដូចជា សមតុល្យសាច់ប្រាក់របស់ស្ថាប័ន មិនថាសាច់ប្រាក់ត្រូវបានបង្កើតឡើងពីពន្ធ, ការពិន័យ, កម្រៃ, និង/ឬ កម្ចី និងមិនថាសាច់ប្រាក់ត្រូវបានបន្ថែមដើម្បីបំពេញតាមចំណាយប្រតិបត្តិការសម្រាប់ការទទួលបានទ្រព្យសកម្មមូលធន ឬសម្រាប់ការដោះបំណុល នឹងធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាពនៃការរាយការណ៍ហិរញ្ញវត្ថុ។ ការលាតត្រដាងបែបនេះក៏នឹងជួយសម្រួលដល់ការវិភាគ និងការវាយតម្លៃលើធនធានសាច់ប្រាក់បច្ចុប្បន្ន ក៏ដូចជាប្រភពដែលអាចទៅរួច និងនិរន្តរភាពនៃលំហូរចូលនៃសាច់ប្រាក់នាពេលអនាគតរបស់ស្ថាប័នផងដែរ។

**ចំណាត់ថ្នាក់**

១.៣.១៧ ចំណាត់ថ្នាក់រង (ឬថ្នាក់) នៃចំណូល និងចំណាយសាច់ប្រាក់សរុបដែលនឹងត្រូវបានលាតត្រដាងដោយអនុលោមតាមកថាខណ្ឌ ១.៣.១២ និង ១.៣.១៤ គឺពាក់ព័ន្ធនឹងការវិនិច្ឆ័យបែបវិជ្ជាជីវៈ។ ការវិនិច្ឆ័យនោះនឹងត្រូវបានអនុវត្តនៅក្នុងបរិបទនៃគោលបំណងបុគ្គលិកលក្ខណៈបែបគុណភាពនៃការរាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់។ ឧបសម្ព័ន្ធ ៤ នៃស្តង់ដានេះបានសង្ខេបអំពីបុគ្គលិកលក្ខណៈបែបគុណភាពនៃព័ត៌មានដែលត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោល-បំណងទូទៅ។ ជាឧទាហរណ៍ ចំណូលសាច់ប្រាក់សរុបអាចត្រូវបានចាត់ថ្នាក់ ដើម្បីធ្វើការកំណត់ដាច់ដោយឡែកអំពីចំណូលសាច់ប្រាក់ពីពន្ធ ឬការវិភាជន៍, អំណោយនិងការបរិច្ចាគ, កម្ចី, ចំណូលពីការលក់អចលនទ្រព្យ, រោងចក្រ និងបរិក្ខារ និងសកម្មភាពពាណិជ្ជកម្ម និងការផ្តល់សេវាបន្ត។ ចំណាយសាច់ប្រាក់សរុបអាចត្រូវបានចាត់ថ្នាក់ ដើម្បីកំណត់ដាច់ដោយឡែកអំពីចំណាយសាច់ប្រាក់ទាក់ទងនឹងសកម្មភាពផ្តល់សេវាបន្ត រួមបញ្ចូលទាំងការផ្ទេរទៅកាន់អង្គភាពនានា ឬរដ្ឋាភិបាល ឬស្ថាប័នដទៃ, កម្មវិធីកាត់បន្ថយបំណុល, ការទិញអចលនទ្រព្យ, រោងចក្រ និងបរិក្ខារ និងសកម្មភាពពាណិជ្ជកម្មណាមួយ។ ការដាក់បង្ហាញជាជម្រើសបន្ថែមក៏អាចធ្វើបានផងដែរ ឧទាហរណ៍ ចំណូលសាច់ប្រាក់សរុបអាចត្រូវបានចាត់ថ្នាក់ដោយយោងទៅតាមប្រភពរបស់ពួកគេ ហើយចំណាយសាច់ប្រាក់អាចត្រូវបានចាត់ថ្នាក់រងដោយយោងទៅតាមចរិកលក្ខណៈនៃចំណាយ ឬ តួនាទី ឬ កម្មវិធីនៅក្នុងស្ថាប័ន តាមភាពសមស្រប។

១.៣.១៨ ផ្នែកទី ២ នៃស្តង់ដានេះលើកទឹកចិត្តឱ្យមានការលាតត្រដាងព័ត៌មានជាក់លាក់អំពីជំនួយខាងក្រៅ និងជំនួយផ្សេងទៀតដែលបានទទួលនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ហើយសមតុល្យនៃជំនួយខាងក្រៅមិនផ្លូវការ និងជំនួយផ្សេងទៀតដែលស្ថាប័នមាន នាកាលបរិច្ឆេទរាយការណ៍។ សម្រាប់ស្ថាប័នរាយការណ៍សាធារណៈជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍ ការធ្វើចំណាត់ថ្នាក់ចំណូល និងចំណាយសាច់ប្រាក់ដើម្បីកំណត់ពីចំនួនជំនួយខាងក្រៅ និងជំនួយផ្សេងទៀតដែលបានទទួលជាសាច់ប្រាក់ និងការប្រើប្រាស់ជំនួយនោះ គឺហាក់ដូចជាមានការពាក់ព័ន្ធនឹងគោលបំណងគណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្ត។

**បន្ទាត់គណនី, ចំណងជើង និងសរុបរង**

១.៣.១៩ កត្តាដែលត្រូវពិចារណាក្នុងការកំណត់ថាតើ បន្ទាត់គណនី, ចំណងជើង និងសរុបរងមួយណាគួរត្រូវបានដាក់បង្ហាញនៅក្នុងចំណាត់ថ្នាក់រងនីមួយៗ ដោយអនុលោមទៅតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.១៤ ខាងលើ រួមមាន៖ លក្ខខណ្ឌចាំបាច់នៃផ្នែកដទៃទៀតនៃស្តង់ដានេះ, ការវាយតម្លៃលើភាពជាសារវន្តដែលអាចទៅរួចនៃការលាតត្រដាងចំពោះអ្នកប្រើប្រាស់, និងកម្រិតដែលការពន្យល់ និងការលាតត្រដាងចាំបាច់ត្រូវបានធ្វើឡើងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។ ផ្នែកទី ២ នៃស្តង់ដានេះបានកំណត់ពីការលាតត្រដាងអំពីថ្នាក់សំខាន់បន្ថែមនៃលំហូរសាច់ប្រាក់ ដែលស្ថាប័នមួយត្រូវបានលើកទឹកចិត្តឱ្យធ្វើនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ឬនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុផ្ទាល់តែម្តង។ វាអាចទៅរួចដែលថា នៅក្នុងករណីជាច្រើន ប៉ុន្តែមិនមែនគ្រប់ករណីនោះទេ ការលាតត្រដាងទាំងនេះនឹងបំពេញតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.១២ ខាងលើ។

**ការរាយការណ៍លើមូលដ្ឋានសុទ្ធ**

១.៣.២០ ស្តង់ដានេះតម្រូវឱ្យមានការរាយការណ៍ចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់តាមមូលដ្ឋានដុល លើកលែងតែនៅក្នុងស្ថានភាពដូចបានកំណត់ដោយកថាខណ្ឌ ១.៣.១៣ ខាងលើ។ កថាខណ្ឌ ១.៣.២១ និង ១.៣.២៤ ខាងក្រោម នឹងពន្យល់លម្អិតបន្ថែមអំពីស្ថានភាពទាំងនោះ ដែលការរាយការណ៍តាមមូលដ្ឋានសុទ្ធ អាចត្រូវបានផ្តល់ហេតុផលនៅក្នុងស្ថានភាពនោះ។

១.៣.២១ រដ្ឋាភិបាល និងនាយកដ្ឋានរបស់រដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀតអាចគ្រប់គ្រងប្រតិបត្តិការ ហើយបើមិនដូច្នេះទេ នឹងដើរតួនាទីជាភ្នាក់ងារជំនួសឱ្យស្ថាប័នដទៃ។ ប្រតិបត្តិការភ្នាក់ងារ និងប្រតិបត្តិការដែលត្រូវបានគ្រប់គ្រងទាំងនេះ អាចរួមបញ្ចូលនូវការប្រមូលចំណូលជំនួសឱ្យស្ថាប័នដទៃ, ការផ្ទេរមូលនិធិទៅកាន់អត្ថគាហកៈដែលមានសិទ្ធិទទួល ឬការរក្សាសុវត្ថិភាពប្រាក់ជំនួសឱ្យអង្គភាពនានា។ ឧទាហរណ៍នៃសកម្មភាពទាំងនេះ អាចរួមបញ្ចូលនូវ៖

(ក) ការប្រមូលពន្ធដោយរដ្ឋាភិបាលកម្រិតមួយ សម្រាប់ផ្តល់ឱ្យរដ្ឋាភិបាលកម្រិតមួយផ្សេងទៀត ដោយមិនរាប់បញ្ចូលនូវពន្ធដែលបានប្រមូលដោយរដ្ឋាភិបាល សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនជាផ្នែកមួយនៃកិច្ចសម្រុះសម្រួលចែករំលែកពន្ធឡើយ

(ខ) ការទទួលយក និងការសងប្រាក់បញ្ញើគ្មានកាលកំណត់របស់គ្រឹះស្ថានហិរញ្ញវត្ថុ

(គ) មូលនិធិដែលត្រូវបានរក្សាទុកសម្រាប់អតិថិជនដោយស្ថាប័នវិនិយោគ ឬស្ថាប័នបរធន

(ឃ) ប្រាក់ឈ្នួលដែលបានប្រមូលជំនួស ឬទូទាត់ទៅឱ្យម្ចាស់អចលនទ្រព្យ

(ង) ការផ្ទេររបស់នាយកដ្ឋានរដ្ឋាភិបាលមួយទៅកាន់ភាគីទីបីឱ្យស្របតាមច្បាប់ ឬអាជ្ញាធររដ្ឋាភិបាលផ្សេងទៀត និង

(ច) មូលនិធិដែលបានគ្រប់គ្រងដោយស្ថាប័នកណ្តាលមួយក្រោម“គណនីទោល” សម្រាប់ការគ្រប់គ្រងចំណាយរបស់រដ្ឋាភិបាល (ដូចមានយោងនៅក្នុងកថាខណ្ឌ ១.២.៨)។

១.៣.២២ នៅក្នុងករណីជាច្រើន សាច់ប្រាក់ដែលស្ថាប័នមួយទទួល ពាក់ព័ន្ធនឹងប្រតិបត្តិការដែលស្ថាប័នបានគ្រប់គ្រងជាភ្នាក់ងារមួយសម្រាប់ស្ថាប័នដទៃ នឹងត្រូវបានដាក់បញ្ញើក្នុងគណនីបរធនសម្រាប់ ឬដាក់បញ្ញើដោយផ្ទាល់នៅក្នុងគណនីធនាគាររបស់គម្បជនចុងក្រោយ ដែលនឹងត្រូវទទួលបានសាច់ប្រាក់។ នៅក្នុងករណីទាំងនេះ ស្ថាប័ននឹងមិនគ្រប់គ្រងសាច់ប្រាក់ដែលខ្លួនបានទទួល ពាក់ព័ន្ធនឹងប្រតិបត្តិការដែលខ្លួនគ្រប់គ្រង ហើយលំហូរសាច់ប្រាក់ទាំងនេះនឹងមិនបង្កើតជាផ្នែកមួយនៃចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់របស់ស្ថាប័នឡើយ។ ទោះជាយ៉ាងណា នៅក្នុងករណីផ្សេងទៀត ប្រាក់ដែលបានទទួលនឹងត្រូវបានដាក់បញ្ញើនៅក្នុងគណនីធនាគារដែលបានគ្រប់គ្រងដោយស្ថាប័នដែលដើរតួជាភ្នាក់ងារមួយ ហើយចំណូលនិងការផ្ទេរសាច់ប្រាក់នោះនឹងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់របស់ស្ថាប័ន។

១.៣.២៣ នៅក្នុងករណីមួយចំនួន ចំនួនទឹកប្រាក់នៃលំហូរសាច់ប្រាក់ដែលកើតឡើងពីប្រតិបត្តិការដែលបានគ្រប់គ្រង ដែល "បានឆ្លងកាត់"គណនីធនាគាររបស់ស្ថាប័នរាយការណ៍ អាចមានទំហំធំ បើធៀបនឹងប្រតិបត្តិការផ្ទាល់របស់ស្ថាប័ន ហើយការត្រួតពិនិត្យអាចកើតឡើងក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ មុនពេលចំនួនទឹកប្រាក់ត្រូវបានផ្ទេរទៅកាន់គម្បជនចុងក្រោយ។ នេះក៏អាចជាការពិតសម្រាប់លំហូរសាច់ប្រាក់ដទៃទៀត រួមបញ្ចូលទាំង ឧទាហរណ៍ បុរេប្រទានដែលបានធ្វើឡើងសម្រាប់ និងការសងលើ៖

(ក) ការទិញ និងការលក់ការវិនិយោគ និង

(ខ) កម្ចីរយៈពេលខ្លីផ្សេងទៀត ឧទាហរណ៍ កម្ចីរយៈពេលខ្លីទាំងឡាយណាដែលមានកាលិយបរិច្ឆេទឥណប្រតិទានចំនួន បីខែ ឬតិចជាងនេះ។

១.៣.២៤ ការទទួលស្គាល់ប្រតិបត្តិការទាំងនេះលើមូលដ្ឋានដុល អាចប៉ះពាល់ដល់លទ្ធភាពរបស់របាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាលមួយចំនួនក្នុងការផ្តល់ព័ត៌មានអំពីចំណូលសាច់ប្រាក់និងចំណាយសាច់ប្រាក់ដែលកើតឡើងពីសកម្មភាពផ្ទាល់របស់ស្ថាប័ន។ ដូច្នេះ ស្តង់ដានេះបានអនុញ្ញាតឱ្យចំណូលសាច់ប្រាក់និងចំណាយសាច់ប្រាក់ ត្រូវបានកាត់កង និងត្រូវបានរាយការណ៍លើមូលដ្ឋានសុទ្ធនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ នៅក្នុងស្ថានភាពដូចបានកំណត់នៅក្នុងកថាខណ្ឌ ១.៣.១៣ ខាងលើ។

**គោលនយោបាយគណនេយ្យ និងកំណត់សម្គាល់ពន្យល់**

**រចនាសម្ព័ន្ធនៃកំណត់សម្គាល់**

១.៣.២៥ *កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នមួយត្រូវ៖*

(ក) *ដាក់បង្ហាញព័ត៌មានអំពីមូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងគោលនយោបាយគណនេយ្យជាក់លាក់ដែលត្រូវបានជ្រើសរើស និងអនុវត្តសម្រាប់ប្រតិបត្តិការជាសារវន្ត និងព្រឹត្តិការណ៍ផ្សេងទៀត និង*

(ខ) *ផ្តល់ព័ត៌មានបន្ថែមដែលមិនបានដាក់បង្ហាញនៅលើរបាយការណ៍ហិរញ្ញវត្ថុ ប៉ុន្តែចាំបាច់សម្រាប់ការដាក់បង្ហាញដ៏ត្រឹមត្រូវអំពីចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់របស់ស្ថាប័ន។*

១.៣.២៦ *កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុត្រូវដាក់បង្ហាញជាលក្ខណៈប្រព័ន្ធ។ គណនីនីមួយៗនៅលើផ្ទៃមុខនៃរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់និងរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀត ត្រូវផ្ទៀងផ្ទាត់ជាមួយនឹងព័ត៌មានពាក់ព័ន្ធផ្សេងៗនៅក្នុងកំណត់សម្គាល់។*

**ការជ្រើសរើស និងការលាតត្រដាងអំពីគោលនយោបាយគណនេយ្យ**

១.៣.២៧ *របាយការណ៍ហិរញ្ញវត្ថុត្រូវលាតត្រដាងព័ត៌មានដែល÷*

(ក) *ងាយយល់*

(ខ) *ពាក់ព័ន្ធនឹងតម្រូវការនៃការធ្វើសេចក្តីសម្រេចចិត្ត និងគណនេយ្យភាពរបស់អ្នកប្រើប្រាស់*

(គ) *ជាការពិពណ៌នាដ៏ស្មោះត្រង់អំពីចំណូលសាច់ប្រាក់, ចំណាយសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់របស់ស្ថាប័ន និងព័ត៌មានផ្សេងទៀតដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពីព្រោះការពិពណ៌នានោះ÷*

(១) *ពេញលេញ*

(២) *អព្យាក្រឹត្យ និង*

(៣) *មិនមានកំហុសឆ្គងជាសារវន្ត*

(ឃ) *អាចប្រៀបធៀបគ្នាបាន*

(ង) *ទាន់ពេលវេលា*

(ច) *អាចបញ្ជាក់បាន។*

*ការដាក់កម្រិតលើព័ត៌មានដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុគឺថា ព័ត៌មាននោះមានភាពជាសារវន្ត, បំពេញតាមការវាយតម្លៃលើចំណាយនិងអត្ថប្រយោជន៍ និងសម្រេចបាននូវតុល្យភាពសមស្របមួយរវាងបុគ្គលិកលក្ខណៈបែបគុណភាព ដូចបានកំណត់ពីចំណុច (ក) ទៅ (ច) ខាងលើ។*

១.៣.២៨ គុណភាពព័ត៌មានដែលបានផ្តល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ បានកំណត់ពីសារៈប្រយោជន៍នៃរបាយ-ការណ៍ទាំងនោះចំពោះអ្នកប្រើប្រាស់។ កថាខណ្ឌ ១.៣.២៧ កំណត់ពីបុគ្គលិកលក្ខណៈបែបគុណភាព និងការដាក់កម្រិតលើព័ត៌មានដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ វាតម្រូវឱ្យមានការ

អភិវឌ្ឍគោលនយោបាយគណនេយ្យ ដើម្បីធានាថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវព័ត៌មានដែលអាចបំពេញតាមបុគ្គលិកលក្ខណៈបែបគុណភាពដូចបានកំណត់ក្នុងកថាខណ្ឌ ១.៣.២៧(ក) ទៅ ១.៣.២៧(ថ) និងអាចបំពេញតាមការដាក់កម្រិតលើព័ត៌មានដែលបានរួមបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ឧបសម្ព័ន្ធ ៤ នៃស្តង់ដានេះសង្ខេបអំពីបុគ្គលិកលក្ខណៈបែបគុណភាព និងការដាក់កម្រិតលើព័ត៌មានដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ។ ការរក្សាទុកនូវកំណត់ត្រាគណនេយ្យដែលត្រឹមត្រូវនិងពេញលេញនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ការបង្កើតរបាយការណ៍ហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា។

១.៣.២៩ *ផ្នែកគោលនយោបាយគណនេយ្យដែលមាននៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ត្រូវពិពណ៌នាអំពីគោលនយោបាយគណនេយ្យជាក់លាក់នីមួយៗដែលចាំបាច់សម្រាប់ការយល់ដឹងដ៏ត្រឹមត្រូវមួយ អំពីរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងវិសាលភាពដែលស្ថាប័នបានអនុវត្តតាមបទប្បញ្ញត្តិអន្តរកាលណាមួយនៅក្នុងស្តង់ដានេះ។*

១.៣.៣០ *ប្រព្រឹត្តិកម្មគណនេយ្យមិនសមស្រប គឺមិនត្រូវបានកែតម្រូវដោយការលាតត្រដាងអំពីគោលនយោបាយគណនេយ្យដែលបានប្រើ ឬដោយកំណត់សម្គាល់ ឬការពន្យល់នោះទេ។*

១.៣.៣១ ក្នុងការសម្រេចថាតើគោលនយោបាយគណនេយ្យជាក់លាក់មួយគួរត្រូវបានលាតត្រដាង ឬក៏យ៉ាងណានោះ ថ្នាក់ដឹកនាំត្រូវពិចារណាថាតើការលាតត្រដាងអាចជួយឱ្យអ្នកប្រើប្រាស់យល់ដឹងអំពីមធ្យោបាយដែលប្រតិបត្តិការនិងព្រឹត្តិការណ៍ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងចំណូលសាច់ប្រាក់, ចំណាយ និងសមតុល្យដែលបានរាយការណ៍ដែរឬទេ។ គោលនយោបាយគណនេយ្យមួយអាចសំខាន់ បើទោះបីជាចំនួនទឹកប្រាក់ដែលបានបង្ហាញសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ននិងការិយបរិច្ឆេទមុន មិនមានភាពជាសារវន្តក៏ដោយ។ កថាខណ្ឌ ១.៣.៤ នៃស្តង់ដានេះបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅរួមបញ្ចូលទាំងគោលនយោបាយគណនេយ្យនិងកំណត់សម្គាល់ពន្យល់។ ជាលទ្ធផល លក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.២៩ ខាងលើ ក៏ត្រូវអនុវត្តចំពោះកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុផងដែរ។

១.៣.៣២ *នៅពេលស្ថាប័នមួយជ្រើសរើសដើម្បីរួមបញ្ចូលនូវការលាតត្រដាងណាមួយ ដែលបានលើកទឹកចិត្តក្នុងផ្នែកទី២ នៃស្តង់ដានេះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ការលាតត្រដាងទាំងនោះត្រូវអនុលោមតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៣.២៧ ខាងលើ។*

១.៣.៣៣ ផ្នែកទី ២ នៃស្តង់ដានេះលើកទឹកចិត្តឱ្យមានការលាតត្រដាងអំពីព័ត៌មានបន្ថែមនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។ នៅពេលការលាតត្រដាងទាំងនេះត្រូវបានធ្វើឡើង ការលាតត្រដាងទាំងនោះចាំបាច់ត្រូវងាយយល់ និងអាចបំពេញបានតាមបុគ្គលិកលក្ខណៈបែបគុណភាពផ្សេងទៀតនៃព័ត៌មានហិរញ្ញវត្ថុ។

## ១.៤ ការពិចារណានានា

**ការិយបរិច្ឆេទរាយការណ៍**

១.៤.១ *របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ ត្រូវដាក់បង្ហាញយ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ។ នៅក្នុងស្ថានភាពលើកលែង នៅពេលដែលកាលបរិច្ឆេទរាយការណ៍របស់ស្ថាប័នផ្លាស់ប្តូរ ហើយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានដាក់បង្ហាញសម្រាប់ការិយបរិច្ឆេទមួយដែលមានរយៈពេលវែងជាង ឬ តិចជាងមួយឆ្នាំ ស្ថាប័នត្រូវលាតត្រដាងបន្ថែមពីលើការិយបរិច្ឆេទដែលបានគ្របដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុ អំពី÷*

(ក) *ហេតុផលដែលស្ថាប័នជ្រើសរើសយកការិយបរិច្ឆេទមួយ ដែលមានរយៈពេលខុសពីមួយឆ្នាំដែលខ្លួនកំពុងប្រើប្រាស់ និង*

(ខ) *ការពិតដែលចំនួនទឹកប្រាក់ប្រៀបធៀប ប្រហែលមិនអាចប្រៀបធៀបគ្នាបាន។*

១.៤.២ កាលបរិច្ឆេទរាយការណ៍ គឺជាកាលបរិច្ឆេទនៃថ្ងៃចុងក្រោយនៃការិយបរិច្ឆេទរាយការណ៍ដែលរបាយការណ៍ហិរញ្ញវត្ថុជាប់ពាក់ព័ន្ធ។ នៅក្នុងស្ថានភាពលើកលែង ស្ថាប័នមួយអាចត្រូវបានតម្រូវឱ្យ ឬសម្រេចចិត្តក្នុងការផ្លាស់ប្តូរកាលបរិច្ឆេទរាយការណ៍របស់ខ្លួន ឧទាហរណ៍ ដើម្បីធ្វើឱ្យវដ្តនៃការរាយការណ៍មានលក្ខណៈកាន់តែស្របគ្នាជាមួយនឹងវដ្តនៃការរៀបចំផែនការថវិកា។ នៅពេលករណីនេះកើតឡើង វាមានសារៈសំខាន់ណាស់ដែលហេតុផលសម្រាប់ការផ្លាស់ប្តូរកាលបរិច្ឆេទរាយការណ៍ ត្រូវបានលាតត្រដាង ហើយដែលអ្នកប្រើប្រាស់បានដឹងថា ចំនួនទឹកប្រាក់ដែលបានបង្ហាញសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន និងចំនួនទឹកប្រាក់ប្រៀបធៀប មិនអាចប្រៀបធៀបគ្នាបាន។

១.៤.៣ ជាធម្មតា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងប្រកបដោយសង្គតិភាពដែលគ្របដណ្តប់លើការិយបរិច្ឆេទដែលមានរយៈពេលមួយឆ្នាំ។ ទោះបីជាយ៉ាងណា ស្ថាប័នមួយចំនួនពេញចិត្តរាយការណ៍ ឧទាហរណ៍ សម្រាប់ការិយបរិច្ឆេទដែលមានរយៈពេល ៥២ សប្តាហ៍ ក្រោមហេតុផលនៃការអនុវត្តជាក់ស្តែង។ ស្តង់ដានេះមិនបានរារាំងដល់ការអនុវត្តបែបនេះឡើយ ពីព្រោះរបាយការណ៍ហិរញ្ញវត្ថុដែលកើតចេញពីការអនុវត្តបែបនេះ ហាក់ដូចជាមិនមានភាពខុសគ្នាជាសារវន្តណាមួយពីរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានដាក់បង្ហាញសម្រាប់រយៈពេលមួយឆ្នាំនោះទេ។

**ភាពទាន់ពេលវេលា**

១.៤.៤ សារៈប្រយោជន៍នៃរបាយការណ៍ហិរញ្ញវត្ថុត្រូវបានថយចុះ ប្រសិនបើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ មិនត្រូវបានផ្តល់ដល់អ្នកប្រើប្រាស់នៅក្នុងរយៈពេលសមស្របណាមួយ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។ ស្ថាប័នមួយគួរតែបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ បើទោះបីជាមានការលើកទឹកចិត្តឱ្យធ្វើការបោះផ្សាយក្នុងរយៈពេលមិនឱ្យលើសពីបីខែ ក៏ដោយ។ កត្តាមួយចំនួនដូចជា ភាពស្មុគស្មាញនៃប្រតិបត្តិការរបស់ស្ថាប័នមួយមិនមែនជាហេតុផល

គ្រប់គ្រាន់ដែលធ្វើឱ្យបរាជ័យក្នុងការរាយការណ៍ឱ្យបានទាន់ពេលវេលានោះទេ។ កាលកំណត់ជាក់លាក់បន្ថែម គឺត្រូវបានដោះស្រាយដោយច្បាប់ និងបទប្បញ្ញត្តិផ្សេងៗនៅក្នុងយុត្តាធិការជាច្រើន។

**កាលបរិច្ឆេទអនុញ្ញាតចេញផ្សាយ**

១.៤.៥ *ស្ថាប័នមួយ ត្រូវលាតត្រដាងអំពីកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានផ្តល់សិទ្ធិសម្រាប់ការបោះផ្សាយ ហើយថាតើនរណាជាអ្នកផ្តល់សិទ្ធិនោះ។ ប្រសិនបើស្ថាប័នដទៃមានអំណាចក្នុងការកែប្រែរបាយការណ៍ហិរញ្ញវត្ថុបន្ទាប់ពីបានបោះផ្សាយរួច ស្ថាប័នត្រូវលាតត្រដាងអំពីការពិតនោះ។*

១.៤.៦ កាលបរិច្ឆេទអនុញ្ញាតចេញផ្សាយ គឺជាកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុបានទទួលការអនុម័តពីបុគ្គល ឬស្ថាប័នមានសមត្ថកិច្ច ដើម្បីបញ្ចប់របាយការណ៍ទាំងនោះសម្រាប់ការបោះផ្សាយ។ វាមានសារៈសំខាន់ណាស់ចំពោះអ្នកប្រើប្រាស់ដើម្បីដឹងថា តើនៅពេលណាដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានផ្តល់សិទ្ធិសម្រាប់ការបោះផ្សាយ ពីព្រោះរបាយការណ៍ហិរញ្ញវត្ថុមិនបានឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនេះទេ។ វាក៏មានសារៈសំខាន់ផងដែរចំពោះអ្នកប្រើប្រាស់ដើម្បីដឹងអំពីស្ថានភាពកម្រផ្សេងៗដែលបុគ្គល ឬស្ថាប័នណាមួយមានអំណាចក្នុងការកែប្រែរបាយការណ៍ហិរញ្ញវត្ថុ បន្ទាប់ពីបានបោះផ្សាយរួច។ ឧទាហរណ៍អំពីបុគ្គល ឬស្ថាប័នដែលអាចមានសិទ្ធិអំណាចក្នុងការកែប្រែរបាយការណ៍ហិរញ្ញវត្ថុបន្ទាប់ពីបានបោះផ្សាយរួច មានដូចជា, រដ្ឋមន្ត្រី, រដ្ឋាភិបាលដែលស្ថាប័នបង្កើតជាផ្នែកមួយនៃរដ្ឋាភិបាលនោះ, សភា, ឬ ស្ថាប័នតំណាងដែលត្រូវបានជ្រើសតាំង។ ប្រសិនបើការផ្លាស់ប្តូរត្រូវបានធ្វើឡើង នោះរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានកែប្រែរួច គឺជាសំណុំរបាយការណ៍ហិរញ្ញវត្ថុថ្មីមួយ។

**ព័ត៌មានអំពីស្ថាប័ន**

១.៤.៧ *ស្ថាប័នមួយត្រូវលាតត្រដាងអំពីចំណុចដូចខាងក្រោម នៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ប្រសិនបើមិនត្រូវបានលាតត្រដាងនៅកន្លែងណាមួយផ្សេង ជាព័ត៌មានដែលត្រូវបានបោះពុម្ពផ្សាយជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ÷*

(ក) *ទីតាំង និងទម្រង់ច្បាប់របស់ស្ថាប័ន និងយុត្តាធិការដែលស្ថាប័នកំពុងធ្វើប្រតិបត្តិការ*

(ខ) *ការពិពណ៌នាអំពីចរិកលក្ខណៈនៃប្រតិបត្តិការ និងសកម្មភាពសំខាន់ៗរបស់ស្ថាប័ន*

(គ) *ឯកសារយោងសម្រាប់ច្បាប់ពាក់ព័ន្ធដែលគ្រប់គ្រងលើប្រតិបត្តិការរបស់ស្ថាប័ន បើមាន និង*

(ឃ) *ស្ថាប័ន ឬ វិស័យសំខាន់ៗរបស់រដ្ឋាភិបាលដែលត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងការផ្លាស់ប្តូរនៅក្នុងស្ថាប័ន ឬវិស័យសំខាន់ៗដែលរួមមាន ស្ថាប័នរាយការណ៍ ហើយត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទមុនៗ។*

១.៤.៨ របាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានរៀបចំឡើងសម្រាប់អង្គភាពតែមួយ ឬស្ថាប័នរដ្ឋបាលដូចជា នាយកដ្ឋានរដ្ឋាភិបាល, ភ្នាក់ងារ ឬកម្មវិធី, សម្រាប់រដ្ឋាភិបាលទាំងមូល, ឬសម្រាប់ក្រុមស្ថាប័ន ឬសកម្មភាពដែលអាចកំណត់បានដូចជា សកម្មភាពទាំងឡាយណាដែលឆ្លុះបញ្ចាំងពីវិស័យថវិកា, វិស័យរដ្ឋាភិបាលទូទៅ

ឬវិស័យផ្សេងទៀតរបស់រដ្ឋាភិបាល។ ការលាតត្រដាងអំពីព័ត៌មាន ដែលបានតម្រូវដោយកថាខណ្ឌ ១.៤.៧ នឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកំណត់ពីចរិកលក្ខណៈនៃប្រតិបត្តិការរបស់ស្ថាប័ន និងទទួលបាននូវការយល់ដឹងអំពីបរិយាកាសច្បាប់ និងបរិយាកាសស្ថាប័នដែលស្ថាប័នកំពុងធ្វើប្រតិបត្តិការ។ វាក៏នឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកំណត់ពីស្ថាប័ន ឬវិស័យសំខាន់ៗដែលបង្កើតបានជាស្ថាប័នរាយការណ៍ និងការផ្លាស់ប្តូរនានា ចាប់តាំងពីកាលបរិច្ឆេទរាយការណ៍មុន។ វាពិតជាចាំបាច់សម្រាប់គោលបំណងគណនេយ្យភាព ហើយនឹងជួយអ្នកប្រើប្រាស់ក្នុងការយល់ដឹង និងវាយតម្លៃលើរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័ន។

**ការរឹតត្បិតលើសមតុល្យសាច់ប្រាក់ និងការទទួលបានកម្ចី**

១.៤.៩ *ស្ថាប័នមួយត្រូវលាតត្រដាងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ជាមួយនឹងការពន្យល់, នូវចរិកលក្ខណៈ និងចំនួននៃ÷*

(ក) *សមតុល្យសាច់ប្រាក់សំខាន់ៗដែលមិនមានសម្រាប់ឱ្យស្ថាប័នប្រើប្រាស់*

(ខ) *សមតុល្យសាច់ប្រាក់សំខាន់ៗដែលប្រឈមនឹងការរឹតត្បិតខាងក្រៅ និង*

(គ) *ឧបករណ៍កម្ចីដែលមិនទាន់បានប្រើប្រាស់ សម្រាប់សកម្មភាពប្រតិបត្តិការនាពេលអនាគត និងដើម្បីទូទាត់កាតព្វកិច្ចមូលធនដែលបង្ហាញពីការរឹតត្បិតណាមួយលើការប្រើប្រាស់ឧបករណ៍កម្ចីទាំងនេះ។*

១.៤.១០ សមតុល្យសាច់ប្រាក់ដែលបានរក្សាទុកដោយស្ថាប័នមួយ នឹងមិនមានសម្រាប់ការប្រើប្រាស់ដោយស្ថាប័ននោះទេ ឧទាហរណ៍ នៅពេលដែលស្ថាប័នក្រោមការគ្រប់គ្រងធ្វើប្រតិបត្តិការនៅក្នុងប្រទេសមួយដែលការគ្រប់គ្រងអត្រាប្តូរប្រាក់ ឬការរឹតត្បិតផ្លូវច្បាប់ផ្សេងទៀតត្រូវបានអនុវត្ត ហើយសមតុល្យពុំមានសម្រាប់ការប្រើប្រាស់ទូទៅដោយស្ថាប័នគ្រប់គ្រង ឬស្ថាប័នក្រោមការគ្រប់គ្រងផ្សេងទៀតនោះទេ។

១.៤.១១ សមតុល្យសាច់ប្រាក់ដែលបានគ្រប់គ្រងដោយស្ថាប័នមួយ អាចប្រឈមនឹងការរឹតត្បិតដែលដាក់កម្រិតដល់គោលបំណង ឬពេលវេលានៃការប្រើប្រាស់របស់ស្ថាប័ន។ ស្ថានភាពនេះតែងកើតមានឡើងនៅពេលស្ថាប័នទទួលបានអំណោយ ឬការបរិច្ចាគដែលត្រូវប្រើប្រាស់សម្រាប់គោលបំណងជាក់លាក់មួយ។ វាក៏អាចកើតមានឡើងផងដែរនាកាលបរិច្ឆេទរាយការណ៍ នៅពេលស្ថាប័នមួយរក្សាទុកសាច់ប្រាក់ដែលខ្លួនបានប្រមូលសម្រាប់ភាគីដទៃក្នុងនាមជាភ្នាក់ងារមួយ ក្នុងគណនីធនាគាររបស់ខ្លួន ប៉ុន្តែសាច់ប្រាក់នោះមិនទាន់ត្រូវបានផ្ទេរទៅកាន់ភាគីទាំងនោះនៅឡើយ។ ទោះបីជាសមតុល្យទាំងនេះត្រូវបានគ្រប់គ្រងដោយស្ថាប័ន ហើយត្រូវបានរាយការណ៍ជាសមតុល្យសាច់ប្រាក់របស់ស្ថាប័នក៏ដោយ តែការលាតត្រដាងដាច់ដោយឡែកអំពីចំនួនទឹកប្រាក់នៃគណនីទាំងនេះគឺមានសារៈសំខាន់ណាស់ចំពោះអ្នកអាន។

១.៤.១២ ឧបករណ៍កម្ចីដែលមិនទាន់បានប្រើប្រាស់ តំណាងឱ្យប្រភពសាច់ប្រាក់ដ៏មានសក្តានុពលសម្រាប់ស្ថាប័ន។ ការលាតត្រដាងអំពីចំនួនទឹកប្រាក់នៃឧបករណ៍កម្ចីទាំងនេះទៅតាមប្រភេទសំខាន់ៗ នឹងអនុញ្ញាតឱ្យ

អ្នកអានអាចវាយតម្លៃពីភាពដែលអាចយកមកប្រើបាននៃសាច់ប្រាក់ទាំងនេះ និងកម្រិតដែលស្ថាប័នអាចប្រើសាច់ប្រាក់ទាំងនោះនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍។

**សង្គតិភាពនៃការដាក់បង្ហាញ**

១.៤.១៣ *ការដាក់បង្ហាញនិងការធ្វើចំណាត់ថ្នាក់នៃគណនីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវរក្សាទុកពីការិយបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយទៀត លុះត្រាតែ÷*

(ក) *វាមានភាពច្បាស់លាស់ដែល បន្ទាប់ពីមានការផ្លាស់ប្តូរសំខាន់មួយនៃចរិកលក្ខណៈនៃប្រតិបត្តិការរបស់ស្ថាប័ន ឬការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដែលការដាក់បង្ហាញ ឬការធ្វើចំណាត់ថ្នាក់ផ្សេងទៀតអាចមានភាពសមស្របជាង ពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស និងការអនុវត្តគោលនយោបាយគណនេយ្យនៅក្នុងកថាខណ្ឌ ១.៣.២៧ ឬ*

(ខ) *ការផ្លាស់ប្តូរនៃការដាក់បង្ហាញត្រូវបានតម្រូវ តាមរយៈការធ្វើវិសោធនកម្មនាពេលអនាគតលើស្តង់ដានេះ។*

១.៤.១៤ ការរៀបចំរចនាសម្ព័ន្ធដ៏សំខាន់មួយនៃកិច្ចសម្រុះសម្រួលផ្តល់សេវា, ការបង្កើតស្ថាប័នរដ្ឋាភិបាលថ្មី ឬការបញ្ចប់ស្ថាប័នរដ្ឋាភិបាលដែលមានស្រាប់, ការទិញ ឬការលក់ដ៏សំខាន់មួយ ឬការត្រួតពិនិត្យលើការដាក់បង្ហាញជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នអាចស្នើថា របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ឬរបាយការណ៍ហិរញ្ញវត្ថុជាបុគ្គលផ្សេងទៀត គួរត្រូវបានដាក់បង្ហាញខុសៗគ្នា។ ឧទាហរណ៍រដ្ឋាភិបាលមួយអាចលក់ធនាគារសន្សំរបស់រដ្ឋាភិបាលដែលតំណាងឱ្យស្ថាប័នមួយក្នុងចំណោមស្ថាប័នសំខាន់បំផុតរបស់ខ្លួន ជាមួយនឹងស្ថាប័នដែលនៅសេសសល់ដែលផ្តល់សេវារដ្ឋបាល និងសេវាប្រឹក្សាពាក់ព័ន្ធនឹងគោលនយោបាយសំខាន់ៗ។ នៅក្នុងករណីនេះ ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលកំណត់គ្រឹះស្ថានហិរញ្ញវត្ថុមួយជាសកម្មភាពសំខាន់មួយរបស់រដ្ឋាភិបាល គឺហាក់ពុំមានការពាក់ព័ន្ធឡើយ។

១.៤.១៥ ស្ថាប័នមួយអាចផ្លាស់ប្តូរការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនបាន លុះត្រាតែរចនាសម្ព័ន្ធដែលត្រូវបានកែសម្រួលទំនងជាអាចបន្ត ឬប្រសិនបើការដាក់បង្ហាញជាជម្រើសមួយបានផ្តល់នូវព័ត៌មានដែលជាតំណាងដ៏ស្មោះត្រង់មួយ ហើយមានការពាក់ព័ន្ធចំពោះអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុប៉ុណ្ណោះ។ នៅពេលការផ្លាស់ប្តូរការដាក់បង្ហាញទាំងនេះត្រូវបានធ្វើឡើង ស្ថាប័នមួយត្រូវធ្វើចំណាត់ថ្នាក់ព័ត៌មានប្រៀបធៀបរបស់ខ្លួនឡើងវិញ ដោយអនុលោមតាមកថាខណ្ឌ ១.៤.១៩។ នៅពេលស្ថាប័នមួយអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជានេះ នោះការផ្លាស់ប្តូរការដាក់បង្ហាញដើម្បីឱ្យមានអនុលោមភាពជាមួយនឹងលក្ខខណ្ឌចាំបាច់ថ្នាក់ជាតិ ត្រូវបានអនុញ្ញាត ដរាបណាការដាក់បង្ហាញដែលត្រូវបានកែសម្រួល មានសង្គតិភាពជាមួយនឹងលក្ខខណ្ឌចាំបាច់នៃស្តង់ដានេះ។

**ព័ត៌មានប្រៀបធៀប**

១.៤.១៦ *ប្រសិនបើបទប្បញ្ញត្តិមួយនៃស្តង់ដានេះ មិនអនុញ្ញាតឬតម្រូវផ្សេងពីនេះទេ នោះព័ត៌មានប្រៀបធៀបត្រូវលាតត្រដាងទាក់ទងនឹងការិយបរិច្ឆេទមុន សម្រាប់ព័ត៌មានជាតួលេខទាំងអស់ដែលបានតម្រូវដោយស្តង់ដានេះឱ្យលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ លើកលែងតែទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទរាយការណ៍ដែលស្តង់ដានេះត្រូវបានអនុវត្តដំបូង។ ព័ត៌មានប្រៀបធៀបត្រូវរួមបញ្ចូលនៅក្នុងព័ត៌មានបែបពិពណ៌នានិងនិទាន នៅពេលដែលព័ត៌មាននេះពាក់ព័ន្ធនឹងការស្វែងយល់អំពីរបាយការណ៍ហិរញ្ញវត្ថុនៃការិយបរិច្ឆេទបច្ចុប្បន្ន។*

១.៤.១៧ ស្តង់ដានេះតម្រូវឱ្យមានការដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ និងបញ្ជាក់ពីការលាតត្រដាងជាក់លាក់ដែលត្រូវបានតម្រូវឱ្យរៀបចំឡើងនៅក្នុងរបាយការណ៍នោះ និងកំណត់សម្គាល់ផ្សេងៗ។ ស្តង់ដានេះមិនបានរារាំងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបន្ថែមឡើយ។ ផ្នែកទី ២ នៃស្តង់ដានេះលើកទឹកចិត្តឱ្យមានការលាតត្រដាងបន្ថែមជាក់លាក់។ នៅពេលរបាយការណ៍ហិរញ្ញវត្ថុបន្ថែមពីលើរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ត្រូវបានរៀបចំឡើង ឬការលាតត្រដាងដែលត្រូវបានលើកទឹកចិត្តដោយផ្នែកទី ២ នៃស្តង់ដានេះត្រូវបានធ្វើឡើង នោះការលាតត្រដាងអំពីព័ត៌មានប្រៀបធៀបក៏ត្រូវបានលើកទឹកចិត្តផងដែរ។

១.៤.១៨ នៅក្នុងករណីមួយចំនួន ព័ត៌មានបែបនិទានដែលបានផ្តល់ជូននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទមុនៗគឺបន្តជាប់ពាក់ព័ន្ធគ្នានឹងការិយបរិច្ឆេទបច្ចុប្បន្ន។ ឧទាហរណ៍ ព័ត៌មានលម្អិតអំពីជម្លោះផ្លូវច្បាប់, លទ្ធផលនៃជម្លោះនោះដែលមិនមានភាពច្បាស់លាស់នាកាលបរិច្ឆេទរាយការណ៍មុន និងនៅមិនទាន់បានដោះស្រាយនៅឡើយ ត្រូវលាតត្រដាងនៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន។ អ្នកប្រើប្រាស់ទទួលបានអត្ថប្រយោជន៍ពីការដឹងថា ភាពមិនជាក់លាក់បានកើតឡើងនាកាលបរិច្ឆេទរាយការណ៍មុន និងដឹងពីជំហានដែលបានអនុវត្តនាពេលកន្លងមកនៅក្នុងអំឡុងការិយបរិច្ឆេទ ដើម្បីដោះស្រាយភាពមិនច្បាស់លាស់។

១.៤.១៩ *នៅពេលការដាក់បង្ហាញ ឬការធ្វើចំណាត់ថ្នាក់គណនីដែលបានតម្រូវឱ្យលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានកែប្រែ នោះចំនួនទឹកប្រាក់ដែលអាចប្រៀបធៀបគ្នាបាន ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញលុះត្រាតែវាមិនអាចអនុវត្តដូច្នេះបាន ដើម្បីធានាបានថា ភាពដែលអាចប្រៀបធៀបគ្នាបានជាមួយនឹងការិយបរិច្ឆេទបច្ចុប្បន្ននិងចរិកលក្ខណៈ, ចំនួនទឹកប្រាក់ និងហេតុផលសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញណាមួយ ត្រូវបានលាតត្រដាង។ នៅពេលដែលមិនអាចធ្វើចំណាត់ថ្នាក់ឡើងវិញបានលើចំនួនទឹកប្រាក់ដែលអាចប្រៀបធៀបគ្នាបាន ស្ថាប័នត្រូវលាតត្រដាងអំពីហេតុផលដែលមិនធ្វើចំណាត់ថ្នាក់ឡើងវិញ និងចរិកលក្ខណៈនៃការផ្លាស់ប្តូរដែលអាចត្រូវបានធ្វើឡើង ប្រសិនបើចំនួនទឹកប្រាក់នោះត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ។*

១.៤.២០ ស្ថានភាពអាចកើតឡើង នៅពេលយើងមិនអាចធ្វើចំណាត់ថ្នាក់ឡើងវិញលើព័ត៌មានប្រៀបធៀប ដើម្បីសម្រេចបាននូវភាពដែលអាចប្រៀបធៀបគ្នាបានជាមួយនឹងការិយបរិច្ឆេទបច្ចុប្បន្ន។ ឧទាហរណ៍ ទិន្នន័យប្រហែលមិនត្រូវបានប្រមូលនៅក្នុងការិយបរិច្ឆេទមុនៗក្នុងមធ្យោបាយមួយដែលអនុញ្ញាត ឱ្យមានការធ្វើចំណាត់ថ្នាក់ឡើងវិញឡើយ ហើយយើងប្រហែលជាមិនអាចបង្កើតព័ត៌មានឡើងវិញបានឡើយ។ នៅក្នុងស្ថានភាពបែបនេះ ចរិកលក្ខណៈនៃការកែសម្រួលលើចំនួនទឹកប្រាក់ដែលអាចប្រៀបធៀបគ្នាបានដែលអាចត្រូវបានធ្វើឡើង ត្រូវបានលាតត្រដាង។

**ការកំណត់អត្តសញ្ញាណរបាយការណ៍ហិរញ្ញវត្ថុ**

១.៤.២១ *របាយការណ៍ហិរញ្ញវត្ថុត្រូវកំណត់ឱ្យបានច្បាស់លាស់ និងញែកឱ្យដាច់ពីព័ត៌មានផ្សេងទៀតនៅក្នុងឯកសារដែលបានបោះផ្សាយតែមួយ។*

១.៤.២២ ស្តង់ដានេះអនុវត្តតែចំពោះរបាយការណ៍ហិរញ្ញវត្ថុ ហើយមិនអនុវត្តចំពោះព័ត៌មានដទៃដែលបានដាក់បង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ឬឯកសារផ្សេងទៀតឡើយ។ ជាលទ្ធផល វាមានសារៈសំខាន់ដែលអ្នកប្រើប្រាស់អាចញែកព័ត៌មានដែលត្រូវបានរៀបចំឡើងដោយប្រើស្តង់ដានេះ ឱ្យដាច់ពីព័ត៌មានផ្សេងទៀតដែលអាចមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់ ប៉ុន្តែវាមិនមែនជាប្រធានបទសម្រាប់ស្តង់ដានេះ។

១.៤.២៣ *សមាសធាតុនីមួយៗនៃរបាយការណ៍ហិរញ្ញវត្ថុ ត្រូវកំណត់ឱ្យបានច្បាស់លាស់។ បន្ថែមពីនេះ ព័ត៌មានខាងក្រោមត្រូវបង្ហាញឱ្យបានឃើញច្បាស់ និងត្រូវធ្វើឡើងវិញជាថ្មី នៅពេលដែលវាចាំបាច់សម្រាប់ការយល់ដឹងដ៏ត្រឹមត្រូវមួយអំពីព័ត៌មានដែលបានដាក់បង្ហាញ៖*

(ក) *ឈ្មោះរបស់ស្ថាប័នរាយការណ៍ ឬមធ្យោបាយនៃការកំណត់អត្តសញ្ញាណផ្សេងទៀត*

(ខ) *ថាតើរបាយការណ៍ហិរញ្ញវត្ថុគ្របដណ្តប់លើស្ថាប័នមួយ ឬស្ថាប័នមួយក្រុម*

(គ) *កាលបរិច្ឆេទរាយការណ៍ ឬការិយបរិច្ឆេទដែលគ្របដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុ មួយណាក៏ដោយដែលសមស្របចំពោះសមាសធាតុពាក់ព័ន្ធនៃរបាយការណ៍ហិរញ្ញវត្ថុ*

(ឃ) *រូបិយបណ្ណសម្រាប់បង្ហាញ និង*

(ង) *កម្រិតនៃភាពច្បាស់លាស់ដែលបានប្រើក្នុងការដាក់បង្ហាញតួលេខ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។*

១.៤.២៤ លក្ខខណ្ឌចាំបាច់នៅក្នុងកថាខណ្ឌ ១.៤.២៣ ជាទូទៅត្រូវបានបំពេញដោយការដាក់បង្ហាញចំណងជើងទំព័រ និងចំណងជើងជួរឈរដែលបានសរសេរកាត់នៅលើទំព័រនីមួយៗនៃរបាយការណ៍ហិរញ្ញវត្ថុ។ ការជ្រើសរើសគំរូរបាយការណ៍ត្រូវបានតម្រូវក្នុងការកំណត់មធ្យោបាយដ៏ល្អបំផុតនៃការដាក់បង្ហាញព័ត៌មានទាំងនោះ។ ឧទាហរណ៍ នៅពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអានជាលក្ខណៈអេឡិចត្រូនិច នោះទំព័រដាច់ដោយឡែកប្រហែលជាមិនត្រូវបានប្រើនោះទេ។ នៅក្នុងករណីបែបនេះ គណនីដូចបានកំណត់ក្នុង

កថាខណ្ឌ ១.៤.២៣ ត្រូវបានដាក់បង្ហាញជាញឹកញាប់ ដើម្បីធានាដល់ការយល់ដឹងដ៏ត្រឹមត្រូវមួយអំពីព័ត៌មានដែលបានផ្តល់។

១.៤.២៥ របាយការណ៍ហិរញ្ញវត្ថុតែងត្រូវបានរៀបចំឡើងឱ្យងាយយល់ តាមរយៈការដាក់បង្ហាញព័ត៌មានជាឯកតាខ្ទង់ពាន់ ឬខ្ទង់លាននៃរូបិយបណ្ណសម្រាប់បង្ហាញ។ វាអាចទទួលយកបាន ដរាបណាកម្រិតនៃភាពច្បាស់លាស់ក្នុងការដាក់បង្ហាញត្រូវបានលាតត្រដាង ហើយព័ត៌មានពាក់ព័ន្ធមិនត្រូវបានបាត់បង់។

## ១.៥ ការកែតម្រូវកំហុសឆ្គង

១.៥.១ *នៅពេលកំហុសឆ្គងមួយកើតឡើងពាក់ព័ន្ធនឹងសមតុល្យសាច់ប្រាក់ ដូចបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ចំនួននៃកំហុសឆ្គងដែលពាក់ព័ន្ធនឹងការិយបរិច្ឆេទមុនៗត្រូវរាយការណ៍ ដោយកែតម្រូវសាច់ប្រាក់នាដើមការិយបរិច្ឆេទ។ ព័ត៌មានដែលអាចប្រៀបធៀបគ្នាបានត្រូវអះអាងឡើងវិញ លុះត្រាតែវាមិនអាចអនុវត្តដូច្នេះបាន។*

១.៥.២ *ស្ថាប័នមួយត្រូវលាតត្រដាងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុនូវ៖*

(ក) *ចរិកលក្ខណៈនៃកំហុសឆ្គងដែលពាក់ព័ន្ធនឹងការិយបរិច្ឆេទមុន*

(ខ) *ចំនួននៃការកែតម្រូវ និង*

(គ) *ការពិតដែលព័ត៌មានដែលអាចប្រៀបធៀបគ្នាបាន ត្រូវបានអះអាងឡើងវិញ ឬថា វាមិនអាចអនុវត្តដូច្នេះបាន។*

១.៥.៣ កំហុសឆ្គងនាការិយបរិច្ឆេទបច្ចុប្បន្នដែលមានសក្តានុពល ដែលត្រូវបានរកឃើញនៅក្នុងការិយបរិច្ឆេទបច្ចុប្បន្នត្រូវបានកែតម្រូវ មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានផ្តល់សិទ្ធិសម្រាប់ការបោះផ្សាយ។ កំហុសឆ្គងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទមុនមួយ ឬច្រើនឆ្នាំមុន អាចត្រូវបានរកឃើញនៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន។ កំហុសឆ្គងអាចកើតឡើងជាលទ្ធផលនៃកំហុសគណិតវិទ្យា, កំហុសនៃការអនុវត្តគោលនយោបាយគណនេយ្យ, ការបកស្រាយខុសអំពីការពិត, ការក្លែងបន្លំ ឬការមើលរំលង។ នៅពេលកំហុសឆ្គងមួយត្រូវបានរកឃើញទាក់ទងនឹងការិយបរិច្ឆេទមុនមួយ សមតុល្យសាច់ប្រាក់ដើមគ្រា ត្រូវបានកែប្រែដើម្បីកែតម្រូវកំហុសឆ្គងនាការិយបរិច្ឆេទមុន ហើយរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងព័ត៌មានដែលអាចប្រៀបធៀបគ្នាបានសម្រាប់ការិយបរិច្ឆេទមុនៗ ត្រូវបានដាក់បង្ហាញ ហាក់ដូចជាកំហុសឆ្គងត្រូវបានកែតម្រូវនៅក្នុងការិយបរិច្ឆេទដែលវាកើតឡើង។ ការពន្យល់អំពីកំហុសឆ្គង និងការកែតម្រូវកំហុសឆ្គងនោះ ត្រូវរួមបញ្ចូលនៅក្នុងកំណត់សម្គាល់។

១.៥.៤ ការបង្ហាញឡើងវិញនៃព័ត៌មានដែលអាចប្រៀបធៀបគ្នាបាន មិនចាំបាច់ឱ្យមានការកែប្រែរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានអនុម័តដោយស្ថាប័នអភិបាល ឬត្រូវបានចុះបញ្ជី ឬត្រូវបានផ្ញើជាមួយនឹងអាជ្ញាធរគ្រប់គ្រងនោះទេ។ ទោះបីជាយ៉ាងណា ច្បាប់ជាតិអាចតម្រូវឱ្យមានការកែប្រែរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

១.៥.៥ ស្តង់ដានេះតម្រូវឱ្យមានការដាក់បង្ហាញរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ និងមិនបានរារាំងដល់ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀតឡើយ។ នៅពេលរបាយការណ៍ហិរញ្ញវត្ថុ បន្ថែមពីលើរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ត្រូវបានដាក់បង្ហាញ នោះលក្ខខណ្ឌចាំបាច់នៅក្នុងកថាខណ្ឌ ១.៥.១ និង ១.៥.២ សម្រាប់ការកែតម្រូវកំហុសឆ្គង ក៏ត្រូវអនុវត្តចំពោះរបាយការណ៍ទាំងនេះផងដែរ។

## ១.៦ រូបិយបណ្ណបរទេស

### និយមន័យ

១.៦.១ *ពាក្យខាងក្រោមត្រូវបានប្រើនៅក្នុងស្តង់ដានេះជាមួយនឹងនិយមន័យដូចបានបញ្ជាក់÷*

*<u>អត្រាប្តូរប្រាក់ចុងគ្រា</u> គឺជាអត្រាប្តូរប្រាក់ដល់ដៃ នាកាលបរិច្ឆេទរាយការណ៍។*

*<u>ភាពខុសគ្នានៃការប្តូរប្រាក់</u> គឺជាភាពខុសគ្នាដែលកើតឡើងពីការបកប្រែចំនួនឯកតានៃរូបិយបណ្ណមួយទៅរូបិយបណ្ណមួយផ្សេងទៀត តាមអត្រាប្តូរប្រាក់ផ្សេងគ្នា។*

*<u>អត្រាប្តូរប្រាក់</u> គឺជាផលធៀបនៃការប្តូរប្រាក់រវាងរូបិយបណ្ណពីរ។*

*<u>រូបិយបណ្ណបរទេស</u> គឺជារូបិយបណ្ណមួយ ផ្សេងពីរូបិយបណ្ណសម្រាប់បង្ហាញរបស់ស្ថាប័ន។*

*<u>រូបិយបណ្ណសម្រាប់បង្ហាញ</u> គឺជារូបិយបណ្ណដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានដាក់បង្ហាញជារូបិយបណ្ណនោះ។*

*<u>អត្រាប្តូរប្រាក់ដល់ដៃ</u> គឺជាអត្រាប្តូរប្រាក់សម្រាប់ការផ្តល់ភ្លាមៗ។*

### ប្រតិបត្តិកម្មចំណូល ចំណាយ និងសមតុល្យសាច់ប្រាក់ជារូបិយបណ្ណបរទេស

១.៦.២ *ចំណូលនិងចំណាយសាច់ប្រាក់ដែលកើតឡើងពីប្រតិបត្តិការជារូបិយបណ្ណបរទេស ត្រូវរួមបញ្ចូលនៅក្នុងរបាយការណ៍ចំណូលនិងចំណាយ ជារូបិយបណ្ណសម្រាប់បង្ហាញរបស់ស្ថាប័ន ដោយយកចំនួនរូបិយបណ្ណបរទេសគុណនឹងអត្រាប្តូរប្រាក់ដល់ដៃ រវាងរូបិយបណ្ណរាយការណ៍ និងរូបិយបណ្ណបរទេស នាកាលបរិច្ឆេទនៃចំណូលនិងចំណាយ។*

១.៦.៣ *សមតុល្យសាច់ប្រាក់ដែលបានរក្សាទុកជារូបិយបណ្ណបរទេស ត្រូវបកប្រែដោយប្រើអត្រាប្តូរប្រាក់ចុងគ្រា។*

១.៦.៤ *ចំណូលសាច់ប្រាក់និងចំណាយសាច់ប្រាក់របស់ស្ថាប័នក្រោមការគ្រប់គ្រងនៅបរទេស ត្រូវបកប្រែតាមអត្រាប្តូរប្រាក់រវាងរូបិយបណ្ណសម្រាប់បង្ហាញនិងរូបិយបណ្ណបរទេស នាកាលបរិច្ឆេទនៃចំណូលនិងចំណាយ។*

១.៦.៥ *ស្ថាប័នមួយត្រូវលាតត្រដាងអំពីចំនួនទឹកប្រាក់នៃភាពខុសគ្នានៃការប្តូរប្រាក់ ដែលត្រូវបានរួមបញ្ចូលជាធាតុសម្រាប់ផ្ទៀងផ្ទាត់ រវាងសមតុល្យសាច់ប្រាក់ដើមគ្រា និងសមតុល្យសាច់ប្រាក់ចុងគ្រា សម្រាប់ការិយបរិច្ឆេទនោះ។*

១.៦.៦ *នៅពេលរូបិយបណ្ណសម្រាប់បង្ហាញ មានភាពខុសគ្នាពីរូបិយបណ្ណរបស់ប្រទេសដែលស្ថាប័នកំពុងស្ថិតនៅដោយស្របច្បាប់ នោះហេតុផលសម្រាប់ការប្រើរូបិយបណ្ណខុសគ្នាត្រូវលាតត្រដាង។ ហេតុផលសម្រាប់ការផ្លាស់ប្តូរណាមួយនៃរូបិយបណ្ណសម្រាប់បង្ហាញ ក៏ត្រូវលាតត្រដាងផងដែរ។*

១.៦.៧ រដ្ឋាភិបាលនិងស្ថាប័នរដ្ឋាភិបាលអាចមានប្រតិបត្តិការជារូបិយបណ្ណបរទេសដូចជា កម្ចីជារូបិយបណ្ណបរទេស, ការទទួលបានជំនួយខាងក្រៅ និងជំនួយផ្សេងទៀតក្នុងទម្រង់ជារូបិយបណ្ណបរទេស ឬការទិញទំនិញនិងសេវា ដែលតម្លៃបញ្ជាទិញត្រូវបានគិតជាចំនួនរូបិយបណ្ណបរទេស។ រដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាលក៏អាចមានប្រតិបត្តិការបរទេស ហើយផ្ទេរសាច់ប្រាក់ និងទទួលសាច់ប្រាក់ពីប្រតិបត្តិការបរទេសទាំងនោះ។ ដើម្បីរួមបញ្ចូលប្រតិបត្តិការជារូបិយបណ្ណបរទេស និងប្រតិបត្តិការបរទេសនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ស្ថាប័នត្រូវបង្ហាញចំណូល ចំណាយ និងសមតុល្យសាច់ប្រាក់ជារូបិយបណ្ណដែលស្ថាប័នរាយការណ៍ធ្វើការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

១.៦.៨ ចំណេញនិងខាតមិនទាន់ទទួលស្គាល់ ដែលកើតឡើងពីការផ្លាស់ប្តូរអត្រាប្តូរប្រាក់នៃរូបិយបណ្ណបរទេសគឺមិនមែនជាចំណូលនិងចំណាយសាច់ប្រាក់ទេ។ ទោះបីជាយ៉ាងណាក៏ដោយ ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់លើសាច់ប្រាក់ដែលបានរក្សាទុកជារូបិយបណ្ណបរទេស ត្រូវរាយការណ៍នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ដើម្បីច្របាច់បញ្ចូលសាច់ប្រាក់ដើមគ្រា និងសាច់ប្រាក់ចុងគ្រានៃការិយ-បរិច្ឆេទ។ ចំនួនទឹកប្រាក់នេះត្រូវបានដាក់បង្ហាញដាច់ដោយឡែកពីចំណូលនិងចំណាយសាច់ប្រាក់ និងរួមបញ្ចូលទាំងភាពខុសគ្នា បើមាន ប្រសិនបើចំណូល ចំណាយ និងសមតុល្យសាច់ប្រាក់ទាំងនោះត្រូវបានរាយការណ៍តាមអត្រាប្តូរប្រាក់ចុងគ្រានៃការិយបរិច្ឆេទ។

## ១.៧ ការដាក់បង្ហាញព័ត៌មានអំពីថវិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

**និយមន័យ**

១.៧.១ *ពាក្យខាងក្រោមត្រូវបានប្រើនៅក្នុងស្តង់ដានេះជាមួយនិយមន័យដូចបានបញ្ជាក់÷*

*<u>មូលដ្ឋានគណនេយ្យ</u> មានន័យថា មូលដ្ឋានគណនេយ្យសាច់ប្រាក់ ឬមូលដ្ឋានបង្គរដូចបានឱ្យនិយមន័យនៅក្នុងស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ និងស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់។*

*<u>ផែនការថវិកាប្រចាំឆ្នាំ</u> មានន័យថា ថវិកាដែលត្រូវបានអនុម័តសម្រាប់រយៈពេលមួយឆ្នាំ។ វាមិនរួមបញ្ចូលនូវការប៉ាន់ស្មាន ឬការព្យាករណ៍ទៅមុខដែលបានបោះផ្សាយសម្រាប់ការិយបរិច្ឆេទក្រោយការិយបរិច្ឆេទផែនការថវិកានោះទេ។*

*<u>ការវិភាជន៍ថវិកា</u> គឺជាការផ្តល់សិទ្ធិដែលបានផ្តល់ដោយស្ថាប័នច្បាប់ ដើម្បីបែងចែកមូលនិធិសម្រាប់គោលបំណង ដូចបានបញ្ជាក់ដោយអាជ្ញាធរនីតិបញ្ញត្តិ ឬ ស្ថាប័នប្រហាក់ប្រហែល។*

*<u>ផែនការថវិកាដែលបានអនុម័ត</u> ជាចំណាយដែលអាជ្ញាធរបានទទួលពីច្បាប់ដែលបានអនុម័ត, សេចក្តីស្នើច្បាប់, សេចក្តីព្រាងច្បាប់ និងការសម្រេចចិត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងប្រាក់ចំណូល ឬចំណូលដែលបានព្យាករណ៍ទុក សម្រាប់ការិយបរិច្ឆេទផែនការថវិកា។*

*<u>មូលដ្ឋានផែនការថវិកា</u> មានន័យថា មូលដ្ឋានគណនេយ្យបង្គរ មូលដ្ឋានគណនេយ្យសាច់ប្រាក់ ឬមូលដ្ឋានគណនេយ្យផ្សេងទៀត ដែលបានប្រើនៅក្នុងផែនការថវិកាដែលត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិ។*

*<u>មូលដ្ឋានប្រៀបធៀប</u> មានន័យថា ចំនួនទឹកប្រាក់ជាក់ស្តែងដែលបានដាក់បង្ហាញតាមមូលដ្ឋានគណនេយ្យដូចគ្នា, មូលដ្ឋានចំណាត់ថ្នាក់ដូចគ្នា, សម្រាប់ស្ថាប័នដូចគ្នា, និងសម្រាប់ការិយបរិច្ឆេទដូចគ្នាទៅនឹងផែនការថវិកាដែលបានអនុម័ត។*

*<u>ផែនការថវិកាចុងក្រោយ</u> គឺជាផែនការថវិកាដើមដែលត្រូវបានកែសម្រួលសម្រាប់ការបម្រុងទុកទាំងអស់, ការផ្ទេរផែនការថវិកាពីគ្រាមុន, ការផ្ទេរ, ការបែងចែក, ការបម្រុងទុកបន្ថែម, និងការផ្លាស់ប្តូរអាជ្ញាធរនីតិបញ្ញត្តិ ឬអាជ្ញាធរប្រហាក់ប្រហែលដែលត្រូវបានផ្តល់សិទ្ធិ ពាក់ព័ន្ធនឹងការិយបរិច្ឆេទផែនការថវិកា។*

*<u>ផែនការថវិកាច្រើនឆ្នាំ</u> គឺជាផែនការថវិកាដែលបានអនុម័តសម្រាប់រយៈពេលច្រើនជាងមួយឆ្នាំ។ វាមិនរួមបញ្ចូលនូវការប៉ាន់ស្មាន ឬការព្យាករណ៍ទៅមុខដែលបានបោះផ្សាយសម្រាប់ការិយបរិច្ឆេទក្រោយការិយបរិច្ឆេទផែនការថវិកានោះទេ។*

*<u>ផែនការថវិកាដើម</u> គឺជាផែនការថវិកាដែលបានអនុម័តដំបូងសម្រាប់ការិយបរិច្ឆេទផែនការថវិកា។*

**ផែនការថវិកាដែលបានអនុម័ត**

១.៧.២ ផែនការថវិកាដែលត្រូវបានអនុម័តមួយដូចបានផ្តល់និយមន័យដោយស្តង់ដានេះ ឆ្លុះបញ្ចាំងពីប្រាក់ចំណូល ឬចំណូលព្យាករណ៍ទុកដែលត្រូវបានរំពឹងទុកថា អាចកើតឡើងនៅក្នុងការិយបរិច្ឆេទផែនការថវិកាប្រចាំឆ្នាំ ឬច្រើនឆ្នាំ ដោយផ្អែកលើផែនការបច្ចុប្បន្ន និងលក្ខខណ្ឌសេដ្ឋកិច្ចដែលបានព្យាករណ៍ទុកនៅក្នុងអំឡុងការិយបរិច្ឆេទផែនការថវិកានោះ និងចំណាយ ឬចំណាយដែលបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិមួយដែលជាអង្គនីតិបញ្ញត្តិ ឬអាជ្ញាធរពាក់ព័ន្ធដទៃទៀត។ ផែនការថវិកាដែលបានអនុម័តមួយគឺមិនមែនជាការប៉ាន់ស្មាន ឬការព្យាករណ៍ទៅមុខដោយផ្អែកលើការសន្មតអំពីព្រឹត្តិការណ៍នាពេលអនាគត និងសកម្មភាពរបស់ថ្នាក់ដឹកនាំដែលអាចទៅរួច ដែលមិនត្រូវបានរំពឹងទុកថានឹងកើតឡើងទេ។ ស្រដៀងគ្នានេះដែរ ផែនការថវិកាដែលបានអនុម័តមួយខុសគ្នាពីព័ត៌មានហិរញ្ញវត្ថុដែលអាចមានទម្រង់ជាការព្យាករណ៍, ការប្រមើល ឬការបញ្ចូលគ្នាទាំងពីរ ឧទាហរណ៍ ការព្យាករណ៍រយៈពេលមួយឆ្នាំ បូកនឹងការប្រមើលរយៈពេលប្រាំឆ្នាំ។

១.៧.៣ នៅក្នុងយុត្តាធិការមួយចំនួន ផែនការថវិកាអាចត្រូវបានចុះហត្ថលេខាទៅក្នុងច្បាប់ថាជាផ្នែកមួយនៃដំណើរការអនុម័ត។ នៅក្នុងយុត្តាធិការផ្សេងទៀត ការអនុម័តអាចត្រូវបានផ្តល់ដោយមិនចាំបាច់ធ្វើឱ្យថវិកាក្លាយទៅជាច្បាប់ឡើយ។ មិនថាដំណើរការអនុម័តមានលក្ខណៈបែបណានោះទេ លក្ខណៈសម្បត្តិសំខាន់នៃផែនការថវិកាដែលបានអនុម័តគឺថា សិទ្ធិក្នុងការដកយកមូលនិធិពីរតនាគាររបស់រដ្ឋាភិបាល ឬស្ថាប័នប្រហាក់ប្រហែលសម្រាប់គោលបំណងដែលបានឯកភាពនិងកំណត់ គឺត្រូវបានផ្តល់ដោយស្ថាប័ននីតិបញ្ញត្តិជាន់ខ្ពស់ ឬអាជ្ញាធរសមស្របដទៃទៀត។ ផែនការថវិកាដែលបានអនុម័តបង្កើតឱ្យមានអាជ្ញាធរចំណាយសម្រាប់គណនីដែលបានកំណត់ជាក់លាក់។ អាជ្ញាធរចំណាយ ជាទូទៅ ត្រូវបានចាត់ទុកជាដែនកម្រិតផ្នែកច្បាប់ដែលស្ថាប័នមួយត្រូវប្រតិបត្តិនៅក្នុងដែនកម្រិតនោះ។ នៅក្នុងយុត្តាធិការមួយចំនួន ផែនការថវិកាដែលបានអនុម័តដែលស្ថាប័នត្រូវមានទំនួលខុសត្រូវ អាចជាផែនការថវិកាដើម ហើយនៅក្នុងយុត្តាធិការផ្សេងទៀត ថវិកាដែលបានអនុម័តនោះអាចជាផែនការថវិកាចុងក្រោយ។

១.៧.៤ ប្រសិនបើផែនការថវិកាមួយ មិនត្រូវបានអនុម័តមុនដើមគ្រានៃការិយបរិច្ឆេទផែនការថវិកាទេ ផែនការថវិកាដើមគឺជាផែនការថវិកាដែលត្រូវបានអនុម័តដំបូង សម្រាប់យកទៅអនុវត្តនៅក្នុងឆ្នាំថវិកា។

**ផែនការថវិកាដើម និងផែនការថវិកាចុងក្រោយ**

១.៧.៥ ផែនការថវិកាដើមអាចរួមបញ្ចូលនូវផែនការថវិកាគ្រោងនៅសល់ដែលត្រូវបានបន្តពីឆ្នាំមុនៗដោយច្បាប់។ ឧទាហរណ៍ ដំណើរការរៀបចំផែនការថវិការបស់រដ្ឋាភិបាលនៅក្នុងយុត្តាធិការមួយចំនួនរួមបញ្ចូលនូវបទប្បញ្ញត្តិផ្នែកច្បាប់មួយ ដែលតម្រូវឱ្យមានការបញ្ជូនដោយស្វ័យប្រវត្តិនៃផែនការថវិកាគ្រោងដើម្បីគ្របដណ្តប់លើកាតព្វកិច្ចឆ្នាំមុន។ កាតព្វកិច្ច រួមមាន បំណុលនាពេលអនាគតដែលអាចទៅរួច ដោយផ្អែកលើកិច្ចព្រមព្រៀងកិច្ចសន្យាបច្ចុប្បន្ន។ នៅក្នុងយុត្តាធិការមួយចំនួន កាតព្វកិច្ចអាចសំដៅលើកាតព្វកិច្ច ឬបំណុល ហើយរួមបញ្ចូលនូវការបញ្ជាទិញមិនទាន់សង និងកិច្ចសន្យាដែលទំនិញ ឬសេវាមិនទាន់បានទទួលនៅឡើយ។

១.៧.៦ វិភាជន៍បន្ថែម អាចចាំបាច់នៅពេលដែលផែនការថវិកាដើមមិនបានព្យាករណ៍បានគ្រប់ជ្រុងជ្រោយអំពីលក្ខខណ្ឌចាំបាច់នៃការចំណាយដែលកើតឡើងពី ឧទាហរណ៍ សង្គ្រាម ឬ គ្រោះមហន្តរាយធម្មជាតិ។ បន្ថែមពីនេះ វាអាចមានកង្វះខាតចំណូលដែលបានគ្រោងទុកនៅក្នុងអំឡុងការិយបរិច្ឆេទហើយការផ្ទេរផ្ទៃក្នុងរវាងចំណងជើងផែនការថវិកា ឬបន្ទាត់គណនី អាចចាំបាច់ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរអាទិភាពនៃការផ្តល់មូលនិធិនៅក្នុងអំឡុងការិយបរិច្ឆេទសារពើពន្ធ។ ជាលទ្ធផល មូលនិធិដែលត្រូវបានផ្តល់ទៅឱ្យស្ថាប័នមួយ ឬសកម្មភាពមួយ អាចចាំបាច់ត្រូវកាត់ចេញពីចំនួនទឹកប្រាក់ដើមដែលត្រូវបានធ្វើវិភាជន៍សម្រាប់ការិយបរិច្ឆេទ ដើម្បីរក្សានូវគោលការណ៍សារពើពន្ធ។ ថវិកាចុងក្រោយរួមបញ្ចូលនូវការផ្លាស់ប្តូរ ឬការកែប្រែដែលត្រូវបានផ្តល់សិទ្ធិទាំងអស់។

**ចំនួនទឹកប្រាក់ជាក់ស្តែង**

១.៧.៧ ស្តង់ដានេះប្រើពាក្យ"ជាក់ស្តែង ឬចំនួនទឹកប្រាក់ជាក់ស្តែង" ដើម្បីពិពណ៌នាអំពីចំនួនទឹកប្រាក់ដែលកើតចេញពីការអនុវត្តផែនការថវិកា។ នៅក្នុងយុត្តាធិការមួយចំនួន ផែនការថវិកាជាក់ស្តែង, ការសម្រេចផែនការថវិកា ឬពាក្យប្រហាក់ប្រហែលគ្នា អាចត្រូវបានប្រើជាមួយនឹងនិយមន័យដូចគ្នាថា "ជាក់ស្តែង ឬចំនួនទឹកប្រាក់ជាក់ស្តែង"។

**ការដាក់បង្ហាញការប្រៀបធៀបផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង**

១.៧.៨ *យោងទៅតាមលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៧.១៧ ស្ថាប័នមួយដែលធ្វើឱ្យថវិកាដែលបានអនុម័តរបស់ខ្លួនអាចប្រើប្រាស់បានជាសាធារណៈ ត្រូវដាក់បង្ហាញការប្រៀបធៀបចំនួនទឹកប្រាក់ផែនការថវិកាដែលស្ថាប័នមានទំនួលខុសត្រូវជាសាធារណៈ និងចំនួនទឹកប្រាក់ជាក់ស្តែងជារបាយការណ៍ហិរញ្ញវត្ថុបន្ថែមដាច់ដោយឡែក ឬជាតារាងជួរឈរផែនការថវិកាបន្ថែមនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដែលបានដាក់បង្ហាញនាពេលបច្ចុប្បន្ន ដោយអនុលោមតាមស្តង់ដានេះ។ ការប្រៀបធៀបផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង ត្រូវដាក់បង្ហាញដាច់ដោយឡែក សម្រាប់កម្រិតនីមួយៗនៃការត្រួតពិនិត្យនីតិបញ្ញត្តិ នូវ÷*

(ក) *ចំនួនទឹកប្រាក់ផែនការថវិកាដើម និងផែនការថវិកាចុងក្រោយ*

(ខ) *ចំនួនទឹកប្រាក់ជាក់ស្តែង តាមមូលដ្ឋានប្រៀបធៀប និង*

(គ) *តាមរយៈមធ្យោបាយនៃការលាតត្រដាងកំណត់សម្គាល់, ការពន្យល់មួយអំពីភាពខុសគ្នាជាសារវន្តរវាងផែនការថវិកាដែលស្ថាប័នមានទំនួលខុសត្រូវជាសាធារណៈ និងចំនួនទឹកប្រាក់ជាក់ស្តែង ប្រសិនបើការពន្យល់បែបនេះ មិនត្រូវបានរួមបញ្ចូលនៅក្នុងឯកសារសាធារណៈផ្សេងទៀតដែលត្រូវបានបោះផ្សាយជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុ ហើយការផ្ទៀងផ្ទាត់ជាមួយនឹងឯកសារទាំងនោះ ត្រូវបានធ្វើឡើងនៅក្នុងកំណត់សម្គាល់។*

**វិសាលភាព**

១.៧.៩ ស្តង់ដានេះអនុវត្តចំពោះស្ថាប័នទាំងអស់ដែលបានតម្រូវ ឬជ្រើសរើសធ្វើឱ្យផែនការថវិកាដែលបានអនុម័ត អាចប្រើប្រាស់បានជាសាធារណៈ។ ស្តង់ដានេះមិនបានតម្រូវធ្វើឱ្យផែនការថវិកាដែលត្រូវបានអនុម័តនោះអាចត្រូវបានប្រើប្រាស់ជាសាធារណៈនោះទេ ហើយក៏មិនបានតម្រូវថា របាយការណ៍ហិរញ្ញវត្ថុត្រូវលាតត្រដាងព័ត៌មាន ឬរួមបញ្ចូលនូវការប្រៀបធៀបជាមួយនឹងផែនការថវិកាដែលបានអនុម័តដែលមិនបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈនោះដែរ។

១.៧.១០ នៅក្នុងករណីមួយចំនួន ផែនការថវិកាដែលបានអនុម័តនឹងត្រូវបានចងក្រងដើម្បីរួមបញ្ចូលនូវរាល់សកម្មភាពទាំងអស់ដែលបានគ្រប់គ្រងដោយស្ថាប័នសាធារណៈមួយ។ នៅក្នុងករណីផ្សេងទៀត ផែនការថវិកាដែលបានអនុម័តដាច់ដោយឡែក អាចត្រូវបានតម្រូវដាក់ឱ្យប្រើប្រាស់ជាសាធារណៈសម្រាប់

សកម្មភាពជាក់លាក់, ក្រុមសកម្មភាព ឬស្ថាប័នដូចបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ឬស្ថាប័នសាធារណៈផ្សេងទៀត។ វាអាចកើតឡើងនៅពេល ឧទាហរណ៍ របាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាលរួមមាន ភ្នាក់ងារ ឬកម្មវិធីរបស់រដ្ឋាភិបាលដែលមានស្វ័យភាពលើប្រតិបត្តិការ និងរៀបចំផែនការថវិកាផ្ទាល់ខ្លួន ឬនៅពេលផែនការថវិកាត្រូវបានរៀបចំតែសម្រាប់វិស័យរដ្ឋាភិបាលទូទៅនៃរដ្ឋាភិបាលទាំងមូល។ ស្តង់ដានេះអនុវត្តចំពោះស្ថាប័នទាំងអស់ដែលដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ នៅពេលផែនការថវិកាដែលបានអនុម័តសម្រាប់ស្ថាប័នឬសមាសធាតុ ត្រូវបានដាក់ឱ្យប្រើជាសាធារណៈ។

**ការប្រៀបធៀបផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង**

១.៧.១១ ការដាក់បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុនូវចំនួនទឹកប្រាក់ផែនការថវិកាដើម និងផែនការថវិកាចុងក្រោយ ជាមួយនឹងចំនួនទឹកប្រាក់ជាក់ស្តែងតាមមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបាន ជាមួយនឹងផែនការថវិកាដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ នឹងជួយបំពេញនូវវដ្តគណនេយ្យភាព ដោយអនុញ្ញាតឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុអាចកំណត់ថាតើ ធនធានត្រូវបានទទួល និងត្រូវបានប្រើប្រាស់ អនុលោមទៅតាមផែនការថវិកាដែលបានអនុម័តដែរឬទេ។ ភាពខុសគ្នារវាងចំនួនទឹកប្រាក់ជាក់ស្តែង និងចំនួនទឹកប្រាក់ផែនការថវិកា មិនថាជាផែនការថវិកាដើម ឬផែនការថវិកាចុងក្រោយ (ដែលសំដៅលើភាពខុសគ្នានៅក្នុងគណនេយ្យ) ក៏អាចត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឱ្យមានភាពពេញលេញផងដែរ។

១.៧.១២ ការពន្យល់អំពីភាពខុសគ្នាជាសារវន្តរវាងចំនួនទឹកប្រាក់ជាក់ស្តែងនិងចំនួនទឹកប្រាក់ផែនការថវិកា នឹងជួយឱ្យអ្នកប្រើប្រាស់បានយល់ពីហេតុផលដែលនាំឱ្យមានការងាកចេញជាសារវន្ត ពីថវិកាដែលបានអនុម័ត ដែលស្ថាប័នត្រូវទទួលខុសត្រូវជាសាធារណៈ។

១.៧.១៣ ស្ថាប័នមួយអាចត្រូវបានតម្រូវ ឬអាចជ្រើសរើសឱ្យដាក់ផែនការថវិកាដើម, ផែនការថវិកាចុងក្រោយ ឬផែនការថវិកាទាំងពីររបស់ខ្លួនឱ្យប្រើប្រាស់ជាសាធារណៈ។ នៅក្នុងស្ថានភាពដែលផែនការថវិកាដើម និងផែនការថវិកាចុងក្រោយត្រូវបានតម្រូវឱ្យប្រើប្រាស់ជាសាធារណៈ នោះច្បាប់, បទប្បញ្ញត្តិ ឬអាជ្ញាធរដទៃទៀត ជារឿយៗនឹងផ្តល់នូវសេចក្តីណែនាំថាតើ ការពន្យល់អំពីភាពខុសគ្នាជាសារវន្តរវាងចំនួនទឹកប្រាក់ផែនការថវិកាជាក់ស្តែង និងចំនួនទឹកប្រាក់ផែនការថវិកាដើម ឬចំនួនទឹកប្រាក់ផែនការថវិកាជាក់ស្តែងនិងចំនួនទឹកប្រាក់ផែនការថវិកាចុងក្រោយ ត្រូវបានតម្រូវ ដោយអនុលោមទៅតាមកថាខណ្ឌ ១.៧.៨(គ) ឬក៏យ៉ាងណា។ ក្នុងករណីដែលគ្មានសេចក្តីណែនាំណាមួយបែបនេះទេ ភាពខុសគ្នាជាសារវន្តអាចត្រូវបានកំណត់ដោយយោងទៅតាម ឧទាហរណ៍ ភាពខុសគ្នារវាងផែនការថវិកាជាក់ស្តែង និងផែនការថវិកាដើម ដើម្បីផ្តោតលើលទ្ធផលជាមួយនឹងផែនការថវិកាដើម ឬភាពខុសគ្នារវាងផែនការថវិកាជាក់ស្តែងនិងផែនការថវិកាចុងក្រោយដើម្បីផ្តោតលើអនុលោមភាពតាមផែនការថវិកាចុងក្រោយ។

១.៧.១៤ នៅក្នុងករណីជាច្រើន ចំនួនទឹកប្រាក់ផែនការថវិកាចុងក្រោយនិងចំនួនទឹកប្រាក់ជាក់ស្តែង នឹងមានចំនួនដូចគ្នា។ នេះគឺដោយសារតែការអនុវត្តផែនការថវិកា ត្រូវបានតាមដានត្រួតពិនិត្យនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ហើយផែនការថវិកាដើមត្រូវបានកែតម្រូវឡើងវិញជាបន្តបន្ទាប់ ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌដែលផ្លាស់ប្តូរ, ស្ថានភាពដែលផ្លាស់ប្តូរ និងបទពិសោធន៍ក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍។ កថាខណ្ឌ ១.៧.២៣ នៃស្តង់ដានេះ តម្រូវឱ្យមានការលាតត្រដាងការពន្យល់អំពីហេតុផលនៃការផ្លាស់ប្តូររវាងផែនការថវិកាដើម និងផែនការថវិកាចុងក្រោយ។ ការលាតត្រដាងនោះ ជាមួយគ្នានឹងការលាតត្រដាងដែលបានតម្រូវដោយកថាខណ្ឌ ១.៧.៨ ខាងលើ នឹងធានាថា ស្ថាប័នដែលដាក់ផែនការថវិកាដែលបានអនុម័តរបស់ពួកគេឱ្យប្រើប្រាស់ជាសាធារណៈ ត្រូវទទួលខុសត្រូវជាសាធារណៈសម្រាប់លទ្ធផលនិងអនុលោមភាពរបស់ខ្លួន ធៀបនឹងផែនការថវិកាដែលបានអនុម័តពាក់ព័ន្ធ។

១.៧.១៥ ការពិភាក្សានិងការវិភាគរបស់ថ្នាក់ដឹកនាំ, ការត្រួតពិនិត្យលើប្រតិបត្តិការ ឬរបាយការណ៍សាធារណៈផ្សេងទៀតដែលផ្តល់ការអត្ថាធិប្បាយលើលទ្ធផល និងជោគជ័យរបស់ស្ថាប័ននៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ ដោយរួមបញ្ចូលទាំងការពន្យល់អំពីភាពខុសគ្នាជាសារវ័ន្តណាមួយពីចំនួនទឹកប្រាក់ផែនការថវិកាគឺតែងត្រូវបានបោះផ្សាយជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុ។ អនុលោមតាមកថាខណ្ឌ ១.៧.៨ (គ) នៃស្តង់ដានេះ ការពន្យល់អំពីភាពខុសគ្នាជាសារវ័ន្តរវាងចំនួនទឹកប្រាក់ជាក់ស្តែង និងចំនួនទឹកប្រាក់ផែនការថវិកានឹងត្រូវបានរួមបញ្ចូលនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ប្រសិនបើមិនត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍សាធារណៈ ឬឯកសារដទៃផ្សេងទៀតដែលបានបោះផ្សាយជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ហើយកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុកំណត់ពីរបាយការណ៍ ឬឯកសារដែលការពន្យល់អាចត្រូវបានរកឃើញនៅក្នុងរបាយការណ៍ ឬឯកសារទាំងនោះ។

១.៧.១៦ នៅពេលផែនការថវិកាដែលបានអនុម័ត ត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈសម្រាប់ស្ថាប័ន ឬសកម្មភាពមួយចំនួនដែលត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ លក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៧.៨ នឹងអនុវត្តចំពោះតែស្ថាប័ន ឬសកម្មភាពណាដែលបានឆ្លុះបញ្ចាំងនៅក្នុងផែនការថវិកាដែលបានអនុម័តប៉ុណ្ណោះ។ នេះមានន័យថា ឧទាហរណ៍ នៅពេលដែលផែនការថវិកាត្រូវបានរៀបចំសម្រាប់តែវិស័យរដ្ឋាភិបាលទូទៅនៃស្ថាប័នរាយការណ៍របស់រដ្ឋាភិបាលទាំងមូល ការលាតត្រដាងដែលបានតម្រូវដោយកថាខណ្ឌ ១.៧.៨ នឹងត្រូវបានធ្វើឡើងទាក់ទងនឹងវិស័យរដ្ឋាភិបាលទូទៅរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។

**ការដាក់បង្ហាញ**

១.៧.១៧ *ស្ថាប័នមួយ ត្រូវដាក់បង្ហាញការប្រៀបធៀបផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែងជាតារាងជួរឈរផែនការថវិកាបន្ថែមនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ តែនៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុនិងផែនការថវិកាត្រូវបានរៀបចំតាមមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបានប៉ុណ្ណោះ។*

១.៧.១៨ ការប្រៀបធៀបផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែង អាចត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ("របាយការណ៍ប្រៀបធៀបផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែង" ឬ របាយការណ៍ដែលមានចំណងជើងប្រហាក់ប្រហែល")។ ជម្រើសមួយទៀត នៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុនិងផែនការថវិកាត្រូវបានរៀបចំតាមមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបានគឺថា តាមមូលដ្ឋានគណនេយ្យដូចគ្នាសម្រាប់ស្ថាប័ន និងការិយបរិច្ឆេទរាយការណ៍ដូចគ្នា និងប្រើប្រាស់ទម្រង់នៃការធ្វើចំណាត់ថ្នាក់ដូចគ្នា តារាងជួរឈរបន្ថែមអាចត្រូវបានបន្ថែមទៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ដែលត្រូវបានដាក់បង្ហាញ ដោយអនុលោមតាមស្តង់ដានេះ។ តារាងជួរឈរបន្ថែមទាំងនេះនឹងកំណត់ពីចំនួនទឹកប្រាក់ផែនការថវិកាដើម និងចំនួនទឹកប្រាក់ផែនការថវិកាចុងក្រោយ និងប្រសិនបើស្ថាប័នជ្រើសរើសភាពខុសគ្នារវាងចំនួនទឹកប្រាក់ផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង។

១.៧.១៩ នៅពេលដែលផែនការថវិកា និងរបាយការណ៍ហិរញ្ញវត្ថុមិនត្រូវបានរៀបចំឡើងតាមមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបាននោះទេ របាយការណ៍ប្រៀបធៀបដាច់ដោយឡែករវាងចំនួនទឹកប្រាក់ផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែង គឺត្រូវដាក់បង្ហាញ។ នៅក្នុងករណីទាំងនេះ ដើម្បីធានាថា អ្នកអានមិនបានបកស្រាយខុសលើព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានរៀបចំឡើងតាមមូលដ្ឋានខុសគ្នា របាយការណ៍ហិរញ្ញវត្ថុអាចបញ្ជាក់ថា ផែនការថវិកានិងមូលដ្ឋានគណនេយ្យមានភាពខុសគ្នា ហើយរបាយការណ៍ប្រៀបធៀបផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែងត្រូវបានរៀបចំឡើងតាមមូលដ្ឋានថវិកា។

## កម្រិតនៃការសរុបបញ្ចូលគ្នា

១.៧.២០ ឯកសារថវិកាអាចផ្តល់នូវព័ត៌មានដ៏សំខាន់អំពីសកម្មភាព កម្មវិធី ឬស្ថាប័នជាក់លាក់។ ព័ត៌មានលម្អិតទាំងអស់នេះតែងត្រូវបានសរុបបញ្ចូលគ្នាទៅក្នុងថ្នាក់ទូលាយ ក្រោមចំណងជើងផែនការថវិកាធម្មតា, ចំណាត់ថ្នាក់ផែនការថវិកា, ឬចំណងជើងផែនការថវិកាសម្រាប់ការដាក់បង្ហាញ និងការអនុម័តដោយអង្គនីតិបញ្ញត្តិ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត។ ការលាតត្រដាងអំពីព័ត៌មានផែនការថវិកានិងព័ត៌មានជាក់ស្តែងដែលមានសង្គតិភាពជាមួយនឹងថ្នាក់ទូលាយទាំងនោះ និងចំណងជើងផែនការថវិកា ឬចំណងជើង នឹងធានាថា ការប្រៀបធៀបត្រូវបានធ្វើឡើងក្នុងកម្រិតនៃការត្រួតពិនិត្យរបស់អង្គនីតិបញ្ញត្តិ ឬស្ថាប័នមានសមត្ថកិច្ចដទៃទៀតដូចបានកំណត់នៅក្នុងឯកសារថវិកា។

១.៧.២១ នៅក្នុងករណីមួយចំនួន ព័ត៌មានហិរញ្ញវត្ថុលម្អិតដែលត្រូវបានរួមបញ្ចូលនៅក្នុងផែនការថវិកាដែលបានអនុម័ត អាចចាំបាច់ត្រូវសរុបបញ្ចូលគ្នាដើម្បីដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមលក្ខខណ្ឌចាំបាច់នៃស្តង់ដានេះ។ ការសរុបបញ្ចូលគ្នានេះអាចជាការចាំបាច់ដើម្បីជៀសវាងការមានព័ត៌មានច្រើនហួស និងដើម្បីឆ្លុះបញ្ចាំងពីកម្រិតនៃការត្រួតពិនិត្យរបស់អង្គនីតិបញ្ញត្តិ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត។ ការកំណត់ពីកម្រិតនៃការសរុបបញ្ចូលគ្នា នឹងមានជាប់ពាក់ព័ន្ធនឹងការវិនិច្ឆ័យបែបវិជ្ជាជីវៈ។ ការវិនិច្ឆ័យនោះនឹងត្រូវបានអនុវត្តនៅក្នុងបរិបទនៃគោលបំណងនៃស្តង់ដានេះ

និងបុគ្គលិកលក្ខណៈបែបគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុ ដូចបានកំណត់ក្នុងកថាខណ្ឌ ១.៣.២៧ នៃស្តង់ដានេះ។

១.៧.២២ ព័ត៌មានអំពីផែនការថវិកាបន្ថែម ដោយរួមបញ្ចូលទាំងព័ត៌មានអំពីជោគជ័យនៃការផ្តល់សេវា អាចត្រូវបានដាក់បង្ហាញនៅក្នុងឯកសារផ្សេងក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ។ ផ្នែកទី ២ នៃស្តង់ដានេះលើកទឹកចិត្តឱ្យមានការរួមបញ្ចូលនូវការផ្ទៀងផ្ទាត់ចំពោះឯកសារទាំងនេះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**ការផ្លាស់ប្តូរពីផែនការថវិកាដើមទៅផែនការថវិកាចុងក្រោយ**

១.៧.២៣ *ស្ថាប័នមួយត្រូវដាក់បង្ហាញការពន្យល់មួយអំពីថាតើ ការផ្លាស់ប្តូររវាងផែនការថវិកាដើមនិងផែនការថវិកាចុងក្រោយ គឺជាលទ្ធផលនៃការបែងចែកឡើងវិញនៅក្នុងថវិកា ឬលទ្ធផលនៃកត្តាផ្សេងទៀត មិនថា÷*

(ក) *តាមរយៈការលាតត្រដាងអំពីកំណត់សម្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ*

(ខ) *នៅក្នុងរបាយការណ៍មួយដែលត្រូវបានបោះផ្សាយពីមុន ក្នុងពេលតែមួយ ឬជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុ ហើយត្រូវរួមបញ្ចូលនូវការផ្ទៀងផ្ទាត់ទៅនឹងរបាយការណ៍នៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។*

១.៧.២៤ ផែនការថវិកាចុងក្រោយរួមបញ្ចូលនូវការផ្លាស់ប្តូរទាំងអស់ ដែលបានអនុម័តដោយសកម្មភាពរបស់អង្គនីតិបញ្ញត្តិ ឬអាជ្ញាធរជ្រើសតាំងផ្សេងទៀត ដើម្បីពិនិត្យឡើងវិញលើផែនការថវិកាដើម។ ដោយមានសង្គតិភាពជាមួយនឹងលក្ខខណ្ឌចាំបាច់នៃស្តង់ដានេះ កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍ដាច់ដោយឡែកមួយដែលត្រូវបានបោះផ្សាយពីមុន ជាមួយគ្នានឹង ឬក្នុងពេលតែមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ នឹងរួមបញ្ចូលនូវការពន្យល់មួយអំពីការផ្លាស់ប្តូររវាងផែនការថវិកាដើម និងផែនការថវិកាចុងក្រោយ។ ការពន្យល់នោះនឹងរួមបញ្ចូល ឧទាហរណ៍ មិនថាជាការផ្លាស់ប្តូរដែលកើតឡើងជាលទ្ធផលនៃការបែងចែកឡើងវិញនៅក្នុងកម្រិតថេរនៃផែនការថវិកាដើម ឬជាលទ្ធផលនៃកត្តាផ្សេងទៀតដូចជា ការផ្លាស់ប្តូរនៃកម្រិតថេរនៃថវិកាទូទៅ រួមបញ្ចូលទាំងការផ្លាស់ប្តូរគោលនយោបាយរបស់រដ្ឋាភិបាល។ ការលាតត្រដាងទាំងនេះជារឿយៗត្រូវបានធ្វើឡើងនៅក្នុងការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំ ឬរបាយការណ៍អំពីប្រតិបត្តិការប្រហាក់ប្រហែលដែលត្រូវបានបោះផ្សាយ ជាមួយគ្នានឹង ប៉ុន្តែមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុឡើយ។ ការលាតត្រដាងទាំងនេះក៏អាចត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍លទ្ធផលនៃផែនការថវិកា ដែលត្រូវបានបោះផ្សាយដោយរដ្ឋាភិបាលដើម្បីរាយការណ៍អំពីការអនុវត្តផែនការថវិកា។ នៅពេលដែលការលាតត្រដាងទាំងនេះត្រូវបានធ្វើឡើងនៅក្នុងរបាយការណ៍ដាច់ដោយឡែកមួយក្រៅពីនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ នោះកំណត់សម្គាល់នឹងរួមបញ្ចូលនូវការផ្ទៀងផ្ទាត់ទៅនឹងរបាយការណ៍នោះ។

**មូលដ្ឋានប្រៀបធៀប**

១.៧.២៥ *គ្រប់ការប្រៀបធៀបរវាងផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែងទាំងអស់ ត្រូវដាក់បង្ហាញតាមមូលដ្ឋានប្រៀបធៀបទៅនឹងផែនការថវិកា។*

១.៧.២៦ ការប្រៀបធៀបរវាងផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែង នឹងត្រូវបានដាក់បង្ហាញលើមូលដ្ឋានគណនេយ្យដូចគ្នា (មូលដ្ឋានបង្គរ, មូលដ្ឋានសាច់ប្រាក់, ឬមូលដ្ឋានផ្សេងទៀត), មូលដ្ឋាននៃការធ្វើចំណាត់ថ្នាក់ដូចគ្នា និងសម្រាប់ស្ថាប័ននិងការិយបរិច្ឆេទដូចគ្នា ដូចគ្នាទៅនឹងផែនការថវិកាដែលបានអនុម័ត។ នេះនឹងធានាថា ការលាតត្រដាងព័ត៌មានអំពីការអនុលោមតាមផែនការថវិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺស្ថិតលើមូលដ្ឋានដូចគ្នានឹងផែនការថវិកាផ្ទាល់។ នៅក្នុងករណីមួយចំនួន វាអាចមានន័យថា ជាការដាក់បង្ហាញការប្រៀបធៀបផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែង តាមមូលដ្ឋានគណនេយ្យខុសគ្នាសម្រាប់ក្រុមសកម្មភាពផ្សេងគ្នា និងជាមួយនឹងការដាក់បង្ហាញ ឬទម្រង់នៃការធ្វើចំណាត់ថ្នាក់ខុសគ្នាពីអ្វីដែលត្រូវបានប្រើសម្រាប់របាយការណ៍ហិរញ្ញវត្ថុ។

១.៧.២៧ ដូចបានកត់សម្គាល់នៅក្នុងកថាខណ្ឌ ១.៧.១០ ផែនការថវិកាដាច់ដោយឡែកអាចនឹងត្រូវបានអនុម័ត និងធ្វើឱ្យមានជាសាធារណៈសម្រាប់ស្ថាប័នបុគ្គល ឬសកម្មភាពជាក់លាក់ដែលបង្កើតបានជាស្ថាប័នរាយការណ៍។ ប្រសិនបើវាកើតឡើង ផែនការថវិកាដាច់ដោយឡែកអាចនឹងត្រូវបានចងក្រងឡើងវិញសម្រាប់ការដាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមលក្ខខណ្ឌចាំបាច់ និងការលើកទឹកចិត្តដែលមាននៅក្នុងស្តង់ដានេះ។ នៅពេលការចងក្រងឡើងវិញបែបនេះកើតឡើង វានឹងមិនពាក់ព័ន្ធនឹងការផ្លាស់ប្តូរ ឬការកែតម្រូវចំពោះផែនការថវិកាដែលបានអនុម័តឡើយ។ នេះគឺដោយសារតែស្តង់ដានេះតម្រូវឱ្យមានការប្រៀបធៀបចំនួនទឹកប្រាក់ជាក់ស្តែង និងចំនួនទឹកប្រាក់ផែនការថវិកាដែលបានអនុម័ត។

១.៧.២៨ ស្ថាប័នអាចប្រើប្រាស់មូលដ្ឋានគណនេយ្យខុសៗគ្នាសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសម្រាប់ផែនការថវិកាដែលបានអនុម័តរបស់ខ្លួន។ ឧទាហរណ៍ នៅក្នុងករណីមួយចំនួន រដ្ឋាភិបាល ឬទីភ្នាក់ងាររបស់រដ្ឋាភិបាលមួយអាចប្រើប្រាស់មូលដ្ឋានសាច់ប្រាក់សម្រាប់របាយការណ៍ហិរញ្ញវត្ថុ និងមូលដ្ឋានបង្គរសម្រាប់ផែនការថវិការបស់ខ្លួន។ លើសពីនេះ ផែនការថវិកាអាចផ្តោតលើ ឬរួមបញ្ចូលនូវព័ត៌មានអំពីកាតព្វកិច្ចដើម្បីចំណាយមូលនិធិនាពេលអនាគតនិងការផ្លាស់ប្តូរនៅក្នុងកាតព្វកិច្ចទាំងនោះខណៈដែលរបាយការណ៍ហិរញ្ញវត្ថុនឹងរាយការណ៍អំពីចំណូល ចំណាយ និងសមតុល្យសាច់ប្រាក់។ ទោះបីជាយ៉ាងណា ស្ថាប័នថវិកានិងស្ថាប័នរាយការណ៍ហិរញ្ញវត្ថុនឹងមានលក្ខណៈដូចគ្នា។ ស្រដៀងគ្នានេះដែរ ការិយបរិច្ឆេទដែលផែនការថវិកាត្រូវបានរៀបចំនិងមូលដ្ឋាននៃការធ្វើចំណាត់ថ្នាក់ដែលត្រូវបានប្រើសម្រាប់ផែនការថវិកា នឹងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការធ្វើបែបនេះនឹងធានាថា ប្រព័ន្ធគណនេយ្យធ្វើការកត់ត្រានិងរាយការណ៍អំពីព័ត៌មានហិរញ្ញវត្ថុតាមរបៀបមួយដែលសម្របសម្រួលដល់ការប្រៀបធៀបផែនការថវិកានិងទិន្នន័យជាក់ស្តែង សម្រាប់គោលបំណងនៃការ

គ្រប់គ្រង និងគណនេយ្យភាព ឧទាហរណ៍ ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការថវិកានៅក្នុងអំឡុងការិយបរិច្ឆេទផែនការថវិកា និងដើម្បីរាយការណ៍ទៅរដ្ឋាភិបាល សាធារណជន និងអ្នកប្រើប្រាស់ផ្សេងទៀតតាមមូលដ្ឋានពាក់ព័ន្ធ និងទាន់ពេលវេលា។

១.៧.២៩ នៅក្នុងយុត្តាធិការមួយចំនួន ផែនការថវិកាអាចត្រូវបានរៀបចំតាមមូលដ្ឋានសាច់ប្រាក់ ឬមូលដ្ឋានបង្គរឱ្យមានសង្គតិភាពនឹងប្រព័ន្ធរាយការណ៍ស្ថិតិ ដែលរួមមានស្ថាប័ននិងសកម្មភាពដែលខុសគ្នាពីស្ថាប័ននិងសកម្មភាពដែលត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ឧទាហរណ៍ ផែនការថវិកាដែលត្រូវបានរៀបចំឱ្យស្របទៅតាមប្រព័ន្ធរាយការណ៍ស្ថិតិ អាចផ្តោតលើវិស័យរដ្ឋាភិបាលទូទៅ និងរួមមានតែស្ថាប័នដែលបំពេញបានតាមមុខងារ "សំខាន់" ឬ "មិនមែនទីផ្សារ" របស់រដ្ឋាភិបាលថាជាសកម្មភាពចម្បងរបស់ពួកគេប៉ុណ្ណោះ ខណៈដែលរបាយការណ៍ហិរញ្ញវត្ថុរាយការណ៍អំពីសកម្មភាពទាំងអស់ដែលគ្រប់គ្រងដោយរដ្ឋាភិបាល រួមបញ្ចូលទាំងសកម្មភាពអាជីវកម្មរបស់រដ្ឋាភិបាលផងដែរ។

១.៧.៣០ នៅក្នុងគំរូរាយការណ៍ស្ថិតិ វិស័យរដ្ឋាភិបាលទូទៅអាចមានកម្រិតរដ្ឋាភិបាលថ្នាក់ជាតិ, ថ្នាក់ក្រុង/ខេត្ត និងថ្នាក់មូលដ្ឋាន។ នៅក្នុងយុត្តាធិការមួយចំនួន រដ្ឋាភិបាលថ្នាក់ជាតិអាចគ្រប់គ្រងរដ្ឋាភិបាលថ្នាក់ក្រុង/ថ្នាក់ខេត្ត និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន, រួមបញ្ចូលរដ្ឋាភិបាលទាំងនោះទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន និងអភិវឌ្ឍ ហើយតម្រូវឱ្យមានជាសាធារណៈនូវផែនការថវិកាដែលបានអនុម័តដែលរួមមានកម្រិតរដ្ឋាភិបាលទាំងបី។ នៅក្នុងករណីទាំងនេះ លក្ខខណ្ឌចាំបាច់នៃស្តង់ដានេះនឹងត្រូវអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិទាំងនោះ។ ទោះបីជាយ៉ាងណានៅពេលដែលរដ្ឋាភិបាលថ្នាក់ជាតិមួយមិនបានគ្រប់គ្រងរដ្ឋាភិបាលថ្នាក់ក្រុង ឬថ្នាក់មូលដ្ឋានទេនោះរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាលថ្នាក់ជាតិនឹងមិនរួមបញ្ចូលនូវរដ្ឋាភិបាលថ្នាក់ក្រុង ឬថ្នាក់ខេត្ត ឬថ្នាក់មូលដ្ឋានដែលខ្លួនមិនបានគ្រប់គ្រងឡើយ។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកអាចនឹងត្រូវបានរៀបចំសម្រាប់កម្រិតរដ្ឋាភិបាលនីមួយៗ។ លក្ខខណ្ឌចាំបាច់នៃស្តង់ដានេះនឹងអនុវត្តចំពោះតែរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នរដ្ឋាភិបាលប៉ុណ្ណោះ នៅពេលដែលផែនការថវិកាដែលបានអនុម័តសម្រាប់ស្ថាប័ននិងសកម្មភាពដែលពួកគេគ្រប់គ្រង ឬផ្នែករងត្រូវបានធ្វើឱ្យមានជាសាធារណៈ។

**ផែនការថវិកាច្រើនឆ្នាំ**

១.៧.៣១ រដ្ឋាភិបាលមួយចំនួន និងស្ថាប័នដទៃទៀតបានអនុម័ត និងធ្វើឱ្យមានជាសាធារណៈនូវផែនការថវិកាច្រើនឆ្នាំ ជាជាងបែងចែកផែនការថវិកាប្រចាំឆ្នាំដាច់ដោយឡែក។ តាមទំលាប់ ផែនការថវិកាច្រើនឆ្នាំរួមមានស៊េរីនៃផែនការថវិកាប្រចាំឆ្នាំ ឬគោលដៅផែនការថវិកាប្រចាំឆ្នាំ។ ផែនការថវិកាដែលបានអនុម័តសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំនៃសមាសធាតុនីមួយៗ ឆ្លុះបញ្ចាំងឱ្យឃើញពីការអនុវត្តគោលនយោបាយផែនការថវិកាដែលជាប់ទាក់ទងនឹងផែនការថវិកាច្រើនឆ្នាំ សម្រាប់ការិយបរិច្ឆេទនៃសមាសធាតុនោះ។ នៅក្នុង

ករណីមួយចំនួន ផែនការថវិកាច្រើនឆ្នាំបានផ្តល់នូវការរំកិលនៃវិភាជន៍ថវិកាដែលមិនបានប្រើនៅក្នុងឆ្នាំទៅលណាមួយ។

១.៧.៣២ រដ្ឋាភិបាលនិងស្ថាប័នដទៃដែលមានផែនការថវិកាច្រើនឆ្នាំ អាចប្រើវិធីសាស្ត្រផ្សេងៗពីគ្នាដើម្បីកំណត់ផែនការថវិកាដើមនិងផែនការថវិកាចុងក្រោយរបស់ពួកគេ អាស្រ័យលើរបៀបដែលផែនការថវិការបស់ពួកគេត្រូវបានអនុម័ត។ ឧទាហរណ៍ រដ្ឋាភិបាលមួយអាចអនុម័តផែនការថវិកាពីរឆ្នាំម្តងដែលមានផែនការថវិកាប្រចាំឆ្នាំដែលបានអនុម័តចំនួនពីរ ដែលក្នុងករណីដែលផែនការថវិកាដែលបានអនុម័តដើម និងផែនការថវិកាចុងក្រោយសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំនីមួយៗនឹងត្រូវបានកំណត់អត្តសញ្ញាណ។ ប្រសិនបើផែនការថវិកាដែលមិនបានប្រើចាប់ពីឆ្នាំទីមួយនៃផែនការថវិកាពីរឆ្នាំម្តង ត្រូវបានអនុញ្ញាតស្របច្បាប់សម្រាប់ការចំណាយក្នុងឆ្នាំទីពីរ នោះផែនការថវិកា "ដើម" សម្រាប់ឆ្នាំទីពីរ នឹងត្រូវបានបង្កើនសម្រាប់ចំនួនទឹកប្រាក់ដែលលើកបន្តទាំងនេះ ”។ នៅក្នុងករណីកម្រដែលរដ្ឋាភិបាលមួយអនុម័តផែនការថវិកាពីរឆ្នាំម្តង រឺច្រើនឆ្នាំ ដែលមិនបានបែងចែកចំនួនផែនការថវិកាទៅក្នុងការិយបរិច្ឆេទប្រចាំឆ្នាំនីមួយៗ នោះការវិនិច្ឆ័យអាចត្រូវការចាំបាច់ក្នុងការកំណត់ពីចំនួនទឹកប្រាក់ដែលអាចរួមបញ្ចូលទៅក្នុងការិយបរិច្ឆេទប្រចាំឆ្នាំនីមួយៗដើម្បីកំណត់ផែនការថវិកាប្រចាំឆ្នាំ សម្រាប់គោលបំណងនៃស្តង់ដានេះ។ ឧទាហរណ៍ ផែនការថវិកាដែលបានអនុម័តដើមនិងចុងក្រោយសម្រាប់ឆ្នាំទីមួយសម្រាប់ការិយ-បរិច្ឆេទពីរឆ្នាំម្តង នឹងរួមបញ្ចូលនូវការទិញមូលធនដែលបានអនុម័តណាមួយសម្រាប់ការិយបរិច្ឆេទពីរឆ្នាំម្តងដែលបានកើតឡើងនៅក្នុងអំឡុងពេលឆ្នាំទីមួយ ជាមួយគ្នានឹងចំនួនទឹកប្រាក់ចំណូលនិងចំណាយដែលកើតឡើងក្នុងឆ្នាំនោះ។ ចំនួនទឹកប្រាក់ដែលមិនទាន់បានចំណាយដែលនៅសល់ពីការិយបរិច្ឆេទប្រចាំឆ្នាំទីមួយ នឹងត្រូវដាក់បញ្ចូលនៅក្នុងផែនការថវិកាដើមសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំទីពីរ ហើយថវិកានោះ ជាមួយគ្នានឹងការកែប្រែណាមួយ នឹងបង្កើតជាផែនការថវិកាចុងក្រោយសម្រាប់ឆ្នាំទីពីរ។ ផ្នែកទី ២ នៃស្តង់ដានេះលើកទឹកចិត្តឱ្យមានការលាតត្រដាងអំពីទំនាក់ទំនងរវាងផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែងនៅក្នុងអំឡុងការិយបរិច្ឆេទផែនការថវិកា។

**ការលាតត្រដាងកំណត់សម្គាល់នៃមូលដ្ឋានថវិកា, ការិយបរិច្ឆេទ និងវិសាលភាព**

១.៧.៣៣ *ស្ថាប័នមួយត្រូវពន្យល់នៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុនូវមូលដ្ឋានផែនការថវិកា និងមូលដ្ឋាននៃការធ្វើចំណាត់ថ្នាក់ដែលត្រូវបានប្រើនៅក្នុងផែនការថវិកាដែលបានអនុម័ត។*

១.៧.៣៤ វាអាចមានភាពខុសគ្នារវាងមូលដ្ឋានគណនេយ្យ (សាច់ប្រាក់, បង្គរ ឬការកែសម្រួលមួយចំនួន) ដែលត្រូវបានប្រើក្នុងការរៀបចំនិងការដាក់បង្ហាញផែនការថវិកា និងមូលដ្ឋានគណនេយ្យដែលត្រូវបានប្រើនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ភាពខុសគ្នាទាំងនេះអាចកើតឡើងនៅពេលដែលប្រព័ន្ធគណនេយ្យនិងប្រព័ន្ធថវិកាធ្វើការចងក្រងព័ត៌មានពីទស្សនវិស័យផ្សេងគ្នា - ថវិកាអាចផ្តោតលើលំហូរសាច់ប្រាក់ ឬក រួមនឹងការបង្គរ និងកាតព្វកិច្ចជាក់លាក់មួយចំនួន ខណៈដែលរបាយការណ៍ហិរញ្ញវត្ថុធ្វើការរាយការណ៍អំពីចំណូលសាច់ប្រាក់ និងចំណាយសាច់ប្រាក់។

១.៧.៣៥ ទម្រង់ និងចំណាត់ថ្នាក់ដែលត្រូវបានប្រើសម្រាប់ការដាក់បង្ហាញផែនការថវិកាដែលបានអនុម័ត ក៏អាចមានភាពខុសគ្នាពីទម្រង់ដែលត្រូវបានប្រើសម្រាប់របាយការណ៍ហិរញ្ញវត្ថុផងដែរ។ ផែនការថវិកាដែលបានអនុម័តអាចធ្វើការចាត់ថ្នាក់គណនីតាមមូលដ្ឋានដូចគ្នា ដូចត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឧទាហរណ៍ ការចំណាយតាមចរិកលក្ខណៈសេដ្ឋកិច្ច (សំណងនិយោជិក, សម្ភារៈ និងគ្រឿងប្រើប្រាស់, ជំនួយឥតសំណង និងការផ្ទេរ ជាដើម) ឬមុខងារ (សុខភាព, ការអប់រំ, ជាដើម)។ ជាជម្រើសបន្ថែម ផែនការថវិកាអាចធ្វើការចាត់ថ្នាក់គណនីតាមកម្មវិធីជាក់លាក់ (ឧទាហរណ៍ ការកាត់បន្ថយភាពក្រីក្រឬការត្រួតពិនិត្យជម្ងឺឆ្លង) ឬសមាសធាតុនៃកម្មវិធីដែលភ្ជាប់ទៅនឹងគោលបំណងលទ្ធផលប្រតិបត្តិការ (ឧទាហរណ៍ សិស្សដែលបានបញ្ចប់ការអប់រំថ្នាក់ឧត្តមសិក្សា ឬប្រតិបត្តិការវះកាត់ដែលធ្វើឡើងដោយសេវាសង្គ្រោះបន្ទាន់របស់មន្ទីរពេទ្យ) ដែលខុសគ្នាពីចំណាត់ថ្នាក់ដែលត្រូវបានប្រើប្រាស់នៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុ។ លើសពីនេះទៀត ផែនការថវិកាចរន្តសម្រាប់ប្រតិបត្តិការដែលកំពុងដំណើរការ (ឧទាហរណ៍ ការអប់រំ ឬសុខភាព) អាចត្រូវបានអនុម័តដាច់ដោយឡែកពីផែនការថវិកាចំណាយមូលធន (ឧទាហរណ៍ ហេដ្ឋារចនាសម្ព័ន្ធ ឬអគារ)។

១.៧.៣៦ ការលាតត្រដាងពីមូលដ្ឋាននៃការរៀបចំថវិកា និងមូលដ្ឋាននៃការធ្វើចំណាត់ថ្នាក់ដែលត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំនិងការដាក់បង្ហាញផែនការថវិកាដែលបានអនុម័ត នឹងជួយឱ្យអ្នកប្រើប្រាស់យល់បានកាន់តែច្បាស់អំពីទំនាក់ទំនងរវាងផែនការថវិកា និងព័ត៌មានគណនេយ្យដែលត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

១.៧.៣៧ ***ស្ថាប័នមួយ ត្រូវលាតត្រដាងនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ នូវការិយបរិច្ឆេទនៃផែនការថវិកាដែលបានអនុម័ត។***

១.៧.៣៨ របាយការណ៍ហិរញ្ញវត្ថុត្រូវបានដាក់បង្ហាញយ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ។ ស្ថាប័នអាចអនុម័តផែនការថវិកាសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ឬសម្រាប់ការិយបរិច្ឆេទច្រើនឆ្នាំ។ ការលាតត្រដាងអំពីការិយបរិច្ឆេទដែលត្រូវបានគ្របដណ្តប់ដោយផែនការថវិកាដែលបានអនុម័ត នៅពេលការិយបរិច្ឆេទនោះខុសគ្នាពីការិយបរិច្ឆេទរាយការណ៍ដែលត្រូវបានប្រើប្រាស់សម្រាប់របាយការណ៍ហិរញ្ញវត្ថុ នឹងជួយឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនោះ យល់បានកាន់តែច្បាស់អំពីទំនាក់ទំនងរវាងទិន្នន័យផែនការថវិកា និងការប្រៀបធៀបផែនការថវិកាទៅនឹងរបាយការណ៍ហិរញ្ញវត្ថុ។ ការលាតត្រដាងអំពីការិយបរិច្ឆេទដែលត្រូវបានគ្របដណ្តប់ដោយផែនការថវិកាដែលបានអនុម័ត នៅពេលការិយបរិច្ឆេទនោះដូចគ្នាទៅនឹងការិយបរិច្ឆេទដែលត្រូវបានគ្រប់ដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុ ក៏នឹងដើរតួនាទីបញ្ជាក់ដ៏សំខាន់មួយ ជាពិសេសនៅក្នុងយុត្តាធិការដែលផែនការថវិកាបណ្តោះអាសន្ននិងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ ក៏ត្រូវបានរៀបចំឡើងផងដែរ។

១.៧.៣៩ ***ស្ថាប័នមួយ នឹងកំណត់នៅក្នុងកំណត់សម្គាល់លើរបាយការណ៍ នូវស្ថាប័នដែលត្រូវបានរួមបញ្ចូលនៅក្នុងផែនការថវិកាដែលបានអនុម័ត។***

១.៧.៤០ កថាខណ្ឌ ២.១.៣៧ នៃ ផ្នែកទី ២ នៃស្តង់ដានេះលើកទឹកចិត្តឱ្យស្ថាប័នគ្រប់គ្រងធ្វើការរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ដែលរួមមាន ស្ថាប័នដែលពឹងផ្អែកលើផែនការថវិកា និងស្ថាប័នសាធារណៈពាណិជ្ជកម្មដែលត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាល។ ទោះបីជាយ៉ាងណាក៏ដោយ ដូចបានកត់សម្គាល់នៅក្នុង កថាខណ្ឌ ១.៧.២៩ ផែនការថវិកាដែលបានអនុម័តដែលត្រូវបានរៀបចំដោយអនុលោមតាមគំរូរាយការណ៍ស្ថិតិ មិនអាចរួមមានប្រតិបត្តិការរបស់រដ្ឋាភិបាលដែលបានអនុវត្តតាមមូលដ្ឋានពាណិជ្ជកម្ម ឬមូលដ្ឋានទីផ្សារនោះទេ។ ដោយមានសង្គតិភាពជាមួយនឹងលក្ខខណ្ឌចាំបាច់នៃកថាខណ្ឌ ១.៧.២៥ ផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែងនឹងត្រូវបានដាក់បង្ហាញតាមមូលដ្ឋានប្រៀបធៀប។ ការលាតត្រដាងអំពីស្ថាប័នដែលបានគ្របដណ្តប់ដោយផែនការថវិកា នឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកំណត់ពីវិសាលភាពដែលសកម្មភាពរបស់ស្ថាប័នត្រូវពឹងផ្អែកលើផែនការថវិកាដែលបានអនុម័ត និងរបៀបដែលស្ថាប័នថវិកាមានភាពខុសគ្នាពីស្ថាប័នដូចបានឆ្លុះបញ្ចាំងក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**ការផ្ទៀងផ្ទាត់ចំនួនទឹកប្រាក់ជាក់ស្តែងតាមមូលដ្ឋានប្រៀបធៀប និងចំនួនទឹកប្រាក់ជាក់ស្តែងក្នុងរបាយការណ៍ហិរញ្ញវត្ថុ**

១.៧.៤១ *ចំនួនទឹកប្រាក់ជាក់ស្តែងដែលបានដាក់បង្ហាញតាមមូលដ្ឋានប្រៀបធៀបទៅនឹងផែនការថវិកា ដោយអនុលោមតាមកថាខណ្ឌ ១.៧.២៥ នៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុនិងផែនការថវិកាមិនត្រូវបានរៀបចំឡើងតាមមូលដ្ឋានប្រៀបធៀប ត្រូវផ្ទៀងផ្ទាត់ជាមួយនឹងចំណូលសាច់ប្រាក់សុរប និងចំណាយសាច់ប្រាក់សុរបដែលកំណត់ដាច់ដោយឡែកពីភាពខុសគ្នានៃមូលដ្ឋាន ពេលវេលា និងស្ថាប័ន។ ការផ្ទៀងផ្ទាត់ ត្រូវបានលាតត្រដាងនៅលើរបាយការណ៍ប្រៀបធៀបរវាងផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែង ឬនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។*

១.៧.៤២ ភាពខុសគ្នារវាងចំនួនទឹកប្រាក់ជាក់ស្តែង ដូចបានកំណត់ស្របជាមួយនឹងមូលដ្ឋានប្រៀបធៀប និងចំនួនទឹកប្រាក់ជាក់ស្តែងដូចបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ អាចត្រូវបានចាត់ថ្នាក់ទៅក្នុង÷

(ក) ភាពខុសគ្នានៃមូលដ្ឋានផែនការថវិកាដែលកើតឡើង នៅពេលផែនការថវិកាដែលបានអនុម័តត្រូវបានរៀបចំតាមមូលដ្ឋានផ្សេងពីមូលដ្ឋានគណនេយ្យ។ ឧទាហរណ៍ នៅពេលដែលផែនការថវិកាត្រូវបានរៀបចំតាមមូលដ្ឋានបង្គរ ឬមូលដ្ឋានសាច់ប្រាក់កែសម្រួល ហើយរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំតាមមូលដ្ឋានសាច់ប្រាក់

(ខ) ភាពខុសគ្នានៃពេលវេលាដែលកើតឡើងនៅពេលដែលការិយបរិច្ឆេទផែនការថវិកា ខុសគ្នាពីការិយបរិច្ឆេទរាយការណ៍ដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) ភាពខុសគ្នានៃស្ថាប័នដែលកើតឡើងនៅពេលដែលផែនការថវិកាលុបបំបាត់កម្មវិធី ឬស្ថាប័ននានាដែលជាផ្នែករបស់ស្ថាប័ន ដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំសម្រាប់ស្ថាប័ននោះ។

វាក៏អាចមានភាពខុសគ្នាលើទម្រង់ និងគ្រោងការណ៍នៃការធ្វើចំណាត់ថ្នាក់ដែលបានប្រើសម្រាប់ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងផែនការថវិកាផងដែរ។

១.៧.៤៣ ការផ្ទៀងផ្ទាត់ដែលត្រូវបានតម្រូវដោយកថាខណ្ឌ ១.៧.៤១ នៃស្តង់ដានេះ នឹងអនុញ្ញាតឱ្យស្ថាប័នអាចអនុវត្តបានកាន់តែប្រសើរ នូវកាតព្វកិច្ចគណនេយ្យភាពរបស់ខ្លួន តាមរយៈការកំណត់ពីប្រភពចម្បងនៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ជាក់ស្តែងតាមមូលដ្ឋានផែនការថវិកា និងចំណូលសាច់ប្រាក់សរុប និងចំណាយសាច់ប្រាក់សរុបដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់។ ស្តង់ដានេះមិនរារាំងដល់ការផ្ទៀងផ្ទាត់រវាងចំនួនទឹកប្រាក់សរុបនិងចំនួនទឹកប្រាក់សរុបរង ឬក៏ថ្នាក់គណនីនីមួយៗដែលបានដាក់បង្ហាញនៅក្នុងការប្រៀបធៀបផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែងជាមួយនឹងចំនួនសមមូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

១.៧.៤៤ សម្រាប់ស្ថាប័នដែលប្រើប្រាស់មូលដ្ឋានគណនេយ្យសាច់ប្រាក់ សម្រាប់ការដាក់បង្ហាញឯកសារថវិកា និងរបាយការណ៍ហិរញ្ញវត្ថុ ការផ្ទៀងផ្ទាត់នឹងមិនត្រូវបានតម្រូវឡើយ នៅពេលដែលថវិកាត្រូវបានរៀបចំសម្រាប់ការិយបរិច្ឆេទដូចគ្នា, រួមមាន ស្ថាប័នដូចគ្នា, និងប្រើប្រាស់ទម្រង់នៃការដាក់បង្ហាញដូចគ្នាទៅនឹងរបាយការណ៍ហិរញ្ញវត្ថុ។ ចំពោះស្ថាប័នផ្សេងទៀតដែលប្រើមូលដ្ឋានគណនេយ្យតែមួយសម្រាប់ផែនការថវិកានិងរបាយការណ៍ហិរញ្ញវត្ថុ វាអាចមានភាពខុសគ្នាលើទម្រង់នៃការដាក់បង្ហាញ, ស្ថាប័នរាយការណ៍ ឬការិយបរិច្ឆេទរបាយការណ៍ - ឧទាហរណ៍ ផែនការថវិកាដែលបានអនុម័តអាចប្រើទម្រង់ចំណាត់ថ្នាក់ ឬទម្រង់នៃការដាក់បង្ហាញផ្សេងគ្នាចំពោះរបាយការណ៍ហិរញ្ញវត្ថុ អាចរួមបញ្ចូលតែសកម្មភាពមិនមែនពាណិជ្ជកម្មរបស់ស្ថាប័ន ឬអាចជាផែនការថវិកាច្រើនឆ្នាំប៉ុណ្ណោះ។ ការផ្ទៀងផ្ទាត់អាចចាំបាច់នៅពេលដែលមានភាពខុសគ្នានៃការដាក់បង្ហាញ, ពេលវេលា ឬស្ថាប័ន រវាងផែនការថវិកានិងរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានរៀបចំឡើងតាមមូលដ្ឋានគណនេយ្យដូចគ្នា។

១.៧.៤៥ *ការលាតត្រដាងអំពីព័ត៌មានប្រៀបធៀបនៅក្នុងការិយបរិច្ឆេទមុន ដោយអនុលោមទៅតាមលក្ខខណ្ឌចាំបាច់នៃស្តង់ដានេះ មិនត្រូវបានតម្រូវឡើយ។*

១.៧.៤៦ ស្តង់ដានេះ តម្រូវឱ្យការប្រៀបធៀបផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែងត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នដែលធ្វើឱ្យផែនការថវិកាដែលបានអនុម័តជាសាធារណៈ មានជាសាធារណៈ។ ស្តង់ដានេះមិនបានតម្រូវឱ្យមានការលាតត្រដាងអំពីការប្រៀបធៀបចំនួនទឹកប្រាក់ជាក់ស្តែងនៃការិយបរិច្ឆេទមុន ជាមួយនឹងផែនការថវិកានៃការិយបរិច្ឆេទមុននោះទេ ហើយក៏មិនតម្រូវថា ការបកស្រាយអំពីភាពខុសគ្នារវាងចំនួនទឹកប្រាក់ជាក់ស្តែង និងផែនការថវិកានៃការិយបរិច្ឆេទមុននោះត្រូវលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទបច្ចុប្បន្ននោះដែរ។

**ការបង្ហាញអំពីលក្ខខណ្ឌចាំបាច់នៃផ្នែកទី ១ នៃស្តង់ដា**

*ឧបសម្ព័ន្ធនេះគឺសម្រាប់តែការបង្ហាញប៉ុណ្ណោះ ហើយវាមិនបានបង្កើតជាផ្នែកមួយនៃស្តង់ដានោះទេ។ គោលបំណង របស់វា គឺជួយក្នុងការបញ្ជាក់ឱ្យបានកាន់តែច្បាស់អំពីអត្ថន័យនៃលក្ខខណ្ឌចាំបាច់នៃផ្នែកទី ១ នៃស្តង់ដានេះ ដោយបង្ហាញពីការអនុវត្តលក្ខខណ្ឌចាំបាច់ទាំងនោះក្នុងការរៀបចំ និងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ គោលបំណងទូទៅ តាមមូលដ្ឋានគណនេយ្យសាច់ប្រាក់ សម្រាប់៖*

*ក) **របាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាលថ្នាក់ជាតិ “ក”***

*ខ) **របាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នរដ្ឋាភិបាល“ខ”** ដែលគ្រប់គ្រងគណនីធនាគាររបស់ខ្លួនផ្ទាល់ និង*

*គ) **របាយការណ៍ហិរញ្ញវត្ថុរបស់នាយកដ្ឋានរដ្ឋាភិបាល “គ”** ដែលចំណូលនិងចំណាយសាច់ប្រាក់ របស់នាយកដ្ឋាននោះ ត្រូវបានគ្រប់គ្រងតាមរយៈមុខងារធនាគារមជ្ឈការ ដែលតែងតែត្រូវបាន គេសំដៅដល់ “គណនីទោលរតនាគារ ”។*

**ឧបសម្ព័ន្ធ ១ក - រដ្ឋាភិបាល "ក"**

**របាយការណ៍ហិរញ្ញវត្ថុសម្រាប់រដ្ឋាភិបាលថ្នាក់ជាតិ "ក"**

របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០X

(ចំណូលតែប៉ុណ្ណោះ)

| | កំណត់សម្គាល់ | ២០០X | | ២០០X-១ | |
|---|---|---|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | | ចំណូល/(ចំណាយ) | | ចំណូល/(ចំណាយ) | |
| ចំណូល | | | | | |
| *ពន្ធ* | | | | | |
| ពន្ធលើប្រាក់ចំណូល | | X | | X | |
| អាករលើតម្លៃបន្ថែម | | X | | X | |
| ពន្ធលើអចលនទ្រព្យ | | X | | X | |
| ពន្ធផ្សេងៗ | | X | | X | |
| | | | X | | X |
| *ការបរិច្ចាគ អំណោយ និងជំនួយផ្សេងទៀត* | ១០ | | X | | X |
| *កម្ចី* | ៣ | | | | |
| ចំណូលពី÷ | | | | | |
| ស្ថាប័នពាណិជ្ជកម្ម | | | X | | |
| ធនាគារអភិវឌ្ឍន៍ និងអង្គការប្រហាក់ប្រហែល | | | X | | |
| *ចំណូលមូលធន* | | | | | |
| ចំណូលពីការលក់រោងចក្រនិងបរិក្ខារ | | X | | X | |
| ចំណូលពីការលក់ឧបករណ៍ហិរញ្ញវត្ថុ | | X | | X | |
| | | | X | | X |
| *សកម្មភាពជួញដូរ* | | | | | |
| ចំណូលពីសកម្មភាពជួញដូរ | | | X | | X |
| *ចំណូលផ្សេងៗ* | ៤ | | X | | X |
| ចំណូលសរុប | | | X | | X |

ឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ ៥៤៥ សហវ-ប្រក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៩

| | កំណត់សម្គាល់ | ២០០X | | ២០០X-១ | |
|---|---|---|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | | ចំណូល/(ចំណាយ) | | ចំណូល/(ចំណាយ) | |
| ចំណាយ | | | | | |
| *ប្រតិបត្តិការ* | | | | | |
| ប្រាក់ឈ្នួល ប្រាក់ខែ និងអត្ថប្រយោជន៍និយោជិក | | (X) | | (X) | |
| សម្ភារៈ និងគ្រឿងប្រើប្រាស់ | | (X) | | (X) | |
| | | | (X) | | (X) |
| *ការផ្ទេរ* | | | | | |
| អំណោយ | | (X) | | (X) | |
| ការផ្ទេរកញ្ចប់ចំណាយផ្សេងៗ | | (X) | | (X) | |
| | | | (X) | | (X) |
| *ចំណាយមូលធន* | | | | | |
| ការទិញ/ការសាងសង់រោងចក្រ និងបរិក្ខារ | | (X) | | (X) | |
| ការទិញឧបករណ៍ហិរញ្ញវត្ថុ | | (X) | | (X) | |
| | | | (X) | | (X) |
| *ការទូទាត់សងឥណទាន និងការប្រាក់* | | | | | |
| ការទូទាត់សងកម្ចី | | (X) | | (X) | |
| ការទូទាត់ការប្រាក់ | | (X) | | (X) | |
| | | | (X) | | (X) |
| *ចំណាយផ្សេងៗ* | ៥ | | (X) | | (X) |
| ចំណាយសរុប | | | (X) | | (X) |
| ការកើនឡើង /(ការថយចុះ) នៃសាច់ប្រាក់ | | | X | | X |
| សាច់ប្រាក់ដើមគ្រា | ២ | | X | | X |
| ការកើនឡើង /(ការថយចុះ) នៃសាច់ប្រាក់ | | | X | | X |
| សាច់ប្រាក់ចុងគ្រា | ២ | | X | | X |

**របាយការណ៍ប្រៀបធៀបរវាងផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង**

សម្រាប់រដ្ឋាភិបាល "ក" សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០X

ផែនការថវិកាដែលបានអនុម័តតាមមូលដ្ឋានសាច់ប្រាក់

(ការធ្វើចំណាត់ថ្នាក់ចំណាយតាមមុខងារ)

| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ចំនួនទឹកប្រាក់ជាក់ស្តែង | ផែនការថវិកាចុងក្រោយ | ផែនការថវិកាដើម | *ភាពខុសគ្នា<br>*ផែនការថវិកាចុងក្រោយ និងចំនួនទឹកប្រាក់ជាក់ស្តែង* |
|---|---|---|---|---|
| លំហូរចូលនៃសាច់ប្រាក់ | | | | |
| ពន្ធ | X | X | X | X |
| អំណោយ និងកិច្ចព្រមព្រៀងផ្តល់ជំនួយ | X | X | X | X |
| ចំណូលពី ÷ កម្ចី | X | X | X | X |
| ចំណូលពី ÷ ការលក់រោងចក្រ និងបរិក្ខារ | X | X | X | X |
| ចំណូលពី ÷ ការលក់ឧបករណ៍ហិរញ្ញវត្ថុ | X | X | X | X |
| សកម្មភាពជួញដូរ | X | X | X | X |
| ចំណូលផ្សេងៗ | X | X | X | X |
| ចំណូលសរុប | X | X | X | X |
| **លំហូរចេញនៃសាច់ប្រាក់** | | | | |
| សុខាភិបាល | (X) | (X) | (X) | (X) |
| ការអប់រំ | (X) | (X) | (X) | (X) |
| សណ្តាប់ធ្នាប់/ សុវត្ថិភាពសាធារណៈ | (X) | (X) | (X) | (X) |
| ការគាំពារផ្នែកសង្គម | (X) | (X) | (X) | (X) |
| ការការពារជាតិ | (X) | (X) | (X) | (X) |
| លំនៅស្ថាន និងសហគមន៍ | (X) | (X) | (X) | (X) |
| ការកំសាន្ត វប្បធម៌ និងសាសនា | (X) | (X) | (X) | (X) |
| កិច្ចការផ្នែកសេដ្ឋកិច្ច | (X) | (X) | (X) | (X) |
| ការការពារបរិស្ថាន | (X) | (X) | (X) | (X) |
| សេវាសាធារណៈទូទៅ | (X) | (X) | (X) | (X) |
| ចំណាយសរុប | (X) | (X) | (X) | (X) |
| **លំហូរសាច់ប្រាក់សុទ្ធ** | X | X | X | X |

*តារាងជួរឈរនៃ "ភាពខុសគ្នា..." មិនត្រូវបានតម្រូវនោះទេ។ ទោះបីជាយ៉ាងណា ការប្រៀបធៀបរវាងចំនួនទឹកប្រាក់ជាក់ស្តែង និងផែនការថវិកាដំបូង ឬផែនការថវិកាចុងក្រោយ ដូចបានកំណត់យ៉ាងច្បាស់លាស់តាមការគួរ អាចត្រូវបានរួមបញ្ចូល។

**របាយការណ៍ហិរញ្ញវត្ថុបន្ថែម (ជម្រើសបន្ថែម)**

របាយការណ៍ហិរញ្ញវត្ថុបន្ថែម អាចត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវព័ត៌មានលម្អិតអំពីចំនួនទឹកប្រាក់ ដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ឧទាហរណ៍ ដើម្បីលាតត្រដាងព័ត៌មានតាមក្រុមមូលនិធិសំខាន់ៗ ឬដើម្បីលាតត្រដាងអំពីការចំណាយតាមមុខងារ ឬកម្មវិធីសំខាន់ៗ ឬដើម្បីផ្តល់នូវព័ត៌មានលម្អិតអំពីប្រភពនៃកម្ចី។ តារាងជួរឈរដែលលាតត្រដាងអំពីចំនួនទឹកប្រាក់ផែនការថវិកា ក៏អាចត្រូវបានរួមបញ្ចូលផងដែរ។

**របាយការណ៍ចំណូលសាច់ប្រាក់ តាមការធ្វើចំណាត់ថ្នាក់មូលនិធិ**

| | ២០០X | ២០០X-១ |
|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ចំណូល | ចំណូល |
| ចំណូល | | |
| មូលនិធិរួម | X | X |
| មូលនិធិពិសេស | X | X |
| មូលនិធិជួញដូរ | X | X |
| ឥណទាន | X | X |
| ចំណូលសរុប | X | X |

**ចំណូលពីកម្ចី**

| | កំណត់សម្គាល់ | ២០០X | ២០០X-១ |
|---|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | | ចំណូលសាច់ប្រាក់ | ចំណូលសាច់ប្រាក់ |
| កម្ចី | | | |
| ស្ថាប័នពាណិជ្ជកម្មក្នុងស្រុក | | X | X |
| ស្ថាប័នពាណិជ្ជកម្មក្រៅប្រទេស | | X | X |
| ធនាគារអភិវឌ្ឍន៍ និងភ្នាក់ងារ ផ្តល់កម្ចីប្រហាក់ប្រហែល | | X | X |
| កម្ចីសរុប | ៣ | X | X |

## របាយការណ៍ចំណាយតាមកម្មវិធី /សកម្មភាព /មុខងាររបស់រដ្ឋាភិបាល

| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ២០០X<br>ចំណាយ | ២០០X-១<br>ចំណាយ |
|---|---|---|
| **ចំណាយ - គណនីប្រតិបត្តិការ** | X | X |
| ការអប់រំ | X | X |
| សុខាភិបាល | X | X |
| ការគាំពារផ្នែកសង្គម | X | X |
| ការការពារជាតិ | X | X |
| សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ | X | X |
| ការកំសាន្ត វប្បធម៌ និងសាសនា | X | X |
| កិច្ចការផ្នែកសេដ្ឋកិច្ច | X | X |
| ការការពារបរិស្ថាន | X | X |
| សេវាសាធារណៈទូទៅ | X | X |
| **ចំណាយសរុប** | X | X |
| **ចំណាយ - គណនីមូលធន** | | |
| ការអប់រំ | X | X |
| សុខាភិបាល | X | X |
| ការគាំពារផ្នែកសង្គម និងសុខុមាលភាព | X | X |
| ការការពារជាតិ | X | X |
| សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ | X | X |
| ការកំសាន្ត វប្បធម៌ និងសាសនា | X | X |
| ការការពារបរិស្ថាន | X | X |
| សេវាសាធារណៈទូទៅ | X | X |
| **ចំណាយសរុប** | X | X |
| **គណនីប្រតិបត្តិការ និងគណនីមូលធនសរុប** | X | X |

**ស្ថាប័នសាធារណៈ - រដ្ឋាភិបាល "ក" ឆាំខមូល**

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

**១. គោលនយោបាយគណនេយ្យ**

**មូលដ្ឋាននៃការរៀបចំ**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់, *ការរាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់*។

គោលនយោបាយគណនេយ្យត្រូវបានអនុវត្តប្រកបដោយសង្គតិភាពពេញមួយការិយបរិច្ឆេទ។

**ស្ថាប័នរាយការណ៍**

របាយការណ៍ហិរញ្ញវត្ថុ គឺសម្រាប់រដ្ឋាភិបាលនៃប្រទេស "ក"។ របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលនូវស្ថាប័នរាយការណ៍ដូចបានបញ្ជាក់នៅក្នុងច្បាប់ពាក់ព័ន្ធ (ច្បាប់ហិរញ្ញវត្ថុសាធារណៈ ២០XX) ។

សកម្មភាពរបស់រដ្ឋាភិបាលរួមមាន ការផ្តល់សេវាសុខាភិបាល, ការអប់រំ, ការគាំពារផ្នែកសង្គម, លំនៅស្ថាន, ការកំសាន្ត និងវប្បធម៌, សេវាសាធារណៈទូទៅ និងការគ្រប់គ្រងសេដ្ឋកិច្ច និងជំនួសឱ្យអង្គភាពនានា។ កំណត់ពីកម្រិតនៃរដ្ឋាភិបាល, យុត្តាធិការ និងចរិកលក្ខណៈនៃសេវាដែលបានផ្តល់។

បញ្ជីស្ថាប័នសំខាន់ៗដែលរួមមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនិងវិស័យនានាដែលស្ថាប័នធ្វើប្រតិបត្តិការ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ទី៧ លើរបាយការណ៍ហិរញ្ញវត្ថុ។

**រូបិយបណ្ណសម្រាប់បង្ហាញ**

រូបិយបណ្ណសម្រាប់បង្ហាញគឺ (រូបិយបណ្ណនៃប្រទេស "ក")។

**២. សាច់ប្រាក់**

សាច់ប្រាក់រួមមាន សាច់ប្រាក់ក្នុងដៃ, ប្រាក់បញ្ញើគ្មានកាលកំណត់ និងសាច់ប្រាក់សមមូល។ ប្រាក់បញ្ញើគ្មានកាលកំណត់ និងសាច់ប្រាក់សមមូល រួមមាន សមតុល្យធនាគារ និងការវិនិយោគលើឧបករណ៍ទីផ្សារហិរញ្ញវត្ថុរយៈពេលខ្លី។

សាច់ប្រាក់ដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ រួមមានចំនួនទឹកប្រាក់ដូចខាងក្រោម÷

| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ២00X | ២00X-១ |
|---|---|---|
| សាច់ប្រាក់ក្នុងដៃ និងសមតុល្យធនាគា | X | X |
| ការវិនិយោគរយៈពេលខ្លី | X | X |
| | X | X |

ដែលត្រូវបានរួមបញ្ចូលនៅក្នុងចំនួនទឹកប្រាក់ដូចបានបង្ហាញខាងលើ គឺជាឯកតារូបិយបណ្ណ X ដែលត្រូវបានផ្តល់ដោយភ្នាក់ងារអន្តរជាតិ XX ដែលត្រូវបានដាក់កំហិតលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។

**៣. កម្ចី**

កម្ចី រួមមាន លំហូរចូលនៃសាច់ប្រាក់ពីធនាគារពាណិជ្ជ និងស្ថាប័នពាណិជ្ជកម្មប្រហាក់ប្រហែល រួមជាមួយនឹងធនាគារអភិវឌ្ឍន៍ និងភ្នាក់ងារផ្តល់ជំនួយប្រហាក់ប្រហែល។

**៤. ចំណូលផ្សេងៗ**

ដែលត្រូវបានរួមបញ្ចូលនៅក្នុងចំណូលផ្សេងៗ គឺជាកម្រៃ, ការផាកពិន័យ និងចំណូលផ្សេងៗទៀត។

**៥. ចំណាយផ្សេងៗ**

ដែលត្រូវបានរួមបញ្ចូលនៅក្នុងចំណាយផ្សេងៗ គឺជាភាគលាភ, ការចែកចាយដែលត្រូវបានទូទាត់, ការដោះស្រាយពាក្យបណ្តឹងតាមផ្លូវច្បាប់ និងចំណាយផ្សេងៗទៀត។

**៦. ឧបករណ៍កម្ចីដែលមិនទាន់បានប្រើប្រាស់**

| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ២០0X | ២០0X-១ |
|---|---|---|
| **ចលនានៃឧបករណ៍កម្ចីដែលមិនទាន់បានប្រើប្រាស់** | | |
| ឧបករណ៍កម្ចីដែលមិនទាន់បានប្រើប្រាស់ នាថ្ងៃទី០១ ខែមករា ឆ្នាំ0X | X | X |
| ឧបករណ៍ឥណទានបន្ថែម | X | X |
| ចំនួនទឹកប្រាក់ដែលមានសម្រាប់ប្រើប្រាស់សរុប | X | X |
| ចំនួនទឹកប្រាក់ដែលបានដក | (X) | (X) |
| ការបិទ/ ការលុបចោលឧបករណ៍ | (X) | (X) |
| ឧបករណ៍កម្ចីដែលមិនទាន់បានប្រើប្រាស់ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ 0X | X | X |

| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ២០0X | ២០0X-១ |
|---|---|---|
| **ឧបករណ៍កម្ចីដែលមិនទាន់បានប្រើប្រាស់** | | |
| ស្ថាប័នហិរញ្ញវត្ថុពាណិជ្ជកម្ម | X | X |
| ធនាគារអភិវឌ្ឍន៍ និងអង្គការប្រហាក់ប្រហែល | X | X |
| ឧបករណ៍កម្ចីដែលមិនទាន់បានប្រើប្រាស់សរុប | X | X |

## ៧. ស្ថាប័នសំខាន់ៗ

| ស្ថាប័ន ២០០X | ស្ថាប័ន ២០០X-១ |
|---|---|
| ស្ថាប័ន ក | ស្ថាប័ន ក |
| ស្ថាប័ន ខ | ស្ថាប័ន ខ |
| ស្ថាប័ន គ | ស្ថាប័ន គ |
| ស្ថាប័ន ឃ | ស្ថាប័ន ឃ |

## ៨. កាលបរិច្ឆេទអនុញ្ញាតចេញផ្សាយ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យចេញផ្សាយ នាថ្ងៃទី XX ខែ XX ២០០X+១ ដោយ លោក YY, ហេរញ្ញិកនៃប្រទេស "ក"។

## ៩. ផែនការថវិកាដែលបានអនុម័តដំបូងនិងចុងក្រោយ និងការប្រៀបធៀបរវាងចំនួនទឹកប្រាក់ជាក់ស្តែង និងចំនួនទឹកប្រាក់ផែនការថវិកា

ផែនការថវិកាដែលបានអនុម័តរួច ត្រូវបានបង្កើតឡើងតាមមូលដ្ឋានគណនេយ្យដូចគ្នា (មូលដ្ឋានសាច់ប្រាក់), មូលដ្ឋាននៃការធ្វើចំណាត់ថ្នាក់ដូចគ្នា, និងសម្រាប់ការិយបរិច្ឆេទដូចគ្នា (ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០X ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០X) ទៅនឹងរបាយការណ៍ហិរញ្ញវត្ថុ។ វារួមបញ្ចូលនូវស្ថាប័នដូចគ្នាទៅនឹងរបាយការណ៍ហិរញ្ញវត្ថុរួមដូចបានកំណត់នៅក្នុងកំណត់សម្គាល់ទី ៧ ខាងលើ។

ផែនការថវិកាដើមត្រូវបានអនុម័តដោយសកម្មភាពច្បាប់នា (កាលបរិច្ឆេទ) ហើយវិភាជន៍បន្ថែមនៃ XXX សម្រាប់ការជួយសង្គ្រោះគ្រោះមហន្តរាយត្រូវបានអនុម័តដោយសកម្មភាពច្បាប់នា (កាលបរិច្ឆេទ) ដោយសារការរញ្ជួយដីនៅក្នុងតំបន់ភាគខាងជើងនា (កាលបរិច្ឆេទ) ។ គោលបំណងនិងគោលនយោបាយនៃការរៀបចំផែនការថវិកាដើម និងការកែសម្រួលឡើងវិញជាបន្តបន្ទាប់ ត្រូវបានពន្យល់យ៉ាងពេញលេញនៅក្នុងរបាយការណ៍ត្រួតពិនិត្យប្រតិបត្តិការនិងការអនុវត្តផែនការថវិកាដែលបានបោះផ្សាយជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុ។

ការចំណាយជាក់ស្តែងដែលលើសពីផែនការថវិកាចុងក្រោយ ១៥% (២៥% លើសពីផែនការថវិកាដើម) សម្រាប់មុខងារសុខាភិបាល គឺដោយសារតែការចំណាយលើសពីកម្រិតដែលបានអនុម័តដោយសកម្មភាពច្បាប់ដើម្បីជាការឆ្លើយតបទៅនឹងគ្រោះរញ្ជួយដី។ ពុំមានភាពខុសគ្នាជាសារវន្តផ្សេងទៀតឡើយ។

***កំណត់សម្គាល់បន្ថែមទី ៩ នៅពេលដែលផែនការថវិកានិងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង តាមមូលដ្ឋានខុសគ្នា***

## ៩. ផែនការថវិកាដែលបានអនុម័តដើមនិងចុងក្រោយ និងការប្រៀបធៀបរវាងចំនួនទឹកប្រាក់ជាក់ស្តែង និងចំនួនទឹកប្រាក់ផែនការថវិកា

ផែនការថវិកាត្រូវបានអនុម័តតាមមូលដ្ឋានសាច់ប្រាក់កែសម្រួល ដោយការធ្វើចំណាត់ថ្នាក់តាមមុខងារ។ ផែនការថវិកាដែលបានអនុម័តគ្របដណ្តប់លើការិយបរិច្ឆេទសារពើពន្ធចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ200X ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ200X និងរួមបញ្ចូលនូវស្ថាប័នទាំងអស់នៅក្នុងវិស័យរដ្ឋាភិបាលទូទៅ។ វិស័យរដ្ឋាភិបាលទូទៅ រួមបញ្ចូលនូវនាយកដ្ឋានរដ្ឋាភិបាលទាំងអស់ - នាយកដ្ឋានសំខាន់ៗត្រូវបានរួមបញ្ចូលនៅក្នុងបញ្ជីស្ថាប័នដែលបានកំណត់នៅក្នុងកំណត់សម្គាល់ទី ៧ ខាងលើ។

ផែនការថវិកាដើម ត្រូវបានអនុម័តដោយសកម្មភាពច្បាប់នា (កាលបរិច្ឆេទ) ហើយវិភាជន៍បន្ថែមនៃ XXX សម្រាប់ការជួយសង្គ្រោះគ្រោះមហន្តរាយត្រូវបានអនុម័តដោយសកម្មភាពច្បាប់នា (កាលបរិច្ឆេទ) ដោយសារការរញ្ជួយដីនៅក្នុងតំបន់ភាគខាងជើងនា (កាលបរិច្ឆេទ) ។ គោលបំណងនិងគោលនយោបាយនៃការរៀបចំផែនការថវិកាដើម និងការកែសម្រួលឡើងវិញជាបន្តបន្ទាប់ត្រូវបានពន្យល់យ៉ាងពេញលេញនៅក្នុងរបាយការណ៍ត្រួតពិនិត្យប្រតិបត្តិការ និងការអនុវត្តផែនការថវិកាដែលបានបោះផ្សាយជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុ។

ការចំណាយជាក់ស្តែងដែលលើសពីផែនការថវិកាចុងក្រោយ ១៥% (២៥% លើសពីផែនការថវិកាដើម) សម្រាប់មុខងារសុខាភិបាល គឺដោយសារតែការចំណាយលើសពីកម្រិតដែលបានអនុម័តដោយសកម្មភាពច្បាប់ដើម្បីជាការឆ្លើយតបទៅនឹងគ្រោះរញ្ជួយដី។ ពុំមានភាពខុសគ្នាជាសារវ័ន្តផ្សេងទៀតឡើយរវាងផែនការថវិកាដែលបានអនុម័តចុងក្រោយ និងចំនួនទឹកប្រាក់ជាក់ស្តែង។

ផែនការថវិកានិងមូលដ្ឋានគណនេយ្យមានភាពខុសគ្នា។ របាយការណ៍ហិរញ្ញវត្ថុសម្រាប់រដ្ឋាភិបាលត្រូវបានរៀបចំឡើងតាមមូលដ្ឋានសាច់ប្រាក់ ដោយប្រើចំណាត់ថ្នាក់ដែលផ្អែកលើចរិកលក្ខណៈនៃចំណាយ។ របាយការណ៍ហិរញ្ញវត្ថុរួមបញ្ចូលនូវស្ថាប័នក្រោមការគ្រប់គ្រងទាំងអស់ រួមទាំងស្ថាប័នវិស័យសាធារណៈពាណិជ្ជកម្មសម្រាប់ការិយបរិច្ឆេទសារពើពន្ធ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០XX ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០XX។ ផែនការថវិកាត្រូវបានអនុម័តតាមមូលដ្ឋានសាច់ប្រាក់កែសម្រួល ដោយការធ្វើចំណាត់ថ្នាក់តាមមុខងារ និងធ្វើការតែជាមួយនឹងវិស័យរដ្ឋាភិបាលទូទៅ ដោយមិនរាប់បញ្ចូលស្ថាប័នសាធារណៈពាណិជ្ជកម្ម និងស្ថាប័ននិងសកម្មភាពដែលមិនមែនជាទីផ្សាររបស់រដ្ឋាភិបាល។

ចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ត្រូវបានកែតម្រូវឱ្យមានសង្គតិភាពជាមួយនឹងមូលដ្ឋានសាច់ប្រាក់កែសម្រួល ហើយត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញដោយការធ្វើចំណាត់ថ្នាក់តាមមុខងារ ដើម្បីឱ្យមានមូលដ្ឋានដូចគ្នាទៅនឹងផែនការថវិកាដែលបានអនុម័តចុងក្រោយ។ លើសពីនេះ ការកែតម្រូវចំនួនទឹកប្រាក់នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់សម្រាប់ភាពខុសគ្នានៃពេលវេលាដែលជាប់ទាក់ទងនឹងវិភាជន៍ និងភាពខុសគ្នានៅក្នុងស្ថាប័នដែលត្រូវបានគ្របដណ្តប់ (ស្ថាប័នសាធារណៈពាណិជ្ជកម្ម និងស្ថាប័នផ្សេងទៀត) ត្រូវបានធ្វើឡើងដើម្បីបង្ហាញពីចំនួនទឹកប្រាក់ជាក់ស្តែងតាមមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបាន ទៅនឹងផែនការថវិកាដែលបានអនុម័តចុងក្រោយ។

ការផ្ទៀងផ្ទាត់រវាងលំហូរចូល និងលំហូរចេញជាក់ស្តែងដែលបានដាក់បង្ហាញនៅក្នុងរបាយការណ៍ប្រៀបធៀបរវាងផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែង និងចំនួនចំណូលសាច់ប្រាក់សរុបនិងចំណាយសាច់ប្រាក់សរុបដែលត្រូវ

បានរាយការណ៍នៅក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ20XX ត្រូវបានដាក់បង្ហាញដូចខាងក្រោម។

| | លំហូរចូលសរុប | លំហូរចេញសរុប |
|---|---|---|
| ចំនួនទឹកប្រាក់ជាក់ស្តែង តាមមូលដ្ឋានដែលអាចប្រៀបធៀបគ្នាបាន ដូចបានដាក់បង្ហាញនៅក្នុងរបាយការណ៍ប្រៀបធៀបរវាងផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែង | X | X |
| ភាពខុសគ្នានៃមូលដ្ឋាន | X | X |
| ភាពខុសគ្នានៃពេលវេលា | - | - |
| ភាពខុសគ្នានៃស្ថាប័ន | X | X |
| ចំណូលសាច់ប្រាក់សរុប | X | |
| ចំណាយសាច់ប្រាក់សរុប | | X |

របាយការណ៍ហិរញ្ញវត្ថុ និងឯកសារផែនការថវិកាត្រូវបានរៀបចំឡើងសម្រាប់ការិយបរិច្ឆេទដូចគ្នា។ មានភាពខុសគ្នានៃស្ថាប័នគឺថា ផែនការថវិកាត្រូវបានរៀបចំឡើងសម្រាប់វិស័យរដ្ឋាភិបាលទូទៅ ហើយរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលនូវស្ថាប័នទាំងអស់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។ ក្នុងនោះ ក៏មានភាពខុសគ្នានៃមូលដ្ឋានផងដែរ គឺថា ផែនការថវិកាត្រូវបានរៀបចំឡើងតាមមូលដ្ឋានសាច់ប្រាក់កែសម្រួល ហើយរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងតាមមូលដ្ឋានសាច់ប្រាក់។

ការផ្ទៀងផ្ទាត់នេះអាចត្រូវបានរួមបញ្ចូលនៅលើផ្ទៃមុខនៃរបាយការណ៍ប្រៀបធៀបរវាងផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែង ឬជាការលាតត្រដាងកំណត់សម្គាល់។

**១០. ការបរិច្ចាគ, អំណោយ និងជំនួយផ្សេងៗ**

ចំណូលសាច់ប្រាក់នៅក្នុងអំឡុងការិយបរិច្ឆេទ រួមមាន ការបរិច្ចាគ, អំណោយ និងជំនួយទាំងឡាយណាដែលត្រូវបានផ្តល់ឱ្យតាមរយៈអង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារម្ចាស់ជំនួយទ្វេភាគីនិងពហុភាគី, ហិរញ្ញប្បទានសហប្រតិបត្តិការដែលត្រូវបានបង្កើតឡើងដោយអង្គការ និងការបរិច្ចាគពីសប្បុរសធម៌, សាជីវកម្ម និងបុគ្គលឯកជន។

ចំនួនទឹកប្រាក់នៃការបរិច្ចាគ អំណោយ និងជំនួយផ្សេងទៀត មិនបានរួមបញ្ចូលនូវជំនួយដែលបានទទួលនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ក្នុងទម្រង់ជាចំណូលពីឥណទាននោះទេ។ ចំណូលពីជំនួយដែលទទួលបាននៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ក្នុងទម្រង់ជាឥណទាន ត្រូវបានរួមបញ្ចូលនៅក្នុងចំនួនកម្ចីដែលត្រូវបានដាក់បង្ហាញជាបន្ទាត់គណនីដាច់ដោយឡែកមួយនៅក្នុងរបាយការណ៍ចំណូលនិងចំណាយ។

## ឧបសម្ព័ន្ធ ១២ - ស្ថាប័នរបស់រដ្ឋាភិបាល "ខ"

(ស្ថាប័ននេះគ្រប់គ្រងគណនីធនាគាររបស់ខ្លួនផ្ទាល់)
របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ សម្រាប់ស្ថាប័ន "ខ"
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០X

| | កំណត់សម្គាល់ | ២០០X | ២០០X-១ |
|---|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | | ចំណូល/(ចំណាយ) | ចំណូល/(ចំណាយ) |
| ចំណូល | | | |
| ការបែងចែកដែលបានអនុញ្ញាត | | X | X |
| ចំណូលផ្សេងៗ | | X | X |
| ចំណូលសរុប | | X | X |
| ចំណាយ | | | |
| ប្រាក់ឈ្នួល ប្រាក់បៀវត្ស និង អត្ថប្រយោជន៍និយោជិក | | (X) | (X) |
| ថ្លៃជួល | | (X) | (X) |
| ចំណាយមូលធន | | (X) | (X) |
| ការផ្ទេរ | ៣ | (X) | (X) |
| ចំណាយសរុប | | (X) | (X) |
| ការកើនឡើង/(ការថយចុះ) នៃសាច់ប្រាក់ | | X | X |
| | | | |
| សាច់ប្រាក់ដើមគ្រា | ២ | X | X |
| ការកើនឡើង/(ការថយចុះ) នៃសាច់ប្រាក់ | | X | X |
| សាច់ប្រាក់ចុងគ្រា | ២ | X | X |

## របាយការណ៍ហិរញ្ញវត្ថុបន្ថែម (ជាជម្រើស)

របាយការណ៍ហិរញ្ញវត្ថុបន្ថែមអាចត្រូវបានរៀបចំឡើង ឧទាហរណ៍ ដើម្បីលាតត្រដាងព័ត៌មានអំពីផែនការថវិកាតាមក្រុមមូលនិធិសំខាន់ៗ ប្រសិនបើអាច ឬដើម្បីបង្ហាញការចំណាយតាមមុខងារសំខាន់ៗ។ ឧទាហរណ៍អំពីរបាយការណ៍តាមមុខងារ ត្រូវបានរួមបញ្ចូលដូចខាងក្រោម។

### របាយការណ៍ចំណាយតាមមុខងារ

| | កំណត់សម្គាល់ | ២០0X | ២០0X-១ |
|---|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | | ចំណាយ | ចំណាយ |
| ចំណាយ | | | |
| កម្មវិធី I | | (X) | (X) |
| កម្មវិធី II | | (X) | (X) |
| កម្មវិធី III | | (X) | (X) |
| កម្មវិធី IV | | (X) | (X) |
| ចំណាយផ្សេងៗ | | (X) | (X) |
| ចំណាយសរុប | | (X) | (X) |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

### ១. គោលនយោបាយគណនេយ្យ

#### មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានសាច់ប្រាក់, *ការរាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់។*

គោលនយោបាយគណនេយ្យត្រូវបានអនុវត្តប្រកបដោយសង្គតិភាពពេញមួយការិយបរិច្ឆេទ។

#### ស្ថាប័នរាយការណ៍

របាយការណ៍ហិរញ្ញវត្ថុ គឺសម្រាប់ស្ថាប័នសាធារណៈ (ស្ថាប័នរដ្ឋាភិបាល "ខ")។ របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលនូវស្ថាប័នរាយការណ៍ដូចបានបញ្ជាក់នៅក្នុងច្បាប់ពាក់ព័ន្ធ (ច្បាប់ហិរញ្ញវត្ថុសាធារណៈ ២០XX) ។

សកម្មភាពសំខាន់របស់ស្ថាប័នរដ្ឋាភិបាល "ខ" គឺដើម្បីផ្តល់ [កំណត់ប្រភេទ] សេវាទៅឱ្យអង្គភាពនានា។ ស្ថាប័នគ្រប់គ្រងគណនីធនាគាររបស់ខ្លួនផ្ទាល់។

**រូបិយបណ្ណសម្រាប់បង្ហាញ**

រូបិយបណ្ណសម្រាប់បង្ហាញ គឺ (រូបិយបណ្ណរបស់ប្រទេស "ក")។

**២. សាច់ប្រាក់**

សាច់ប្រាក់ រួមមាន សាច់ប្រាក់ក្នុងដៃ, ប្រាក់បញ្ញើគ្មានកាលកំណត់ និងសាច់ប្រាក់សមមូល។ ប្រាក់បញ្ញើគ្មានកាលកំណត់ និងសាច់ប្រាក់សមមូលរួមមាន សមតុល្យធនាគារ និងការវិនិយោគលើឧបករណ៍ទីផ្សារហិរញ្ញវត្ថុរយៈពេលខ្លី។

វិភាជន៍ និងចំណូលសាច់ប្រាក់ផ្សេងទៀតត្រូវបានដាក់បញ្ញើនៅក្នុងគណនីធនាគារផ្ទាល់របស់ស្ថាប័ន។ កម្ចីទាំងអស់ត្រូវបានអនុវត្តដោយស្ថាប័នហិរញ្ញវត្ថុកណ្តាល។

ចំណូលពីប្រតិបត្តិការប្តូរប្រាក់ ត្រូវបានដាក់បញ្ញើនៅក្នុងគណនីមូលនិធិជួញដូរដែលគ្រប់គ្រងដោយស្ថាប័ន។ ចំណូលត្រូវបានផ្ទេរទៅកាន់ប្រាក់ចំណូលរួម នាចុងឆ្នាំ។

សាច់ប្រាក់ដែលបានរួមបញ្ចូលក្នុងរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ រួមមានចំនួនទឹកប្រាក់ដូចខាងក្រោម÷

| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | ២០0X | ២០0X-១ |
|---|---|---|
| សាច់ប្រាក់ក្នុងដៃ និងសមតុល្យធនាគារ | X | X |
| ការវិនិយោគរយៈពេលខ្លី | X | X |
| | X | X |

**៣. ការផ្ទេរ**

ចំនួនទឹកប្រាក់ត្រូវបានផ្ទេរទៅឱ្យអ្នកទទួលសិទ្ធិ ដោយអនុលោមតាមអាណត្តិប្រតិបត្តិការ និងអាជ្ញាធររបស់ស្ថាប័ន។

**៤. ស្ថាប័នសំខាន់ៗ**

| ស្ថាប័ន ២០0X | ស្ថាប័ន ២០0X-១ |
|---|---|
| ស្ថាប័ន X | X |
| ស្ថាប័ន Y | X |

**៥. កាលបរិច្ឆេទអនុញ្ញាតចេញផ្សាយ**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានផ្តល់សិទ្ធិសម្រាប់ការចេញផ្សាយនា ថ្ងៃទីXX ខែ ឆ្នាំ២០0X+១ ដោយ លោក XX, រដ្ឋមន្ត្រីក្រសួង XXXXX របស់ស្ថាប័ន "កខ"។

**ឧបសម្ព័ន្ធ ១គ - នាយកដ្ឋានរបស់រដ្ឋាភិបាល "គ"**

(រដ្ឋាភិបាលអនុវត្តប្រព័ន្ធគណនីទោលមជ្ឈការ)

របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ សម្រាប់នាយកដ្ឋាន "គ"

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០X

| | កំណត់សម្គាល់ | ២០០X | ២០០X-១ |
|---|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | | ចំណូល/(ចំណាយ) | ចំណូល/(ចំណាយ) |
| **ចំណូល** | | | |
| វិភាជន៍ | ២ | X | X |
| ចំណូលផ្សេងៗ | | X | X |
| **ចំណូលសរុប** | | X | X |
| **ចំណាយ** | | | |
| ប្រាក់ឈ្នួល ប្រាក់បៀវត្ស និង អត្ថប្រយោជន៍និយោជិក | | (X) | (X) |
| ថ្លៃជួល | | (X) | (X) |
| ចំណាយមូលធន | | (X) | (X) |
| ការផ្ទេរ | ៣ | (X) | (X) |
| **ចំណាយសរុប** | | (X) | (X) |

**របាយការណ៍ហិរញ្ញវត្ថុបន្ថែម (ជាជម្រើស)**

ឧទាហរណ៍ របាយការណ៍ហិរញ្ញវត្ថុបន្ថែម ត្រូវបានរៀបចំឡើងដើម្បីលាតត្រដាងព័ត៌មានអំពីផែនការថវិកាតាមក្រុមមូលនិធិសំខាន់ៗ ប្រសិនបើអាច ឬដើម្បីបង្ហាញការចំណាយតាមមុខងារ ឬចំណាយសំខាន់ៗ។ ឧទាហរណ៍អំពីរបាយ-ការណ៍តាមមុខងារ ត្រូវបានរួមបញ្ចូលដូចខាងក្រោម។

**របាយការណ៍ចំណាយតាមមុខងារ**

| | កំណត់សម្គាល់ | ២០០X | ២០០X-១ |
|---|---|---|---|
| (ឯកតារូបិយបណ្ណគិតជាខ្ទង់ពាន់) | | ចំណូល/(ចំណាយ) | ចំណូល/(ចំណាយ) |
| ចំណាយ | | | |
| កម្មវិធី I | | X | X |
| កម្មវិធី II | | X | X |
| កម្មវិធី III | | X | X |
| កម្មវិធី IV | | X | X |
| ចំណាយផ្សេងៗ | | X | X |
| ចំណាយសរុប | | X | X |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ**

**១. <u>គោលនយោបាយគណនេយ្យ</u>**

**មូលដ្ឋាននៃការរៀបចំ**

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ មូលដ្ឋានសាច់ប្រាក់, *ការរាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់*។

គោលនយោបាយគណនេយ្យត្រូវបានអនុវត្តប្រកបដោយសង្គតិភាពពេញមួយការិយបរិច្ឆេទ។

**ស្ថាប័នរាយការណ៍**

របាយការណ៍ហិរញ្ញវត្ថុ គឺសម្រាប់ស្ថាប័នសាធារណៈ÷ នាយកដ្ឋានរបស់រដ្ឋាភិបាល "គ"។ របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលនូវស្ថាប័នរាយការណ៍ ដូចបានចែងនៅក្នុងច្បាប់ពាក់ព័ន្ធ (ច្បាប់ហិរញ្ញវត្ថុសាធារណៈ ២០XX) ។

សកម្មភាពសំខាន់របស់នាយកដ្ឋានរបស់រដ្ឋាភិបាល "គ" គឺដើម្បីផ្តល់ (បញ្ជាក់ប្រភេទ) សេវាទៅឱ្យអង្គភាពនានា។

នាយកដ្ឋានរបស់រដ្ឋាភិបាល "គ" មិនធ្វើប្រតិបត្តិការនៅក្នុងគណនីធនាគារផ្ទាល់ខ្លួននោះទេ។ រដ្ឋាភិបាលអនុវត្តមុខងារធនាគារមជ្ឈការដើម្បីគ្រប់គ្រងចំណូលនិងចំណាយសាច់ប្រាក់ (ការចំណាយ) របស់នាយកដ្ឋាននៅក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ។

**រូបិយបណ្ណសម្រាប់បង្ហាញ**

រូបិយបណ្ណសម្រាប់បង្ហាញ គឺ (រូបិយបណ្ណរបស់ប្រទេស "ក")។

**២. ចំនួនទឹកប្រាក់ដែលបានអនុញ្ញាតសម្រាប់ការប្រើប្រាស់នៅក្នុងនាយកដ្ឋាន "គ"**

ចំនួនទឹកប្រាក់ដែលបានអនុញ្ញាតសម្រាប់ការប្រើប្រាស់នៅក្នុងនាយកដ្ឋាន "គ" ត្រូវបានគ្រប់គ្រងតាមរយៈគណនីកណ្តាលដែលគ្រប់គ្រងដោយការិយាល័យរតនាគាររបស់នាយកដ្ឋាន។ ចំនួនទឹកប្រាក់ត្រូវបានប្រើប្រាស់ជំនួសឱ្យនាយកដ្ឋាន "គ" តាមសំណើនៅពេលត្រូវបានគាំទ្រតាមរយៈការដាក់បង្ហាញឯកសារសមស្រប និងមានការផ្តល់សិទ្ធិអនុញ្ញាត។ រាល់កម្ចីទាំងអស់ត្រូវបានអនុវត្តដោយស្ថាប័នហិរញ្ញវត្ថុកណ្តាល។

ចំនួនទឹកប្រាក់ដែលត្រូវបានអនុញ្ញាតសម្រាប់ការប្រើប្រាស់នៅក្នុងនាយកដ្ឋាន ដែលជាចំនួនទឹកប្រាក់មិនទាន់បានចំណាយនាចុងឆ្នាំ ត្រូវបានផ្ទេរទៅកាន់ប្រាក់ចំណូលរួម។

**៣. ការផ្ទេរ**

ចំនួនទឹកប្រាក់ត្រូវបានផ្ទេរទៅឱ្យអ្នកទទួលសិទ្ធិ ដោយអនុលោមតាមអាណត្តិប្រតិបត្តិការ និងអាជ្ញាធររបស់នាយកដ្ឋាន "កគ"។

**៤. កាលបរិច្ឆេទអនុញ្ញាតចេញផ្សាយ**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានផ្តល់សិទ្ធិសម្រាប់ការចេញផ្សាយនា ថ្ងៃទីXX ខែ ឆ្នាំ២០០X+១ ដោយ លោក XX, រដ្ឋមន្ត្រីក្រសួង XXXXX នៃស្ថាប័ន "គ"។

**ផ្នែកទី ២៖ ការរាយការណ៍ហិរញ្ញវត្ថុក្រោមមូលដ្ឋានគណនេយ្យសាច់ប្រាក់ -- ការលាតត្រដាងបន្ថែមដែលត្រូវបានលើកទឹកចិត្ត**

ផ្នែកនេះនៃស្តង់ដា មិនមែនចាំបាច់ត្រូវតែអនុវត្តនោះទេ។ ផ្នែកនេះត្រូវបានរៀបចំឡើងដើម្បីគាំទ្រស្ថាប័នដែលកំពុងផ្លាស់ប្តូរពីការប្រើប្រាស់មូលដ្ឋានគណនេយ្យសាច់ប្រាក់ ទៅកាន់មូលដ្ឋានបង្គរនៃការរាយការណ៍ហិរញ្ញវត្ថុ និងការប្រើប្រាស់ស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ។ ផ្នែកនេះកំណត់ពីការលាតត្រដាងបន្ថែមដែលត្រូវបានលើកទឹកចិត្តសម្រាប់ការរាយការណ៍ក្រោមមូលដ្ឋានគណនេយ្យសាច់ប្រាក់។ ផ្នែកនេះគួរត្រូវបានអាន ជាមួយគ្នានឹងផ្នែកទី ១ នៃស្តង់ដានេះ ដែលបានកំណត់ពីលក្ខខណ្ឌចាំបាច់សម្រាប់ការរាយការណ៍ ក្រោមមូលដ្ឋានគណនេយ្យសាច់ប្រាក់។ ការលាតត្រដាងដែលត្រូវបានលើកទឹកចិត្តដែលត្រូវបានកំណត់ជាប្រភេទតួអក្សរទ្រេត គួរត្រូវបានអាននៅក្នុងបរិបទជាកថាខណ្ឌបែបអត្ថាធិប្បាយនៅក្នុងផ្នែកនេះនៃស្តង់ដាដែលមានលក្ខណៈសាមញ្ញ។

ស្ថាប័នរាយការណ៍គួរតែបង្ហាញផ្លូវរបស់គេទៅកាន់ការប្រើប្រាស់ស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ និងចាប់ផ្តើមដំណើរការនៃការកសាងព័ត៌មានចាំបាច់ដើម្បីអនុលោមតាមស្តង់ដា IPSAS ទាំងនោះ ដែលមានសង្គតិភាពជាមួយនឹងផ្លូវអន្តរកាលដែលត្រូវបានប្រើប្រាស់។

**ការរាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់ ផ្នែកទី ២ ÷ ការលាតត្រដាងបន្ថែមដែលត្រូវបានលើកទឹកចិត្ត**

*ការលាតត្រដាងបន្ថែមដែលបានលើកទឹកចិត្តត្រូវបានកំណត់ជាប្រភេទអក្សរទ្រេត។ ពួកគេនឹងត្រូវបានអាននៅក្នុងបរិបទជាកថាខណ្ឌបែបអត្ថាធិប្បាយ នៅក្នុងផ្នែកទី ២ នៃស្តង់ដានេះដែលជាប្រភេទភាសាធម្មតា។*

**២.១ ការលាតត្រដាងបន្ថែមដែលត្រូវបានលើកទឹកចិត្ត**

**និយមន័យ**

២.១.១ *ពាក្យខាងក្រោមត្រូវបានប្រើនៅក្នុងផ្នែកនេះនៃស្តង់ដាជាមួយនឹងនិយមន័យដូចបានបញ្ជាក់÷*

*មូលដ្ឋានបង្គរ មានន័យថាជាមូលដ្ឋានគណនេយ្យមួយដែលប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងទៀតត្រូវបានទទួលស្គាល់នៅពេលពួកគេកើតឡើង (និងមិនមែនតែនៅពេលដែលសាច់ប្រាក់ ឬសមមូលសាច់ប្រាក់ត្រូវបានទទួល ឬទូទាត់ឡើយ)។ ដូច្នេះ ប្រតិបត្តិការនិងព្រឹត្តិការណ៍ត្រូវបានកត់ត្រាទុកនៅក្នុងបញ្ជីគណនេយ្យ និងត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុចំពោះការិយបរិច្ឆេទ ដែលពាក់ព័ន្ធ។ ធាតុដែលបានទទួលស្គាល់តាមគណនេយ្យបង្គរ គឺ ទ្រព្យសកម្ម, បំណុល, ទ្រព្យសកម្មសុទ្ធ ឬមូលធនសុទ្ធ, ចំណូល និងចំណាយ។*

*ទ្រព្យសកម្ម គឺជាធនធានដែលបានគ្រប់គ្រងដោយស្ថាប័នមួយដែលជាលទ្ធផលនៃព្រឹត្តិការណ៍នាពេលអតីតកាល និងដែលអត្ថប្រយោជន៍សេដ្ឋកិច្ចឬសក្តានុពលសេវានាពេលអនាគតត្រូវបានរំពឹងថានឹងហូរចូលទៅកាន់ស្ថាប័នតាមរយៈធនធានទាំងនោះ។*

*បន្ទុកលើប្រាក់កម្ចី គឺជាការប្រាក់ និងចំណាយផ្សេងទៀតដែលត្រូវបានបង្កើតឡើងដោយស្ថាប័នមួយទាក់ទងនឹងកម្ចីមូលនិធិ។*

*អត្រាប្តូរប្រាក់ចុងគ្រា គឺជាអត្រាប្តូរប្រាក់ដល់ដៃ នាកាលបរិច្ឆេទរាយការណ៍។*

*ការចែកចាយទៅកាន់ម្ចាស់ គឺជាអត្ថប្រយោជន៍សេដ្ឋកិច្ច ឬសក្តានុពលសេវាដែលបានបែងចែកដោយស្ថាប័នទៅកាន់ម្ចាស់ទាំងអស់ ឬម្ចាស់មួយចំនួនរបស់ខ្លួន ដែលជាចំណូលពីការវិនិយោគទុន ឬចំណូលនៃការវិនិយោគទុន។*

*ចំណាយ គឺជាការធ្លាក់ចុះនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬសក្តានុពលសេវានៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ក្នុងទម្រង់ជាលំហូរចេញ ឬការប្រើប្រាស់ទ្រព្យសកម្ម ឬការជាប់បំណុលដែលឱ្យផលជាការធ្លាក់ចុះនៃទ្រព្យសកម្មសុទ្ធឬមូលធនសុទ្ធ ជាជាងចំណាយដែលពាក់ព័ន្ធនឹងការចែកចាយទៅកាន់ម្ចាស់។*

*<u>បំណុល</u> គឺជាកាតព្វកិច្ចបច្ចុប្បន្នរបស់ស្ថាប័នដែលកើតឡើងពីព្រឹត្តិការណ៍នាពេលអតីតកាល, ការទូទាត់ដែលត្រូវបានរំពឹងទុកថានឹងឱ្យផលជាលំហូរចេញពីស្ថាប័ន នូវធនធានដែលតំណាងឱ្យអត្ថប្រយោជន៍សេដ្ឋកិច្ច ឬសក្ដានុពលសេវា។*

*<u>ចំណូល</u> គឺជាលំហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬសក្ដានុពលសេវានៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ នៅពេលលំហូរចូលទាំងនោះឱ្យផលជាការកើនឡើងទ្រព្យសកម្មសុទ្ធ ឬមូលធនសុទ្ធ ជាជាងការកើនឡើងដែលពាក់ព័ន្ធនឹងការចូលរួមវិភាគទានពីម្ចាស់។*

*ពាក្យដែលត្រូវបានផ្ដល់និយមន័យនៅក្នុងផ្នែកទី ១ នៃស្តង់ដានេះ ត្រូវបានប្រើនៅក្នុងផ្នែកនៃស្តង់ដានេះជាមួយនឹងនិយមន័យដែលបានផ្ដល់របស់ពួកគេ។*

**អត្ថប្រយោជន៍សេដ្ឋកិច្ច ឬសក្ដានុពលសេវានាពេលអនាគត**

២.១.២ ទ្រព្យសកម្មដោយរួមបញ្ចូលទាំងសាច់ប្រាក់និងធនធានដទៃ ផ្ដល់នូវមធ្យោបាយមួយដល់ស្ថាប័នក្នុងការសម្រេចបាននូវគោលបំណងរបស់ខ្លួន។ ទ្រព្យសកម្មដែលត្រូវបានប្រើប្រាស់ដើម្បីផ្ដល់ទំនិញ និងសេវាដោយអនុលោមតាមគោលបំណងរបស់ស្ថាប័នប៉ុន្តែមិនបានបង្កើតលំហូរសាច់ប្រាក់សុទ្ធ តែងត្រូវបានពិពណ៌នាថាតំណាងឱ្យ "សក្ដានុពលសេវា"។ ដើម្បីរួមបញ្ចូលនូវគោលបំណងទាំងអស់ដែលទ្រព្យសកម្មត្រូវបានដាក់សំដៅលើ ស្តង់ដានេះប្រើពាក្យថា "អត្ថប្រយោជន៍សេដ្ឋកិច្ច ឬសក្ដានុពលសេវានាពេលអនាគត" ដើម្បីពិពណ៌នាអំពីបុគ្គលិកលក្ខណៈសំខាន់របស់ទ្រព្យសកម្ម។

**និរន្តរភាព**

២.១.៣ *នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នមួយ អ្នកដែលមានការទទួលខុសត្រូវចំពោះការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលើកទឹកចិត្តឱ្យធ្វើការវាយតម្លៃអំពីសមត្ថភាពរបស់ស្ថាប័ន ដើម្បីបន្តជានិរន្តរភាព។ នៅពេលអ្នកដែលមានការទទួលខុសត្រូវចំពោះការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបានដឹង ក្នុងដំណើរការវាយតម្លៃរបស់ពួកគេ អំពីភាពមិនច្បាស់លាស់ភាពជាសារវន្តពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចនាំឱ្យមានមន្ទិលអំពីសមត្ថភាពរបស់ស្ថាប័ន ដើម្បីបន្តជានិរន្តរភាព នោះការលាតត្រដាងអំពីភាពមិនច្បាស់លាស់ទាំងនោះត្រូវបានលើកទឹកចិត្ត។*

២.១.៤ ការកំណត់ថាតើស្ថាប័នមួយជានិរន្តរភាព មានជាប់ពាក់ព័ន្ធជាសំខាន់សម្រាប់ស្ថាប័ននីមួយៗ ជាជាងសម្រាប់រដ្ឋាភិបាលទាំងមូល។ សម្រាប់ស្ថាប័ននីមួយៗ ក្នុងការវាយតម្លៃថាតើស្ថាប័នគឺជានិរន្តរភាព អ្នកដែលមានទំនួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ÷

(ក) នឹងចាំបាច់ត្រូវពិចារណានូវរាល់ព័ត៌មានទាំងអស់ សម្រាប់អនាគតដែលអាចព្យាករណ៍បាន ដែលនឹងរួមបញ្ចូលនូវប៉ុន្តែនឹងមិនកំណត់ត្រឹមរយៈពេលដប់ពីរ (១២) ខែ គិតចាប់ពីការអនុម័តរបាយ-ការណ៍ហិរញ្ញវត្ថុ និង

(ខ) អាចចាំបាច់ត្រូវពិចារណាអំពីកត្តាផ្សេងៗជាច្រើនពាក់ព័ន្ធនឹងប្រតិបត្តិការនាពេលបច្ចុប្បន្ន និងប្រតិបត្តិការដែលបានរំពឹងទុក, ការរៀបចំរចនាសម្ព័ន្ធឡើងវិញដ៏មានសក្តានុពល និងដែលត្រូវបានប្រកាសចំពោះស្ថាប័នក្រោមចំណុះ, ការប៉ាន់ស្មានអំពីចំណូល ឬភាពដែលអាចទៅរួចនៃមូលនិធិរបស់រដ្ឋាភិបាលដែលបានបន្ត និងប្រភពចម្បងនៃការផ្តល់ហិរញ្ញប្បទានជំនួស មុនពេលដែលវាមានភាពសមស្របដើម្បីធ្វើការសន្និដ្ឋានថា ស្ថាប័ននឹងបន្តជានិរន្តរភាព។

២.១.៥ អាចមានស្ថានភាពមួយចំនួនដែលការធ្វើតេស្តពីនិរន្តរភាពធម្មតានៃសន្ទនីយភាព និងសាធនភាពដូចបានអនុវត្តចំពោះសហគ្រាសពាណិជ្ជកម្មមិនមានភាពអនុគ្រោះ ប៉ុន្តែកត្តាផ្សេងទៀតបានស្នើថា ស្ថាប័នគឺជានិរន្តរភាព។ ឧទាហរណ៍៖

(ក) ក្នុងការវាយតម្លៃថាតើរដ្ឋាភិបាលគឺជានិរន្តរភាពមួយ អំណាចដើម្បីកំណត់ពីអត្រាពន្ធនាំចូល ឬពន្ធ អាចអនុញ្ញាតឱ្យស្ថាប័នមួយចំនួនត្រូវបានពិចារណាថាជានិរន្តរភាពមួយ បើទោះបីជាចំណាយសាច់ប្រាក់របស់ស្ថាប័នអាចលើសពីចំណូលសាច់ប្រាក់របស់គេ សម្រាប់ការិយបរិច្ឆេទពន្យារក៏ដោយ

(ខ) សម្រាប់ស្ថាប័នមួយ ការវាយតម្លៃអំពីលំហូរសាច់ប្រាក់របស់ខ្លួនសម្រាប់ការិយបរិច្ឆេទរាយការណ៍មួយអាចស្នើថា ស្ថាប័នមិនមែនជានិរន្តរភាពនោះទេ។ ទោះបីជាយ៉ាងណា អាចមានកិច្ចព្រមព្រៀងផ្តល់មូលនិធិច្រើនឆ្នាំដែលមានស្រាប់ជាមួយនឹងរដ្ឋាភិបាល ដែលនឹងធានាដល់ប្រតិបត្តិការបន្តរបស់ស្ថាប័ន។

## ប្រតិបត្តិការដែលត្រូវបានគ្រប់គ្រង

២.១.៦ *ស្ថាប័នត្រូវបានលើកទឹកចិត្តឱ្យដាក់បង្ហាញនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ នូវចំនួន និងចរិកលក្ខណៈនៃលំហូរសាច់ប្រាក់និងសមតុល្យសាច់ប្រាក់ដែលកើតឡើងពីប្រតិបត្តិការ ដែលត្រូវបានគ្រប់គ្រងដោយស្ថាប័នក្នុងនាមជាភ្នាក់ងារមួយជំនួសឱ្យបុគ្គលដទៃ ដែលចំនួនទាំងនោះស្ថិតនៅក្រៅការគ្រប់គ្រងរបស់ស្ថាប័ន។*

២.១.៧ លំហូរសាច់ប្រាក់ពាក់ព័ន្ធនឹងប្រតិបត្តិការដែលត្រូវបានគ្រប់គ្រងដោយស្ថាប័នមួយ ដែលដើរតួជាភ្នាក់ងារមួយជំនួសឱ្យបុគ្គលដទៃ មិនអាចឆ្លងកាត់គណនីធនាគារដែលបានគ្រប់គ្រងដោយស្ថាប័នរាយការណ៍នោះទេ។ នៅក្នុងករណីទាំងនេះ ស្ថាប័នមិនអាចប្រើឬក៏ទទួលបានអត្ថប្រយោជន៍ពីសាច់ប្រាក់ដែលខ្លួនគ្រប់គ្រងដើម្បីសម្រេចបាននូវគោលបំណងផ្ទាល់ខ្លួនរបស់ស្ថាប័នឡើយ។ លំហូរសាច់ប្រាក់ទាំងនេះមិនត្រូវបានគ្រប់គ្រងដោយស្ថាប័នទេ ហើយដូច្នេះមិនត្រូវបានរួមបញ្ចូលជាចំនួនសាច់ប្រាក់សរុបដូចបានបង្ហាញនៅលើផ្ទៃមុខនៃរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ឬរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលអាចត្រូវបានរៀបចំឡើងនោះទេ។ ទោះបីជាយ៉ាងណា ការដាក់បង្ហាញអំពីចំនួនទឹកប្រាក់ និងចរិកលក្ខណៈនៃប្រតិបត្តិការទាំងនេះតាមប្រភេទសំខាន់ៗត្រូវបានលើកទឹកចិត្ត ពីព្រោះវាផ្តល់នូវព័ត៌មាន



តទៅរាជកិច្ចលេខ ៨៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ :១៣៣.ឧស.ក.ប.ក.១៦

ថ្ងៃ...ចន្ទ ១២ កើត.........ខែ.ផល្គុន...ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៨.....ខែ.មីនា..ឆ្នាំ២០១៩

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងប្តូរប្រកាសបង្កើតរោងចក្រទម្រង់ថ្មី ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ថិចភែក ភែកឃិជីង (ខេមបូឌា)

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ថិចភែក ភែកឃិជីង (ខេមបូឌា) (TEXPACK PACKAGING (CAMBODIA) LTD.) តំណាងដោយលោក **WANG BIZHONG** បង្កើតរោងចក្រផលិតសម្ភារៈវេចខ្ចប់ ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូជឿង ឃុំបិតត្រាំង និងភូមិស្ទឹងជ្រៅ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ)។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ១- សម្ភារៈវេចខ្ចប់ (ពីក្រដាស) | ១៧០២ |
| ២- សម្ភារៈវេចខ្ចប់ (ពីប្លាស្ទិក) | ២២២០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រផលិតសម្ភារៈវេចខ្ចប់ ប៊ិចកែក កែកឃិជីង (ខេមបូឌា) "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់ហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ ០២៩៣ ឧស.កឧ.ប្រក.១០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**មាន សុភា**

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តព្រះសីហនុ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ
-អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ
-រដ្ឋបាលស្រុកព្រៃនប់
-រដ្ឋបាលឃុំបិតត្រាំង និងឃុំរាម
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី